ខែមករា ឆ្នាំ២០១២

# ការផ្តន្ទាទោសសមាមាត្រនឹងបទល្មើស ៖ ការផ្តន្ទាទោស និងការលុបបំបាត់អំពើហិង្សាដោយអាស៊ីដដ៏មានប្រសិទ្ធភាព នៅកម្ពុជា តាមរយៈ ការបង្កើត និងការអនុវត្តន៍ច្បាប់

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

## មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ម.ស.ម.ក)

ម.ស.ម.ក គឺជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ និងមិនចូលបក្សសម្ព័ន្ធ ដែលធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្សនៅព្រះរាជាណាចក្រកម្ពុជា (កម្ពុជា)។ ទស្សនវិស័យរបស់យើង គឺកម្ពុជាគ្មានអំពើហិង្សា ដែលប្រជាពលរដ្ឋទទួលបានសិទ្ធិជាមូលដ្ឋាន មានសិទ្ធិស្មើគ្នា និងត្រូវបានផ្តល់អំណាច ដើម្បីចូលរួមក្នុងលិទ្ធិប្រជាធិបតេយ្យ និងទទួលបានការចែករំលែកផលប្រយោជន៍ពីការអភិវឌ្ឍន៍ប្រទេសកម្ពុជា។ យើងចង់បាននីតិរដ្ឋជាជាងនិទណ្ឌភាព ស្ថាប័នរឹងមាំជាជាងបុគ្គលខ្លាំង និងសង្គមសេរីពហុបក្សដែលភាពចម្រុះត្រូវបានគេស្វែងរក និងអបអរសាទរជាជាងការមិនអើពើ និងការដាក់ទោស។ ស្លាកសញ្ញារបស់យើង គឺរូបសត្វព្រាបសហើរចេញពីរង្វង់ផ្ទៃមេឃពណ៌ខៀវ ដែលតំណាងឲ្យការទាមទារសេរីភាពនៅកម្ពុជា។

## សេចក្តីថ្លែងអំណរគុណ

របាយការណ៍ "*ការផ្តន្ទាទោសសមាមាត្រនឹងបទល្មើស ៖ ការផ្តន្ទាទោស និងលុបបំបាត់អំពើហិង្សាដោយអាស៊ីដដ៏មានប្រសិទ្ធភាព នៅកម្ពុជា តាមរយៈការបង្កើត និងការអនុវត្តន៍ច្បាប់*" (របាយការណ៍) ទទួលការគាំទ្រផ្នែកមូលនិធិពី ក្រសួងការបរទេសសហរដ្ឋអាមេរិក។ តែរាល់គំនិត របកគំហើញ និងសេចក្តីសន្និដ្ឋាននៅទីនេះ ជាគំនិតរបស់អ្នកនិពន្ធ និងមិនបានឆ្លុះបញ្ចាំងពីទស្សនៈរបស់ក្រសួងការបរទេសសហរដ្ឋអាមេរិកនោះទេ។

## សំណួរ ឬការផ្តល់មតិយោបល់កែលម្អ

ប្រសិនបើអ្នកមានសំណួរ ឬចង់បានព័ត៌មានបន្ថែមអំពីរបាយការណ៍នេះ ឬមានបំណងចង់ផ្តល់មតិយោបល់កែលម្អ សូមអ៊ីម៉ែលមកកាន់ info@cchrcambodia.org ។

របាយការណ៍នេះ និងការបោះពុម្ពផ្សាយដទៃទៀតរបស់ ម.ស.ម.ក គឺអាចរកបាននៅលើ គេហទំព័ររបស់ ម.ស.ម.ក www.cchrcambodia.org និងគេហទំព័រសិទ្ធិមនុស្ស របស់ ម.ស.ម.ក www.sithi.org ។

(CC) ឆ្នាំ២០១១ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
ផ្ទះលេខ ៧៩៨ ផ្លូវលេខ ៩៩ បឹងត្របែក
ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

# មាតិកា


និយមន័យ និងអក្សរកាត់...............................................................................................................៣

១. សេចក្តីផ្តើម........................................................................................................................................៤
១.១ អំពើហិង្សាដោយអាស៊ីដនៅកម្ពុជា...............................................................................................៥
២.២ ក្របខណ្ឌច្បាប់បច្ចុប្បន្ន...........................................................................................................៦

២. បទប្បញ្ញត្តិសំខាន់ៗសម្រាប់ច្បាប់ស្តីពីការគ្រប់គ្រងអាស៊ីដ...............................................................៨
២.១ ការចាត់ទុកអំពើហិង្សាដោយអាស៊ីដជាបទល្មើស.........................................................................៨
២.២ ការគ្រប់គ្រងការលក់ ចែកចាយ និងកាន់កាប់អាស៊ីដខ្លាំង...............................................................៩
២.៣ ការកាត់ទោស និងផ្តន្ទាទោស..................................................................................................១១
(ក) ការកាត់ទោស...........................................................................................................១១
(ខ) ការផ្តន្ទាទោស..........................................................................................................១២
២.៤ ការគាំពារជនរងគ្រោះ.............................................................................................................១២
(ក) ការគាំពារផ្នែកវេជ្ជសាស្ត្រ...........................................................................................១៣
(ខ) ការគាំពារផ្នែកច្បាប់...................................................................................................១៤

៣. សេចក្តីព្រាងច្បាប់អាស៊ីដសម្រាប់កម្ពុជា......................................................................................១៥
៣.១ ការចាត់ទុកអំពើហិង្សាដោយអាស៊ីដជាបទល្មើស.......................................................................១៥
អនុសាសន៍...................................................................................................................១៧
៣.២ ការគ្រប់គ្រងការលក់ ចែកចាយ និងកាន់កាប់អាស៊ីដខ្លាំង............................................................១៧
អនុសាសន៍...................................................................................................................១៩
៣.៣ ការកាត់ទោស និងផ្តន្ទាទោស................................................................................................២០
អនុសាសន៍...................................................................................................................២១
៣.៤ ការគាំពារជនរងគ្រោះ...........................................................................................................២១
(ក) ការគាំពារផ្នែកវេជ្ជសាស្ត្រ..........................................................................................២២
(ខ) ការគាំពារផ្នែកច្បាប់..................................................................................................២៣
អនុសាសន៍...................................................................................................................២៤

៤. សេចក្តីសន្និដ្ឋាន..........................................................................................................................២៦

៥. ឧបសម្ព័ន្ធ ច្បាប់ស្តីពីការគ្រប់គ្រងអាស៊ីដខ្លាំង..................................................................................២៧

៦. គន្ថនិទ្ទេស...................................................................................................................................៣៣

# និយមន័យ និងអក្សរកាត់

| | |
|---|---|
| ច្បាប់គ្រប់គ្រងអាស៊ីដខ្លាំង | ច្បាប់ស្តីពីការគ្រប់គ្រងអាស៊ីដខ្លាំង របស់កម្ពុជា អនុម័តនៅថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០១១ និងចូលជាធរមាននៅខែធ្នូ ឆ្នាំ២០១១ អត្ថបទច្បាប់មាននៅក្នុងឧបសម្ព័ន្ធ១ ក្នុងរបាយការណ៍នេះ |
| របាយការណ៍អាស៊ីដ | នាំគ្នាបញ្ឈប់អំពើហិង្សាដោយអាស៊ីដនៅកម្ពុជា ចងក្រងដោយ អ.ជ.ជ.អ.ក និង ម.ស.ម.ក ខែឧសភា ឆ្នាំ២០១០ |
| ម.ជ.អ | មូលនិធិជនរងគ្រោះដោយអាស៊ីដ |
| មូលនិធិ អាវ៉ែន | មជ្ឈមណ្ឌលអាវ៉ែនពិភពលោក ដើម្បីស្ត្រី និងយុត្តិធម៌នៅសាលាច្បាប់ខរណែល |
| កម្ពុជា | ព្រះរាជាណាចក្រកម្ពុជា |
| អ.ជ.ជ.ក.អ | អង្គការជួយជនរងគ្រោះកម្ពុជាដោយសារអាស៊ីដ |
| ម.ស.ម.ក | មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា |
| ក្រមនីតិវិធីព្រហ្មទណ្ឌ | ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ |
| រដ្ឋធម្មនុញ្ញ | រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា |
| ច្បាប់អំពើហិង្សាក្នុងគ្រួសារ | ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ឆ្នាំ២០០៥ |
| ក.អ.ស.ព.ន | កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិង សិទ្ធិនយោបាយ ឆ្នាំ១៩៦៦ |
| លីកាដូ | អង្គការសម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ |
| ក.ម.ផ | ក្រសួងមហាផ្ទៃ |
| ក.ឧ.រ.ថ | ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល |
| ម.ក.ជ.គ.អ.ប | មូលនិធិរបស់ក្រុមប្រឹក្សាជាតិគ្រប់គ្រងអាស៊ីដប្រទេសបង់ក្លាដេស |
| ក្រមព្រហ្មទណ្ឌ | ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១០ |
| របាយការណ៍ | របាយការណ៍ស្តីពីសេចក្តីព្រាងច្បាប់អាស៊ីដ |
| រដ្ឋាភិបាល | រាជរដ្ឋាភិបាលកម្ពុជា |

# ១. សេចក្ដីផ្ដើម

នៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០១១ បុរសពីរនាក់បានជិះម៉ូតូមកជិត និងបានវាយប្រហារដោយជះទឹកអាស៊ីដចាក់អាគុយប្រហែលកន្លះលីត្រលើស្ត្រីពីរនាក់ នៅរាជធានីភ្នំពេញ។[1] ជនរងគ្រោះម្នាក់រងរបួសរលាកលើផ្ទៃមុខ ភ្នែក និងដងខ្លួន ចំណែកជនរងគ្រោះម្នាក់ទៀតរងរបួសរលាកមិនសូវជាធ្ងន់ធ្ងរត្រង់ជើង និងដៃ។ ស្ត្រីទាំងពីររូបនេះ ត្រូវទទួលគ្រោះថ្នាក់ដោយសារតែមានការឈ្លោះប្រកែកនឹងមិត្តរួមការងារម្នាក់ ដែលមានការអះអាងថាជាអ្នកបញ្ជាឲ្យមានការវាយប្រហារនេះ។ បួនថ្ងៃក្រោយមក ជនល្មើសទាំងពីររូប និងអ្នកផ្ដើមគំនិត ត្រូវបានចោទប្រកាន់ពីបទប្រព្រឹត្តអំពើហិង្សាដោយចេតនា ជាមួយនឹងស្ថានទម្ងន់ទោសក្នុងមាត្រា២១៧ និង២១៨ នៃក្រមព្រហ្មទណ្ឌ។[2] កាលពីថ្ងៃទី២២ ខែមិថុនា តុលាការរាជធានីភ្នំពេញ បានកាត់ទោសឈ្មោះ ហារ ឡា ឲ្យជាប់ពន្ធនាគារចំនួន ៣ឆ្នាំ ពីបទផ្ដើមគំនិត។ ចំណែកស្វាមីរបស់ ហារ ឡា ឈ្មោះ ណោ ផានិត ហើយប្អូនថ្លៃប្រុស ឈ្មោះ ណោ ផាណែត ត្រូវកាត់ទោសឲ្យជាប់ពន្ធនាគារ ចំនួន ៨ឆ្នាំ និង ៣ឆ្នាំ ដោយឡែកពីគ្នា។[3] តែជនរងគ្រោះវិញទទួលភាពឈឺចាប់ផ្នែករាងកាយ និងភាពភ័យខ្លាចដក់ក្នុងចិត្ត ប្រៀបដូចជាទទួលរងទារុណកម្មពេញមួយជីវិតដូច្នោះដែរ។

ករណីខាងលើគឺជាករណីវាយប្រហារដោយអាស៊ីដលើកទីមួយក្នុងឆ្នាំ២០១១ ដែលជាការបង្ហាញឲ្យឃើញនូវអំពើហិង្សាដោយអាស៊ីដដ៏ព្រៃផ្សៃដែលបន្តកើតមាននៅក្នុងប្រទេសកម្ពុជា ។ ក្នុងរយៈពេល ៦ខែដំបូងនៃឆ្នាំ២០១១ អង្គការជួយជនរងគ្រោះដោយសារអាស៊ីដនៅកម្ពុជា (អ.ជ.ជ.ក.អ) កត់ត្រាថាមានករណីវាយប្រហារចំនួន ៦ករណី និងគ្រោះថ្នាក់ដោយចៃដន្យចំនួន ៣ករណី ដែលមានចំនួនជនរងគ្រោះចំនួន ១៥នាក់។ អ.ជ.ជ.ក.អ ជាមូលនិធិជួយជនរងគ្រោះដោយសារអាស៊ីដឈានមុខនៅកម្ពុជា ក្នុងឆ្នាំ២០០៩ បានកត់ត្រាករណីវាយប្រហារចំនួន ២៨ករណី ដែលបណ្ដាលឲ្យមានជនរងគ្រោះចំនួន ៣៣នាក់។[4] កាលពីឆ្នាំមុន ចំនួនការវាយប្រហារដោយអាស៊ីដធ្លាក់ចុះ គឺមានការកត់ត្រាករណីវាយប្រហារត្រឹមតែ ១៩ករណីប៉ុណ្ណោះ ប៉ុន្តែចំនួនជនរងគ្រោះបែរជាកើនឡើង ដែលមានរហូតដល់ទៅ ៤០នាក់។[5] មួយភាគបីនៃចំនួនជនរងគ្រោះទាំងអស់ គឺជាជនរងគ្រោះដោយអចេតនា ដែលនៅជិតជនរងគ្រោះគោលដៅក្នុងពេលនៃការវាយប្រហារ។[6] ទោះបីជាតួលេខដែលត្រូវបានកត់ត្រាមានការប្រែប្រួលពីមួយឆ្នាំទៅមួយឆ្នាំពិតមែន តែកុំភ្លេចថានៅមាន "តួលេខងងឹត"[7] ដែលជាចំនួនករណីវាយប្រហារមិនបានរាយការណ៍ នៅមិនទាន់ដឹងច្បាស់ទេថាមានចំនួនប៉ុន្មានករណី។ អ.ជ.ជ.ក.អ បានធ្វើការប៉ាន់ស្មានថា "ចំនួនងងឹត" ថាយ៉ាងហោចណាស់ អាចមានចំនួនច្រើនប្រហាក់ប្រហែលនឹងចំនួនដែលបានរាយការណ៍ដែរ។[8] ដោយហេតុថា ជនរងគ្រោះមួយចំនួនមានជីវភាពក្រីក្រ រស់នៅតំបន់ដាច់ស្រយាល និងមិនបានដឹងពីដំណើរការដាក់ពាក្យបណ្ដឹង និងមិនអាចសុំការជួយសង្គ្រោះពីអង្គការមិនមែនរដ្ឋាភិបាល (អង្គការ) ថែមទាំងមានការភ័យខ្លាចការគម្រាមកំហែងពីជនល្មើស អាចជាកត្តាដែលធ្វើឲ្យជនរងគ្រោះមិនហ៊ានរាយការណ៍។

---

[1] ឆេង សុខហុង និង ហ្សមប៉ៃ ភីតទ័រ "ជនសង្ស័យ៣នាក់ ត្រូវបានចាប់ខ្លួនក្នុងករណីវាយប្រហារដោយអាស៊ីដលើកទីមួយ ក្នុងឆ្នាំ២០១១" ឌឹ ខែមបូឌា ដេលី ថ្ងៃទី២០ ខែមករា ឆ្នាំ២០១១, ឃី សុវុឌ្ឍី និងហ្សមប៉ៃ ភីតទ័រ "ជនសង្ស័យក្នុងករណីវាយប្រហារដោយអាស៊ីដត្រូវបានសួរចម្លើយកាលពីម្សិលមិញ" ឌឹ ខែមបូឌា ដេលី ថ្ងៃទី២១ ខែមករា ឆ្នាំ២០១១, មុំ គន្ធា "តុលាការចោទប្រកាន់បុគ្គល៣នាក់ ក្នុងករណីវាយប្រហារនៅរាជធានី" ភ្នំពេញប៉ុស្ដិ៍ ថ្ងៃទី២១ ខែមករា ឆ្នាំ២០១១, មុំ គន្ធា "ជនសង្ស័យ៣នាក់ ត្រូវបានចោទប្រកាន់ក្នុងករណីវាយប្រហារដោយអាស៊ីដ" ភ្នំពេញប៉ុស្ដិ៍ ថ្ងៃទី២៤ ខែមករា ឆ្នាំ២០១១។

[2] ដូចខាងលើ។

[3] ឃី សុវុឌ្ឍី "បុគ្គល៣នាក់ ត្រូវបានកាត់ទោសក្នុងករណីវាយប្រហារនៅភ្នំពេញ" ឌឹ ខែមបូឌា ដេលី ថ្ងៃទី១០-១២ ខែមិថុនា ឆ្នាំ២០១១, ឃី សុវុឌ្ឍី "តុលាការក្រុងភ្នំពេញ ផ្ដន្ទាទោសបុគ្គល ៣នាក់ ក្នុងករណីវាយប្រហារដោយអាស៊ីដ" ឌឹ ខែមបូឌា ដេលី ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១១។

[4] អង្គការជួយជនរងគ្រោះដោយសារអាស៊ីដនៅកម្ពុជា (អ.ជ.ជ.ក.អ) របាយការណ៍ប្រចាំឆ្នាំ២០០៩ អាចអានបាន ៖ http://www.cambodianacidsurvivorscharity.org/annual%20report2009.pdf ។

[5] អ.ជ.ជ.ក.អ របាយការណ៍ប្រចាំឆ្នាំ២០១០ អាចអានបាន ៖ http://www.cambodianacidsurvivorscharity.org/annual%20report2010.pdf ទំព័រ ទី៤ ។

[6] អ.ជ.ជ.ក.អ និង មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ម.ស.ម.ក) "*នាំគ្នាបញ្ឈប់អំពើហិង្សាដោយអាស៊ីដ នៅកម្ពុជា*" (អ.ជ.ជ.ក.អ និង ម.ស.ម.ក ភ្នំពេញ កម្ពុជា ខែឧសភា ឆ្នាំ២០១០) ទំព័រទី៣ ។

[7] ចាន់ វ៉ាន់ ឌីក, អ៊ីរិន សាជែល ក្រែនដ៍ និង លីអូ ធូនលីត "ឧក្រិដ្ឋវិទ្យាក្នុងពេលបច្ចុប្បន្ន" (រោងពុម្ព អែស ឌី យូ ទីក្រុងឡាអេ ឆ្នាំ២០០៦) ។

[8] លទ្ធផលនៃបទសម្ភាសន៍ជាមួយសមាជិកនៃ អ.ជ.ជ.ក.អ ក្នុងខែវិច្ឆិកា ឆ្នាំ២០១០។ សូមអានរបាយការណ៍ប្រចាំឆ្នាំបន្ថែម កំណត់សម្គាល់លេខ៥ ទំព័រ៥ ។

រាជរដ្ឋាភិបាលកម្ពុជា (រដ្ឋាភិបាល) បានចាប់ផ្តើមចាត់វិធានការវិជ្ជមានដើម្បីបំបាត់នូវសកម្មភាពដ៏គួរឲ្យភ័យខ្លាចទាំងនេះ និងបានទទួលស្គាល់ថាសកម្មភាពផ្នែកនីតិបញ្ញត្តិ ចាំបាច់សម្រាប់ការបញ្ឈប់បទល្មើសដ៏សាហាវព្រៃផ្សៃទាំងនេះ។ ចាប់តាំងពីឆ្នាំ២០១០ គណកម្មាធិការពិសេសមួយបានធ្វើការលើច្បាប់ថ្មីមួយ ដែលបានអនុម័តដោយគណរដ្ឋមន្ត្រី[9] និងយកមកជជែកពិភាក្សាក្នុងរដ្ឋសភានៅថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១១ និងអនុម័តនៅថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០១១ និងចូលជាធរមានក្នុងខែធ្នូ ឆ្នាំ២០១១។[10] ច្បាប់នេះមានបទប្បញ្ញត្តិវិជ្ជមានមួយចំនួនដែលមានការចាំបាច់ក្នុងការកាត់បន្ថយអំពើហិង្សាដោយអាស៊ីដ ដែលពាក់ព័ន្ធនឹងការចាត់ទុកអំពើហិង្សាដោយអាស៊ីដជាបទល្មើសទោសប្បញ្ញត្តិដ៏ស័ក្តិសមសម្រាប់ជនល្មើស ការគ្រប់គ្រងលើការលក់ ការទិញ ការចែកចាយ និងដឹកជញ្ជូនអាស៊ីដ និងការគាំពារជនរងគ្រោះ ។ ប៉ុន្តែ បញ្ញត្តិមួយចំនួនមានភាពមិនច្បាស់លាស់ មិនពេញលក្ខណៈ ឬក៏តម្រូវឲ្យមានការអនុម័តនូវអនុក្រឹត្យបន្ថែមទៀត សេចក្តីណែនាំក្នុងការអនុវត្ត ដើម្បីធានាឲ្យច្បាប់នេះអាចមានប្រសិទ្ធភាពក្នុងការបំបាត់អំពើហិង្សាដោយអាស៊ីដ ។

គោលបំណងនៃរបាយការណ៍នេះ គឺធ្វើការវិភាគយ៉ាងទូលំទូលាយមកលើច្បាប់គ្រប់គ្រងអាស៊ីដខ្លាំង ដែលអនុម័តដោយរដ្ឋសភា ដើម្បីវាយតម្លៃពីភាពខ្លាំង និងភាពខ្សោយរបស់ច្បាប់នេះ។ ដើម្បីអាចធ្វើបែបនេះបាន របាយការណ៍នេះបានវិភាគច្បាប់អាស៊ីដ ជុំវិញពិភពលោក ពិចារណាពីចំណុច "វិជ្ជមាន" ក្នុងច្បាប់អាស៊ីដផ្សេងៗដែលអាចដោះស្រាយបញ្ហា និងចំណុចវិវាទជុំវិញអំពើហិង្សាដោយអាស៊ីដយ៉ាងមានប្រសិទ្ធភាព និងចំណុច "អវិជ្ជមាន" ក្នុងច្បាប់អាស៊ីដផ្សេងៗដែលបរាជ័យក្នុងការដោះស្រាយបទល្មើសទាំងនោះ ។ ពាក់ព័ន្ធនឹងចំណុចនេះ យើងបានរកឃើញមូលបទដែលកើតមានជាញឹកញាប់ ចំនួនបួន ក្នុងច្បាប់អាស៊ីដក្នុងប្រទេសផ្សេងៗ។ ចំណុចទាំងនោះមាន (១) ការចាត់ទុកអំពើហិង្សាដោយអាស៊ីដជាបទល្មើស (២) ការគ្រប់គ្រងការលក់ ចែកចាយ កាន់កាប់ និងដឹកជញ្ជូនអាស៊ីដ (៣) ការកាត់ទោស និងផ្តន្ទាទោស និង (៤) ការគាំពារជនរងគ្រោះ។ របាយការណ៍នេះ បានប្រើចំណុចគោលទាំងនេះដើម្បីវិភាគ និងវាយច្បាប់គ្រប់គ្រងអាស៊ីដខ្លាំងសម្រាប់កម្ពុជាបច្ចុប្បន្ន និងផ្តល់ជាអនុសាសន៍ជូនរដ្ឋាភិបាល នូវចំណុចមួយចំនួនដែលគួរតែមាននៅក្នុងច្បាប់ ខ្លឹមសារនៅក្នុងអនុក្រឹត្យ និងការណែនាំដែលគួរតែត្រូវបានអនុវត្ត ដើម្បីបន្ថែមទៅក្នុងច្បាប់ និងជ្រោមជ្រែងចំពោះការអនុវត្តច្បាប់បន្ទាប់ពីច្បាប់នេះចូលជាធរមាន។

ក្នុងសេចក្តីផ្តើមនេះ ម.ស.ម.ក បង្ហាញពីសារតាររបស់បញ្ហាពាក់ព័ន្ធនឹងអំពើហិង្សាដោយអាស៊ីដនៅកម្ពុជា។ សេចក្តីផ្តើមនេះ ក៏បានបង្ហាញរូបភាពរួមនៃក្របខណ្ឌច្បាប់បច្ចុប្បន្នដែលមានចំពោះអំពើហិង្សាដោយអាស៊ីដផងដែរ។ ក្នុងផ្នែកទី២ ម.ស.ម.ក ធ្វើការវិភាគច្បាប់អាស៊ីដក្នុងស្រុក និងក្នុងដែនសមត្ថកិច្ចដទៃទៀត ដោយផ្អែកលើមូលបទទាំងបួនខាងលើ។ ក្នុងផ្នែកទី៣ យើងនឹងពិនិត្យមើលលើច្បាប់គ្រប់គ្រងអាស៊ីដខ្លាំងសម្រាប់កម្ពុជា ធៀបទៅនឹងមូលបទទាំងបួនខាងលើ កត់សម្គាល់ពីចំណុចខ្លាំង និងផ្តល់អនុសាសន៍ដើម្បីពង្រឹងបញ្ញត្តិផ្សេងៗ និងការអនុវត្តនៃច្បាប់នេះ។

## ១.១ អំពើហិង្សាដោយអាស៊ីដនៅកម្ពុជា

ក្នុងរបាយការណ៍ *នាំគ្នាបញ្ឈប់អំពើហិង្សាដោយអាស៊ីដនៅកម្ពុជា*[11] ដែលរួមគ្នាតាក់តែងដោយ អ.ជ.ជ.ក.អ និង ម.ស.ម.ក (របាយការណ៍អាស៊ីដ) បានបញ្ជាក់ថាស្របពេលដែលអំពើហិង្សាដោយអាស៊ីដជាបាតុភូតក្នុងប្រទេសកំពុងអភិវឌ្ឍមួយចំនួន កត្តាក្នុងស្រុកនីមួយៗរួមចំណែកយ៉ាងសំខាន់ក្នុងការវាយប្រហារ។ ជាទូទៅ នៅកម្ពុជា ការវាយប្រហារដោយអាស៊ីដ គឺជាលទ្ធផល ឬត្រូវបានមើលឃើញថាជាមធ្យោបាយនៃការដោះស្រាយជម្លោះ ដែលការវាយប្រហារភាគច្រើនកើតឡើងព្រោះតែបញ្ហាគ្រួសារ ឬបញ្ហាផ្ទាល់ខ្លួន។[12] ឧទាហរណ៍ "*មូលហេតុមួយក្នុងចំណោមមូលហេតុជាច្រើននៃការវាយប្រហារដោយអាស៊ីដ គឺជាការសងសឹកចំពោះភាពមិនស្មោះត្រង់ក្នុងទំនាក់ទំនងស្នេហា*

[9] ម៉ារី កូស្លូវស្គី និង មុំ គន្ធា "គណៈរដ្ឋមន្ត្រីអនុម័តសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងអាស៊ីដ" ភ្នំពេញប៉ុស្ដិ៍ ថ្ងៃទី ២៩ ខែសីហា ឆ្នាំ២០១១។

[10] មុំ គន្ធា "ច្បាប់គ្រប់គ្រងអាស៊ីដសង្ឃឹមថានឹងត្រូវបានអនុម័ត" ភ្នំពេញប៉ុស្ដិ៍ ថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០១១

[11] អ.ជ.ជ.ក.អ និង ម.ស.ម.ក កំណត់សម្គាល់លេខ៦ ។

[12] ដូចខាងលើ ទំព័រទី៤ ។

*ដូចជាប្រពន្ធដែលប្តីផិតក្បត់ វាយប្រហារស្រីកំណាន់របស់ប្តីខ្លួន ឬករណីមួយទៀត ស្រីកំណាន់ជាអ្នកវាយប្រហារលើប្រពន្ធដើមវិញ"* ។[13] របាយការណ៍អាស៊ីដក៏បានបញ្ជាក់ផងដែរថា ជម្លោះផ្នែកអាជីវកម្ម និងដីធ្លីក៏ជាមូលហេតុចម្បងមួយក្នុងការវាយប្រហារដោយអាស៊ីដផងដែរ ដូចជាករណីដែលបានលើកឡើងក្នុងផ្នែកដំបូងនៃរបាយការណ៍នេះជាដើម។ នៅកម្ពុជា ករណីវាយប្រហារលើបុរសមានចំនួនប្រហាក់ប្រហែលនឹងស្ត្រីដែរ។ ចំណែកអ្នកប្រព្រឹត្តបទល្មើសមានទាំងបុរស និងស្ត្រី ទោះជា "*តាមរបាយការណ៍បញ្ជាក់ថាជាទូទៅ ជនល្មើសគឺជាស្ត្រីច្រើនជាងបុរស*" ក៏ដោយ។[14]

មានមូលហេតុជាច្រើន ដែលអាស៊ីដត្រូវបានគេប្រើជាមធ្យោបាយប្រព្រឹត្តអំពើហិង្សានៅកម្ពុជា។ យើងកត់សម្គាល់ឃើញថា ភាពងាយស្រួលក្នុងការយកអាស៊ីដមកប្រើ តម្លៃទាប ភាពងាយស្រួលក្នុងការដឹកជញ្ជូន និងប្រើដោយគ្មានអ្នកចាប់អារម្មណ៍ ហើយជាពិសេសការមានអាស៊ីដគឺជាអំពើស្របច្បាប់ ចំណុចទាំងនេះហើយ ដែលជាកត្តាសំខាន់ធ្វើឲ្យមនុស្សចូលចិត្តប្រើអាស៊ីដ។ អាស៊ីដមានភាពងាយស្រួលក្នុងការទិញជាងអាវុធដទៃទៀត ដូចជាកាំភ្លើង ប៉ុន្តែអាចបណ្តាលឲ្យមានភាពខាតបង់យ៉ាងធ្ងន់ធ្ងរប្រហាក់ប្រហែលគ្នា។

នៅកម្ពុជា វប្បធម៌និទណ្ឌភាពជុំវិញអំពើហិង្សាដោយអាស៊ីដក្នុងករណីជាច្រើន ជាលទ្ធផលដែលធ្វើឲ្យជនល្មើសមិនត្រូវបាននាំយកមកការកាត់ទោស។ និទណ្ឌភាពគឺជា "ចលនាជំរុញទៅមក"[15] ហើយការប្រព្រឹត្តបែបនេះជំរុញឲ្យអ្នកដទៃហ៊ានប្រព្រឹត្តសកម្មភាពដូចគ្នា។ ដោយសារតែជនល្មើសនៅតែអាចគេចផុតពីការផ្តន្ទាទោសជាបន្តបន្ទាប់ ចំណុចនេះអាចធ្វើឲ្យមានការទទួលស្គាល់ក្នុងសង្គមថាជាមធ្យោបាយ ដែលអាចទទួលយកបានក្នុងការដោះស្រាយជម្លោះ។ ដូច្នេះ ការរៀបចំបង្កើតច្បាប់ និងយន្តការដ៏ត្រឹមត្រូវ មានសារៈសំខាន់ណាស់ ដើម្បីធានាថាជនល្មើសត្រូវតែទទួលការផ្តន្ទាទោស ហើយចំណុចទាំងនេះនឹងដើរតួជាការរាំងដ៏មានប្រសិទ្ធភាពដើម្បីបញ្ឈប់ជនល្មើសមិនឲ្យប្រព្រឹត្តសកម្មភាពបែបនេះតទៅទៀត។

## ១.២ ក្របខណ្ឌច្បាប់បច្ចុប្បន្ន

បច្ចុប្បន្ននៅកម្ពុជា ក្របខណ្ឌច្បាប់នៅមិនទាន់អាចដោះស្រាយអំពើហិង្សាដោយអាស៊ីដឲ្យបានគ្រប់គ្រាន់នៅឡើយទេ។ ស្ទើរតែគ្មានច្បាប់គ្រប់គ្រង ឬដាក់កំហិតមកលើលទ្ធភាពប្រើប្រាស់អាស៊ីដ។ ដូច្នេះបើទោះបីជាក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល (ក.ឧ.រ.ថ) ផ្តល់អាជ្ញាប័ណ្ណដើម្បីនាំអាស៊ីដចូល និងកំណត់បញ្ញត្តិឲ្យអនុវត្ត និងកំហិតលើការនាំចូលក៏ពិតមែន តែនៅមានឧបសគ្គមួយចំនួនសម្រាប់ការលក់អាស៊ីដបន្ទាប់ពីត្រូវបាននាំចូលរួចហើយ។ ជាពិសេស ច្បាប់នេះក៏មិនបានចែងស្តីពីលទ្ធភាពនៃការទិញ លក់ ដឹកជញ្ជូន ឬរក្សាទុកអាស៊ីដនោះទេ។

ច្បាប់ព្រហ្មទណ្ឌបច្ចុប្បន្ន ក៏នៅមានកង្វះខាតក្នុងការដោះស្រាយអំពើហិង្សាដោយអាស៊ីដដែរ។ ក្រមព្រហ្មទណ្ឌ ខកខានមិនបានផ្តល់សុពលភាពជាក់លាក់ចំពោះការចាត់ទុកអំពើហិង្សាដោយអាស៊ីដជាបទល្មើសព្រហ្មទណ្ឌ ហើយដែលនឹងត្រូវផ្តន្ទាទោសតាមច្បាប់[16] ហើយថែមទាំងគ្មានការអះអាងពីការចាត់ទុកការលក់ ចែកចាយ ឬកាន់កាប់អាស៊ីដដោយគ្មានអាជ្ញាប័ណ្ណ ឬលិខិតអនុញ្ញាតជាបទល្មើសដែរ។ ទោះបីជាក្រមព្រហ្មទណ្ឌមិនបានចែងយ៉ាងជាក់លាក់ស្តីពីការវាយប្រហារដោយអាស៊ីដ ប៉ុន្តែក្រមនេះបានចែងពីការផ្តន្ទាទោសយ៉ាងធ្ងន់ធ្ងរចំពោះបទល្មើសនៃ *"អំពើទារុណកម្ម និងអំពើឃោរឃៅ"* និងការប្រើអំពើហិង្សាដោយចេតនា ក្នុងករណីដែលអំពើនោះបណ្តាលឲ្យជនរងគ្រោះបាត់បង់អវយវៈ ឬពិការភាពជាអចិន្ត្រៃយ៍ ដែលទំនងជាអាចអនុវត្តជាមួយករណីអំពើហិង្សាទឹកអាស៊ីដបាន។[17] ក៏ប៉ុន្តែ ទណ្ឌកម្មចំពោះអំពើបែបនេះគឺត្រូវជាប់ពន្ធនាគារត្រឹមតែពី ៥ ទៅ ១០ឆ្នាំ ប៉ុណ្ណោះ ។

---

[13] ដូចខាងលើ ។
[14] ដូចខាងលើ ទំព័រទី៣ ។
[15] ដូចខាងលើ ទំព័រទី១៦ ។
[16] មាត្រា២៧-២៨ និងមាត្រា៤៧-៤៨ មាត្រា១៩៩-២០១ នៃក្រមព្រហ្មទណ្ឌបានលើកឡើងស្តីពីអំពើហិង្សា និងការប្រើប្រាស់អាវុធប៉ុន្តែមិនបានបញ្ជាក់ពីអំពើហិង្សាដោយអាស៊ីដនោះទេ។
[17] មាត្រា២២៣ នៃក្រមព្រហ្មទណ្ឌ។

របាយការណ៍អាស៊ីដ បង្ហាញថានៅកម្ពុជា អំពើហិង្សាដោយអាស៊ីដគឺមិនទាន់មានការទទួលស្គាល់ជាទូទៅថាជាបទល្មើសព្រហ្មទណ្ឌដែលទាមទារឲ្យរដ្ឋមានកាតព្វកិច្ចធ្វើអន្តរាគមន៍នោះទេ គឺដូចគ្នានឹងករណីអំពើហិង្សាក្នុងគ្រួសារកាលពីមុន។[18] ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ឆ្នាំ២០០៥ (ច្បាប់អំពើហិង្សាក្នុងគ្រួសារ) បានបោះជំហានដ៏សំខាន់មួយ ដោយបានចាត់ទុកអំពើហិង្សាក្នុងគ្រួសារជាបទល្មើស និងបំភ្លឺរាល់ភាពមិនច្បាស់លាស់ពាក់ព័ន្ធនឹងចរិតលក្ខណៈនៃបទល្មើសរបស់អំពើហិង្សាប្រភេទនេះ និងការជជែកវែកញែកដែលកើតឡើងជាបន្តបន្ទាប់ ហើយដែលអំពើហិង្សាក្នុងគ្រួសារត្រូវបានមើលឃើញថាមិនមែនជារឿងគ្រួសារតទៅទៀតទេ ប៉ុន្តែគឺជាបទល្មើសព្រហ្មទណ្ឌដែលទាមទារឲ្យមានការអន្តរាគមន៍ដើម្បីធានាឲ្យមានការការពារដល់ជនរងគ្រោះ និងសាធារណជនទូទៅ។ ប៉ុន្តែ ច្បាប់អំពើហិង្សាក្នុងគ្រួសារ ក៏នៅមានការខ្វះខាតក្នុងការដោះស្រាយអំពើហិង្សាដោយអាស៊ីដផងដែរ ព្រោះច្បាប់នេះអនុវត្តបានចំពោះសមាជិកគ្រួសារម្នាក់ដែលជះទឹកអាស៊ីដលើសមាជិកគ្រួសារម្នាក់ទៀតប៉ុណ្ណោះ ដូច្នេះ មិនអាចអនុវត្តចំពោះបុគ្គលដែលជះទឹកអាស៊ីដលើបុគ្គលដទៃនោះទេ។[19]

[18] អ.ជ.ជ.ក.អ និង ម.ស.ម.ក កំណត់សម្គាល់លេខ៦ ទំព័រទី១៧ ។

[19] សូមអានច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ឆ្នាំ២០០៥ (អនុម័តថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៥ ចូលជាធរមានថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៥) ។

# ២. បញ្ញត្តិសំខាន់ៗក្នុងច្បាប់ស្តីពីការគ្រប់គ្រងអាស៊ីដខ្លាំង

ក្នុងការស្រាវជ្រាវដ៏លម្អិតរបស់យើង យើងបានធ្វើការពិចារណាលើច្បាប់ និងសេចក្តីព្រាងច្បាប់របស់ប្រទេសដទៃដែលបានរងគ្រោះពីអំពើហិង្សាដោយអាស៊ីដផងដែរ។ ការយកចិត្តទុកដាក់ជាពិសេស បានផ្តោតលើប្រទេសបង់ក្លាដែស ដែលបានបង្កើតច្បាប់ដ៏ជាក់លាក់មួយដើម្បីដោះស្រាយជាមួយអំពើហិង្សាដោយអាស៊ីដកាលពីឆ្នាំ២០០២។[20] ការត្រួតពិនិត្យច្បាប់ ព្រមទាំងភាពខ្លាំង និងភាពខ្សោយនៃច្បាប់របស់ប្រទេសទាំងនេះ មានសារៈ-សំខាន់ណាស់ ដើម្បីឲ្យមានការយល់ដឹងពីប្រភេទបញ្ញត្តិដែលចាំបាច់ដើម្បីឲ្យច្បាប់គ្រប់គ្រងអាស៊ីដនៅកម្ពុជាកាន់តែមានប្រសិទ្ធភាពខ្លាំងឡើង។ យោងតាមអនុសាសន៍ក្នុងរបាយការណ៍អាស៊ីដ[21] និងដូចបានឆ្លុះបញ្ចាំងក្នុងរបាយការណ៍របស់មូលនិធិអាវ៉ន ស្តីពីការទប់ស្កាត់អំពើហិង្សាទឹកអាស៊ីដនៅបង់ក្លាដែស កម្ពុជា និងប៉ាគីស្ថាន នាពេលថ្មីៗនេះ[22] ច្បាប់ទាំងអស់គួរតែបញ្ចូលនូវវិធីសាស្ត្របែបពហុវិធានការវិន័យសម្រាប់អំពើហិង្សាដោយអាស៊ីដ។ ផ្នែកនេះមានលើកឡើងពីការចងក្រងនៃការស្រាវជ្រាវរបស់យើង ដែលយើងនឹងបង្ហាញពីកត្តាដែលយើងពិចារណាថាអាចបង្កើតច្បាប់អាស៊ីដ "មានប្រសិទ្ធភាព" និងកត្តាដែលបង្កើតច្បាប់អាស៊ីដ "គ្មានប្រសិទ្ធភាព"។ ដូចដែលបានកត់សម្គាល់ក្នុងសេចក្តីផ្តើម ការវិភាគរបស់យើង ផ្អែកលើចំណុចបួនគឺ (១) ការចាត់ទុកអំពើហិង្សាដោយអាស៊ីដជាបទល្មើស (២) ការគ្រប់គ្រងការដឹកជញ្ជូន ការលក់ និងការកាន់កាប់អាស៊ីដ (៣) ការផ្តន្ទាទោសជនល្មើស និង(៤) ការគាំពារជនរងគ្រោះ។ ចំណុចទាំងនេះ នឹងត្រូវបានលើកយកមកពិនិត្យមើលជាបន្តបន្ទាប់។

## ២.១ ការចាត់ទុកអំពើហិង្សាដោយអាស៊ីដជាបទល្មើស

គ្រប់ច្បាប់អាស៊ីដ ត្រូវតែទទួលស្គាល់ថាអាស៊ីដ ឬសារធាតុដែលអាចកាត់បំផ្លាញសាច់ នៅពេលដែលប្រើជះ ស្រោច ឬមធ្យោបាយដទៃ ដែលមានបំណងបង្កឲ្យមានការឈឺចាប់ដល់រូបរាងកាយ ធ្វើឲ្យខូចរូបសម្ផស្ស ឬបណ្តាលឲ្យបុគ្គលដទៃបាត់បង់ជីវិត ត្រូវចាត់ទុកជាអាវុធ និងត្រូវបានប្រើជាអាវុធ។ ច្បាប់គួរតែពិចារណានូវការខូចខាតដ៏ធ្ងន់ធ្ងរដែលអាវុធទាំងនេះបណ្តាលឲ្យមាន ឯការប្រើប្រាស់អាស៊ីដ ឬសារធាតុទាំងនោះជាអាវុធ គួរតែត្រូវបានពិនិត្យមើលឲ្យបានម៉ត់ចត់ក្នុងច្បាប់។

ក្នុងផ្នែកនៃការចាត់ទុកអំពើហិង្សាដោយអាស៊ីដជាបទល្មើស និយមន័យដ៏ទូលាយរបស់ "អាស៊ីដ" ដែលរួមមានសារធាតុកាត់បំផ្លាញសាច់ និងសារធាតុគីមីទាំងអស់ដែលអាចប្រើធ្វើជាមធ្យោបាយប្រព្រឹត្តអំពើហិង្សាដូចបានរៀបរាប់ខាងលើ ត្រូវតែបញ្ចូលក្នុងច្បាប់នេះ។ ឧទាហរណ៍ មាត្រា២(ខ) នៃច្បាប់ស្តីពីការគ្រប់គ្រងអាស៊ីដរបស់បង់ក្លាដែស បានកំណត់និយមន័យអាស៊ីដថា *"ធាតុផ្សំគ្រប់ប្រភេទ ទាំងខាប់ រាវ ឬជាល្បាយ របស់អាស៊ីដស៊ុលហ្វួរិក អាស៊ីដក្លរីឌ្រិក អាស៊ីដនីទ្រិក អាស៊ីដផូស្វ័រិក អាស៊ីដកាបូលីក អាស៊ីដរាវប្រើសម្រាប់ចាក់អាគុយ អាស៊ីដក្រូមិក និងអាស៊ីដលាយ និងសារធាតុដែលកាត់បំផ្លាញសាច់ដទៃទៀតដែលរដ្ឋាភិបាលចាត់ទុកថាជាអាស៊ីដ"* ។[23] ចំណុចខ្លាំងរបស់និយមន័យនេះគឺមានវិសាលភាពទូលំទូលាយ ថែមទាំងបានទុកចន្លោះសម្រាប់សារធាតុដទៃទៀតអាចនឹងត្រូវបានបញ្ចូលទៅក្នុងបញ្ជីនាពេលអនាគត ប្រសិនបើមានការរកឃើញបន្ថែមទៀត។

ចរិតលក្ខណៈនៃការវាយប្រហារដោយអាស៊ីដគឺថា ក្នុងករណីជាច្រើនដែលអ្នកប្រព្រឹត្តបទល្មើស គឺមិនចាំបាច់ជាអ្នកផ្តើមគំនិតនោះទេ ដូចឧទាហរណ៍ក្នុងផ្នែកខាងដើមនៃរបាយការណ៍នេះជាភស្តុតាងស្រាប់។ ដូច្នេះ គឺជា

[20] សូមអានច្បាប់ស្តីពីការគ្រប់គ្រងអាស៊ីដ និងច្បាប់ស្តីពីការគ្រប់គ្រងបទល្មើសអាស៊ីដ របស់បង់ក្លាដែស។

[21] អ.ជ.ជ.ក.អ និង ម.ស.ម.ក កំណត់សម្គាល់លេខ៦ ទំព័រទី៣៦ ។

[22] មជ្ឈមណ្ឌលអាវ៉ននៃពិភពលោកដើម្បីស្ត្រី និងយុត្តិធម៌ នៅសាលាច្បាប់ខរណែល និងគណៈមេធាវីនៃទីក្រុងញូវយ៉ក "ការទប់ស្កាត់អំពើហិង្សាដោយអាស៊ីដនៅ បង់ក្លាដែស កម្ពុជា និងឥណ្ឌា" (២០១១) អាចអានបាន ៖ http://www.lawschool.cornell.edu/womenandjustice/Launch-event-Avon-Global-Center-report-on-acid-violence-in-Bangladesh-Cambodia-and-India.cfm ។

[23] មាត្រា២(ខ) នៃច្បាប់ស្តីពីការគ្រប់គ្រងអាស៊ីដរបស់បង់ក្លាដែស ឆ្នាំ២០០២។

រឿងដ៏ចាំបាច់បំផុតដែលច្បាប់អាស៊ីដទាំងអស់ ត្រូវចាត់ទុករាល់សកម្មភាព របស់សហចារី អ្នកផ្តើមគំនិត និង/ឬអ្នកសមគំនិតជាបទល្មើសដូចគ្នាដែរ។[24]

ការចាត់ទុកអំពើហិង្សាដោយអាស៊ីដជាបទល្មើស គួរតែត្រូវបានមើលឃើញថាជាផ្នែកមួយនៃវិធីសាស្រ្តដែលមានលក្ខណៈគ្របដណ្តប់ចំពោះអំពើហិង្សាដោយអាស៊ីដ ដែលនេះគឺជាជំហានដ៏សំខាន់ក្នុងកិច្ចខំប្រឹងប្រែង ដើម្បីលុបបំបាត់បទល្មើសបែបនេះ ។ ច្បាប់ទាំងអស់ ត្រូវតែមានហេដ្ឋារចនាសម្ព័ន្ធ និងដំណើរការដ៏សមស្របដើម្បីជំរុញឲ្យមានការចាត់ទុកសកម្មភាពទាំងនោះជាបទល្មើស។ ប្រទេសបង់ក្លាដែស ជាករណីសិក្សាដ៏ល្អមួយក្នុងស្ថានភាពបែបនេះ។[25] រយៈពេល៣ឆ្នាំ បន្ទាប់ពីការប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងអាស៊ីដរបស់បង់ក្លាដែស ឆ្នាំ២០០២ មានការរាយការណ៍ថាអំពើហិង្សាដោយអាស៊ីដបន្តកើតមានច្រើនលើសពី ៣០០ករណីក្នុងមួយឆ្នាំ ទោះបីជាចំនួនការវាយប្រហារដោយអាស៊ីដបានធ្លាក់ចុះជាបន្តបន្ទាប់ពី ១៥ទៅ២០% ជារៀងរាល់ឆ្នាំក៏ដោយ។[26] មូលហេតុមួយចំនួនគឺដោយសារកង្វះខាតនៃការវិវឌ្ឍន៍បឋមដ៏សំខាន់ក្នុងករណីអំពើហិង្សាដោយអាស៊ីដ បន្ទាប់ពីមានការចាត់ទុកជាបទល្មើសហើយ។ ចំណុចដំបូងបំផុត គឺកង្វះខាតភ្នាក់ងារអនុវត្តច្បាប់មានការបណ្តុះបណ្តាល ដែលមានសមត្ថភាពរៀបចំការស៊ើបអង្កេតលើករណីវាយប្រហារដោយអាស៊ីដបានគ្រប់គ្រាន់។ មន្រ្តីនគរបាលដែលមានការងារដ៏ច្រើនសន្ធឹកស្រាប់ទៅហើយ មិនអាចអនុវត្តកាតព្វកិច្ចស៊ើបអង្កេតរបស់ពួកគេបានយ៉ាងសមស្របនោះទេ។ ចំណុចនេះធ្វើឲ្យករណីជាច្រើនមិនត្រូវបាននាំទៅតុលាការ និងនិទណ្ឌភាពមានការកើនឡើង។ ការឆ្លុះបញ្ចាំងពីប្រទេសបង់ក្លាដែសគួរឲ្យកត់សម្គាល់ណាស់ ដោយបញ្ជាក់ថាការចាត់ទុកអំពើហិង្សាដោយអាស៊ីដជាបទល្មើសតែម្យ៉ាង គឺមិនទាន់គ្រប់គ្រាន់នោះទេ។ អ្នកគាំទ្រច្បាប់ស្តីពីការគ្រប់គ្រងអាស៊ីដថ្មីនៅប៉ាគីស្ថាន បានលើកយកពីបញ្ហាប្រឈមនៃការអនុវត្តច្បាប់មកពិចារណា។[27] ដូច្នេះបន្ថែមពីលើការដាក់ឲ្យច្បាប់ពាក់ព័ន្ធនឹងអំពើហិង្សាដោយអាស៊ីដឲ្យចូលជាធរមាន រដ្ឋាភិបាលត្រូវធានាថាមានការបង្កើតនូវហេដ្ឋារចនាសម្ព័ន្ធដ៏ចាំបាច់ និងការអនុវត្តន៍ត្រឹមត្រូវ ដើម្បីឲ្យច្បាប់នេះមានប្រសិទ្ធភាពពិតប្រាកដក្នុងការបំបាត់អំពើហិង្សាដ៏ឃោរឃៅទាំងនេះ។

## ២.២ ការគ្រប់គ្រងការលក់ ចែកចាយ និងកាន់កាប់អាស៊ីដខ្លាំង

តាមការកត់សម្គាល់ក្នុងរបាយការណ៍អាស៊ីដ *"ប្រសិនបើគ្មានការបង្កើតច្បាប់ដ៏សមស្របមួយសម្រាប់អ្នកលក់ និងអ្នកទិញអាស៊ីដ និងមានការអនុវត្តន៍ច្បាប់យ៉ាងតឹងរ៉ឹង រាល់ប្រព័ន្ធច្បាប់នឹងខកខានមិនអាចផ្តល់ការការពារដ៏មានប្រសិទ្ធភាពទេ"* ។[28] ការបង្កើត និងដាក់ច្បាប់ឲ្យអនុវត្ត ស្តីពីលទ្ធភាពទទួលបានអាស៊ីដ និងសារធាតុគ្រោះថ្នាក់ដទៃ ជាជំហានដ៏សំខាន់មួយក្នុងការរារាំងអំពើហិង្សាដោយអាស៊ីដ។[29] ក.ឧ.រ.ថ ទទួលខុសត្រូវក្នុងការផ្តល់អាជ្ញាប័ណ្ណសម្រាប់ការនាំអាស៊ីដចូល និងដាក់ច្បាប់ឲ្យអនុវត្ត និងដាក់កំហិតចំពោះលើដំណើរការនេះហើយ។ ប៉ុន្តែបច្ចុប្បន្ន នៅមិនទាន់មានរបបផ្តល់អាជ្ញាប័ណ្ណនៅកម្ពុជា ដែលគ្របដណ្តប់លើការលក់អាស៊ីដ បន្ទាប់ពីបាននាំចូលមកនោះទេ។

ប្រព័ន្ធផ្តល់អាជ្ញាប័ណ្ណ និងការគ្រប់គ្រង មានទាំងនៅក្នុងច្បាប់របស់បង់ក្លាដែស និងសេចក្តីព្រាងច្បាប់របស់ប៉ាគីស្ថាន សម្រាប់ធ្វើជាមធ្យោបាយការពារមិនឲ្យបុគ្គលដែលប្រើប្រាស់សារធាតុទាំងនោះដោយមិនពាក់ព័ន្ធនឹងអាជីវកម្មរបស់ខ្លួន មានលទ្ធភាពទទួលយកសារធាតុគីមីនេះដោយងាយស្រួល ដោយសង្ឃឹមថាតាមរយៈការគ្រប់

---

[24] ច្បាប់ស្តីពីការគ្រប់គ្រងអាស៊ីដរបស់បង់ក្លាដែស ឆ្នាំ២០០២ មាត្រា៧ បានចែងថា *"ប្រសិនបើបុគ្គលណាជួយ បុគ្គលម្នាក់ទៀតដើម្បីប្រព្រឹត្តបទល្មើសដែលមានចែងក្នុងច្បាប់នេះ និងដោយសារតែការជួយនេះ បទល្មើសត្រូវបានប្រព្រឹត្ត ឬការប៉ុនប៉ងដើម្បីប្រព្រឹត្តបទល្មើសកើតមាន អ្នកសមគំនិតនឹងទទួលការផ្តន្ទាទោសដូចជាជនល្មើសដែរ"* ។

[25] លីហ្សា អែម ថៃល័រ "ការសង្គ្រោះផ្ទៃមុខ ៖ ច្បាប់ស្តីពីអំពើហិង្សាដោយអាស៊ីដ បន្ទាប់ពីមានការបង្កើត កតិកាសញ្ញាស្តីពីការលុបបំបាត់ការរើសអើងគ្រប់ទម្រង់ប្រឆាំងនឹងស្រ្តី" សារព័ត៌មានចចជៀរ ស្តីពីច្បាប់អន្តរជាតិ និងប្រៀបធៀប ភាគទី២៩ (២០០០-២០០១) ៣៩៥-៤២៦។

[26] សៃរ៉ា រ៉ាម៉ាន "ការឆ្លុះបញ្ចាំងខុសពីការពិត ៖ អំពើហិង្សាដោយអាស៊ីដ និងច្បាប់នៅបង់ក្លាដែស" គណៈកម្មការសិទ្ធិមនុស្ស ថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៥ អាចអានបាន ៖ http://www.hrsolidarity.net/mainfile.php/2005vol15no03/2429/ និង មូលនិធិអារ៉ែន សូមអាន កំណត់សម្គាល់លេខ២១ ទំព័រទី១២ ។

[27] ណាតាលី អូរិនស្ទើន "ជនរងគ្រោះដោយអាស៊ីដជំរុញឲ្យមានការបង្កើតច្បាប់នៅប៉ាគីស្ថាន" ញូវស៍ដេស ថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១០ អានអាចបាន ៖ http://newsdesk.org/2010/06/acid-attack-victim-inspires-pakistani-legislation/ ចូលអានកាលពីថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១១។

[28] អ.ជ.ជ.ក.អ និង ម.ស.ម.ក កំណត់សម្គាល់ លេខ៦ ទំព័រទី៨។

[29] លីហ្សា ថៃល័រ កំណត់សម្គាល់លេខ២៤ ។

គ្រងលើការផ្គត់ផ្គង់ នឹងធ្វើឲ្យការប្រើអាស៊ីដជាមធ្យោបាយដោះស្រាយជម្លោះធ្លាក់ចុះ។[30] យោងតាមកំណត់សម្គាល់ខាងលើ ចាប់តាំងពីមានការប្រកាសឲ្យអនុវត្តច្បាប់ដែលមានទាំងបញ្ញត្តិស្តីពីការគ្រប់គ្រងការលក់ និងចែកចាយអាស៊ីដ អត្រានៃករណីវាយប្រហារដោយអាស៊ីដនៅបង់ក្លាដែស ថយចុះប្រហែលជា ១៥ ទៅ ២០% រៀងរាល់ឆ្នាំ។[31]

របបនៃការផ្តល់អាជ្ញាប័ណ្ណទាំងអស់ គួរតែបញ្ចូលតម្រូវការសម្រាប់ ការផលិត នាំចេញ ដឹកជញ្ជូន រក្សាទុក ការលក់ និងការប្រើប្រាស់អាស៊ីដ និងផ្តន្ទាទោសចំពោះប្រតិបត្តិការដែលគ្មានអាជ្ញាប័ណ្ណ។ បន្ថែមពីលើនោះ ច្បាប់គួរតែរួមបញ្ចូលបទប្បញ្ញត្តិដែលអាចដោះស្រាយជាមួយការគ្រប់គ្រងកាកសំណល់អាស៊ីដ ដើម្បីគ្រប់គ្រងភាពខូចខាតដែលអាចកើតមានដោយសារអាស៊ីដ ឬល្បាយអាស៊ីដ របស់អង្គភាពបញ្ចេញកាកសំណល់ ឬឧស្សាហកម្ម។ អាជ្ញា-ប័ណ្ណគួរតែផ្តល់ឲ្យក្នុងរយៈពេលកំណត់មួយ ដើម្បីអនុញ្ញាតឲ្យអាជ្ញាធរដែលទទួលខុសត្រូវក្នុងការផ្តល់អាជ្ញាប័ណ្ណអាចធានាបានថា អ្នកកាន់កាប់អាជ្ញាប័ណ្ណ បានគោរពតាមលក្ខខណ្ឌរបស់អាជ្ញាប័ណ្ណ ជាពិសេសក្នុងដំណើរការបន្តអាជ្ញាប័ណ្ណ។ ច្បាប់ត្រូវតែតម្រូវឲ្យអ្នកលក់កត់ឈ្មោះ និងអាសយដ្ឋានរបស់អ្នកទិញទាំងអស់ទុក។[32] ចំណុចនេះមានសារៈសំខាន់ចំពោះទស្សនៈនៃការស៊ើបអង្កេត សម្រាប់ពេលដែលមានការវាយប្រហារដោយអាស៊ីដកើតឡើង ដើម្បីឲ្យប៉ូលីសផ្នែកស៊ើបអង្កេតអាចកំណត់បានថា ជនល្មើសទិញទឹកអាស៊ីដពីកន្លែងណា ឯការត្រួតពិនិត្យលើការកត់ត្រានេះមានសារៈសំខាន់ខ្លាំងណាស់ចំពោះការស៊ើបអង្កេត។

អាជ្ញាប័ណ្ណទាំងអស់ គួរតែអាចលុបចោល ឬព្យួរបាន ប្រសិនបើមានការរំលោភលក្ខខណ្ឌនៃអាជ្ញាប័ណ្ណ[33] ហើយស្របពេលនេះ គួរតែមានការផ្តន្ទាទោសដ៏សមស្របចំពោះការផលិត ការនាំចូល ការដឹកជញ្ជូន ការរក្សាទុក ការលក់ និងការប្រើប្រាស់អាស៊ីដដោយគ្មានអាជ្ញាប័ណ្ណ ដែលនឹងត្រូវបានពិភាក្សាយ៉ាងលម្អិតក្នុងផ្នែកខាងក្រោម។[34] បង់ក្លាដែស បានចែងពីការផ្តន្ទាទោសផ្នែកព្រហ្មទណ្ឌចំពោះបុគ្គលដែល *"ផលិត នាំចូល ដឹកជញ្ជូន រក្សាទុក លក់ ឬប្រើប្រាស់ ឬកាន់កាប់អាស៊ីដ ដោយមិនបានអនុវត្តតាមបញ្ញត្តិច្បាប់ស្តីពីការគ្រប់គ្រងអាស៊ីដ ឬមិនបានបំពេញតាមលក្ខខណ្ឌនៃអាជ្ញាប័ណ្ណ"* ។[35] មាត្រា៣៦ ក្នុងច្បាប់ស្តីពីការគ្រប់គ្រងអាស៊ីដរបស់បង់ក្លាដែស ក៏បានចែងពីការដាក់ពន្ធនាគារចាប់ពី៣ ទៅ១០ឆ្នាំ និងការពិន័យជាប្រាក់ចំពោះការផលិត នាំចូល ដឹកជញ្ជូន ស្តុកទុកសម្រាប់លក់ និងប្រើអាស៊ីដដោយគ្មានអាជ្ញាប័ណ្ណ។ ការរំលោភលក្ខខណ្ឌរបស់អាជ្ញាប័ណ្ណ នឹងត្រូវបានផ្តន្ទាទោសដោយជាប់ពន្ធនាគារយ៉ាងហោចណាស់មួយឆ្នាំ និង/ឬត្រូវពិន័យជាប្រាក់។

ទោះជា របបផ្តល់អាជ្ញាប័ណ្ណដែលមានវិសាលភាពទូលំទូលាយ ពិតជាមានសារៈសំខាន់ ប៉ុន្តែក៏មិនត្រូវច្រើនហួសហេតុពេកដែលមិនអាចអនុវត្តបាននោះដែរ។ បង់ក្លាដែស បានអនុម័យនូវប្រព័ន្ធផ្តល់អាជ្ញាប័ណ្ណដែលអ្នកធ្វើវិចារណកថាបាននិយាយថា *"មានភាពខុសឆ្គងបន្តិច សម្រាប់អ្នកប្រើប្រាស់អាស៊ីដក្នុងជីវភាពប្រចាំថ្ងៃ គឺតថាពុំមានភាពងាយស្រួលក្នុងការអនុវត្តន៍"* ។[36] ថ្វីបើមានការអនុម័តច្បាប់ថ្មី និងការថយចុះនៃអំពើហិង្សាដោយអាស៊ីដក៏ដោយ ប៉ុន្តែតាមរយៈបទពិសោធន៍នៅបង់ក្លាដែស ឃើញថាមានការលំបាកក្នុងការដាក់កំហិតលើការលក់អាស៊ីដ។ បរាជ័យក្នុងការអនុលោមតាមតម្រូវការផ្តល់អាជ្ញាប័ណ្ណ ដោយសារតែកង្វះខាតចំណេះដឹងផ្នែកច្បាប់ និងការស្ទាក់ស្ទើក្នុងការចំណាយទៅលើការដាក់ពាក្យស្នើសុំ។[37] ជាលទ្ធផល ធ្វើឲ្យពិបាកក្នុងការស្វែងរកប្រភពអាស៊ីដដែលប្រើក្នុងការវាយប្រហារ ដូច្នេះមិនអាចផ្តន្ទាទោសដល់អ្នកលក់បាន។ ចំណុចទីពីរ ការបំភ័ន្តពីមូលហេតុនៃការទិញអាស៊ីដ គឺមានភាព

[30] ច្បាប់របស់ បង់ក្លាដែសបានចែងពីរបបផ្តល់អាជ្ញាប័ណ្ណ សម្រាប់ការនាំចូល និងការផលិតអាស៊ីដ និងការដឹកជញ្ជូន រក្សាទុក លក់ និងប្រើប្រាស់ សូមអានមាត្រា១៦ នៃច្បាប់ស្តីពីការគ្រប់គ្រងអាស៊ីដរបស់បង់ក្លាដែស។

[31] មូលនិធិអាវ៉ន កំណត់សម្គាល់លេខ២១ ទំព័រទី១២ ។

[32] មាត្រា២២ នៃច្បាប់ស្តីពីការគ្រប់គ្រងអាស៊ីដរបស់បង់ក្លាដែសបានចែងថា *"អ្នកកាន់កាប់អាជ្ញាប័ណ្ណទាំងអស់ត្រូវរក្សាពល់ព័ត៌មានដែលពាក់ព័ន្ធនឹងអាស៊ីដ ដូចជា ការផលិត ការនាំចូល ការដឹកជញ្ជូន ការស្តុកទុក ការលក់ ការប្រើប្រាស់ ទិញ យោងតាមបញ្ញត្តិចែងក្នុងច្បាប់"* ។

[33] សូមអាន មាត្រា៦(ក) នៃសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងអាស៊ីដ និងបទល្មើសអាស៊ីដ របស់ប្រទេសប៉ាគីស្ថាន ។

[34] មាត្រា១៧-២០ នៃច្បាប់ស្តីពីការគ្រប់គ្រងអាស៊ីដរបស់បង់ក្លាដែស ។

[35] សូមអានមាត្រា៣៦ នៃច្បាប់ស្តីពីការគ្រប់គ្រងអាស៊ីដរបស់បង់ក្លាដែស។

[36] អ.ជ.ជ.ក.អ និង ម.ស.ម.ក កំណត់សម្គាល់លេខ៦ ទំព័រទី១០។ សូមអាន មាត្រា១៦-២២ នៃច្បាប់ស្តីពីការគ្រប់គ្រងអាស៊ីដរបស់បង់ក្លាដែស សម្រាប់ព័ត៌មានបន្ថែមស្តីពីដំណើរការផ្តល់អាជ្ញាប័ណ្ណ។

[37] មូលនិធិអាវ៉ន កំណត់សម្គាល់លេខ២១ ទំព័រទី២៩។

ងាយស្រួល ដោយគ្រាន់តែសំអាងលើមូលហេតុស្របច្បាប់។ ម្យ៉ាងវិញទៀត អ្នកធ្វើវិចារណកថាបានកត់សម្គាល់ថា "*ការលាក់កំបាំងអ្នកផ្គត់ផ្គង់ពិតប្រាកដក្នុងរបាយការណ៍របស់ពួកគេ គឺងាយស្រួលសម្រាប់អ្នកផ្គត់ផ្គង់ ដោយសារតែអំពើសូកប៉ាន់មានលក្ខណៈទូទៅនៅបង់ក្លាដែស ដូច្នេះធ្វើឲ្យអាស៊ីដអាចងាយស្រួលរកបាន*" ។[38]

បញ្ហានៃការគ្រប់គ្រងអាស៊ីដគឺមានភាពស្មុគស្មាញនៅបង់ក្លាដែស ដោយសារតែអវត្តមានរបស់ក្រុមស៊ើបអង្កេតដើម្បីគ្រប់គ្រងលើការប្រើប្រាស់ និងការលក់អាស៊ីដ។ អវត្តមាននៃក្រុមស៊ើបអង្កេតក្នុងប្រទេសបង់ក្លាដែសមានន័យថា ស្របពេលដែលប្រព័ន្ធច្បាប់មានលក្ខណៈទូលំទូលាយ អាស៊ីដនៅតែបន្តលក់ដោយគ្មានការត្រួតពិនិត្យជាពិសេសធ្វើឲ្យច្បាប់នេះគ្មានប្រយោជន៍ ដោយសារនគរបាលខកខានមិនបានត្រួតពិនិត្យមើលថាតើអ្នកប្រើប្រាស់មានអាជ្ញាប័ណ្ណឬក៏អត់។ ការតាមដាន គឺសំខាន់ណាស់ក្នុងការការពារការរាលដាលនៃទីផ្សារងងឹតរបស់អាស៊ីដ និងគួរតែផ្តោតលើការត្រួតពិនិត្យ និងស៊ើបអង្កេតដែលធ្វើឡើងដោយអង្គភាពជំនាញមានការបណ្តុះបណ្តាលក្នុងវិស័យនេះ ដែលខំប្រឹងប្រែងដើម្បីធានាថារូបវន្តបុគ្គល និងអាជីវកម្មត្រូវតែអនុវត្តស្របទៅតាមក្បួន និងច្បាប់។[39]

## ២.៣ ការកាត់ទោស និងផ្តន្ទាទោស

ការកាត់ទោស និងផ្តន្ទាទោស យ៉ាងមានប្រសិទ្ធភាពដល់ជនល្មើសនៃការវាយប្រហារដោយអាស៊ីដ ជាផ្នែកដ៏សំខាន់ក្នុងការការពារមិនឲ្យមានការវាយប្រហារនាពេលអនាគត។ ច្បាប់ទាំងឡាយដែល ម.ស.ម.ក បានធ្វើការសិក្សា បានផ្តល់គំនិតដ៏មានតម្លៃអំពីវិធីកាត់ទោសចំពោះជនល្មើសនៃការវាយប្រហារដោយអាស៊ីដ និងវិសាលភាពនៃការផ្តន្ទាទោសដ៏សមរម្យចំពោះបទល្មើសទាំងនេះ។

### (ក) ការកាត់ទោស

របាយការណ៍ស្តីពីអំពើហិង្សាដោយអាស៊ីដជុំវិញពិភពលោកបង្ហាញថា ជាញឹកញាប់ មានការខកខានមិនបានផ្តន្ទាទោសលើជនល្មើស។[40] ចំណុចនេះបង្កើតជាលទ្ធផលដែលមិនអាចចៀសវាងបាន គឺជនរងគ្រោះត្រូវតែរៀបចំដំណើរការនីតិវិធីច្បាប់ដោយខ្លួនឯង ដែលអាចបង្កើតជាបញ្ហា ដោយសារជនរងគ្រោះជាធម្មតាមានភាពភ័យតក់ស្លុត ដែលអាចរារាំងសមត្ថភាពពួកគេក្នុងការបន្តដំណើរការផ្នែកច្បាប់។ ប្រាក់ចំណាយលើសេវាច្បាប់ ដែលនឹងត្រូវលើកយកមកពិភាក្សាយ៉ាងលម្អិតក្នុងផ្នែកខាងក្រោមនៃរបាយការណ៍នេះក៏ជាបញ្ហាដែរ ជាពិសេស នៅពេលដែលរួមនឹងប្រាក់ចំណាយសម្រាប់ការព្យាបាលរបួសដោយអាស៊ីដ និងស្លាកស្នាម។ ការកាត់ទោសផ្នែកព្រហ្មទណ្ឌដ៏មានប្រសិទ្ធភាព គឺពិតជាមានសារៈសំខាន់ខ្លាំងណាស់ដើម្បីបញ្ចប់និទណ្ឌភាព និងដើម្បីធ្វើឲ្យមានការភ័យខ្លាចមិនហ៊ានប្រព្រឹត្តបទល្មើសទាំងនេះ។

ច្បាប់ស្តីពីការគ្រប់គ្រងអាស៊ីដនៅបង់ក្លាដែស បានចែងយ៉ាងជាក់លាក់ ពីការស៊ើបអង្កេតរបស់នគរបាលចំពោះបទល្មើសត្រូវតែបញ្ចប់ក្នុងរយៈពេល ៣០ថ្ងៃ បន្ទាប់ពីមានការជូនដំណឹងពីបទល្មើស ឬត្រូវបានបញ្ជាដោយចៅក្រម។[41] ប្រសិនបើការស៊ើបអង្កេតមិនបានបញ្ចប់ក្នុងរយៈពេលនេះទេ នឹងមានការបន្តផ្តល់ពេល៣០ថ្ងៃទៀត ដើម្បីធ្វើការស៊ើបអង្កេត។ តម្រូវឲ្យមានការស៊ើបអង្កេតយ៉ាងឆាប់រហ័ស ដើម្បីធានាថាជនរងគ្រោះដោយអាស៊ីដបានទទួលយុត្តិធម៌ឆាប់រហ័សបំផុតតាមដែលអាចធ្វើបាន ជាពិសេសជំនួយផ្នែកហិរញ្ញវត្ថុ និងផ្នែកវេជ្ជសាស្រ្ត និងការសងជំងឺចិត្ត សម្រាប់ឲ្យពួកគេរស់នៅបន្តទៀត។ ខណៈពេលដែលច្បាប់កម្ពុជាត្រូវតែពិចារណាលើកាតព្វកិច្ចវិជ្ជមានរបស់រដ្ឋក្នុងការស៊ើបអង្កេតបទល្មើសអាស៊ីដ ក្រសួងយុត្តិធម៌ និងក្រុមនគរបាលគួរតែធានាថាមន្រ្តីនគរបាលទាំងនេះ អាចធ្វើការស៊ើបអង្កេតយ៉ាងម៉ត់ចត់ និងត្រឹមត្រូវ។ ភាពជោគជ័យនៃការកាត់ទោស គឺប្រាកដជាមានទំនាក់ទំនងជាមួយនឹង

---

[38] យើធី បូឡឺនីនី "អំពើហិង្សាយេនឌ័រក្នុងលំហសាធារណៈ ៖ ការជះទឹកអាស៊ីដ" មជ្ឈមណ្ឌលសីឃ្វិន ដើម្បីសមភាព និងការរួមបញ្ចូល ឆ្នាំ២០១០ http://cequinindia.org/pdf/Special_Reports/Acid%20Throwing.pdf ចូលអានកាលពីថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១០។

[39] សៃរ៉ា រ៉ាម៉ាន, សាហប្រាដ ហ៊ូសៃន និងកានីស ហ្វៃតម៉ា "បញ្ឈប់និទណ្ឌភាពជុំវិញអំពើហិង្សាដោយអាស៊ីដ និងការរំលោភ" អូធិកា ថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០០៧។

[40] សូមអានរបាយការណ៍របស់មូលនិធិអាវ៉ន កំណត់សម្គាល់លេខ២១។

[41] មាត្រា១១ នៃច្បាប់ស្តីពីការគ្រប់គ្រងបទល្មើសអាស៊ីដរបស់បង់ក្លាដែស។

ការស៊ើបអង្កេតដ៏មានគុណភាព ដូច្នេះជាការចាំបាច់ដែលក្រុមនគរបាលទាំងនោះទទួលបានការបណ្តុះបណ្តាល និងធនធានគ្រប់គ្រាន់ក្នុងការធ្វើការស៊ើបអង្កេតយ៉ាងឆាប់រហ័ស។ ដើម្បីលើកទឹកចិត្តឲ្យមានការស៊ើបអង្កេតដ៏ត្រឹមត្រូវ ចំណុចដែលគួរឲ្យកត់សម្គាល់គឺ ច្បាប់របស់បង់ក្លាដែស បានចែងយ៉ាងបើកចំហថាអាចមានការចាត់វិធានការច្បាប់ប្រឆាំងនឹងមន្ត្រីទទួលបន្ទុកផ្នែកស៊ើបអង្កេត ដែលប្រមូលភស្តុតាង ឬរបាយការណ៍របស់សាក្សី ប្រសិនបើត្រូវបានរកឃើញថា "*ដើម្បីជួយបុគ្គលណាម្នាក់ឲ្យផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ មន្ត្រីនេះមិនបានប្រមូល ឬពិនិត្យភស្តុតាងដែលអាចប្រើប្រាស់បាន ឬឲ្យជនល្មើសធ្វើជាសាក្សី ឬចៀសវាងមិនរួមបញ្ចូលសាក្សីសំខាន់ក្នុងការរៀបចំកំណត់ហេតុរបស់ពួកគេ*" ។[42] ការបញ្ចូលបញ្ញត្តិបែបនេះ អាចជាបញ្ញត្តិដ៏សំខាន់ដើម្បីឲ្យជនរងគ្រោះមានការជឿជាក់ និងមានជំនឿចំពោះច្បាប់ និងប្រព័ន្ធអនុវត្តន៍ច្បាប់ ដូច្នេះអាចទទួលបានការសហការណ៍យ៉ាងពេញលេញ ដើម្បីធានាថាជនល្មើសត្រូវតែទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួន។

### (ខ) ការផ្តន្ទាទោស

ការផ្តន្ទាទោសយ៉ាងច្បាស់លាស់ និងសមាមាត្រគឺចាំបាច់ ដើម្បីធានាថាជនរងគ្រោះនឹងមិនចាញ់ប្រៀបអ្នកប្រព្រឹត្តបទល្មើស។ អ្វីដែលសំខាន់ គឺការទទួលស្គាល់ថាផលប៉ះពាល់នៃអំពើហិង្សាដោយអាស៊ីដមិនបញ្ឈប់ត្រឹមតែការវាយប្រហារនោះទេ ផលវិបាកគឺមានក្នុងគ្រប់ទិដ្ឋភាពទាំងអស់នៃជីវិត និងគ្មានពេលកំណត់។ ដូច្នេះ វិធានការផ្តន្ទាទោសត្រូវតែសមាមាត្រនឹងកម្រិតរបួស។ ការផ្តន្ទាទោសគួរតែពិចារណាលើទំហំ ជម្រៅ និងប្រវែងនៃរបួសរាងកាយដែលបណ្តាលមកពីបទល្មើស[43] ការខូចខាតជាអចិន្ត្រៃយ៍ដែលកើតមាន រួមទាំងផ្នែកសុខភាព ការបាត់បង់ជីវភាពប្រចាំថ្ងៃ និងប្រាក់ចំណូល ឋានៈក្នុងសង្គម និងភាពតក់ស្លុត ជាដើម។ គ្រប់ការផ្តន្ទាទោសគួរតែពិចារណាចំពោះការរៀបចំផែនការទុកមុន និងការវាយតម្លៃលើលក្ខណៈនៃបទល្មើស។

បន្ថែមពីលើនេះ គួរតែមានការផ្តន្ទាទោសស្មើគ្នា ចំពោះអ្នកជួយសម្រួល និងញុះញង់ឲ្យប្រព្រឹត្តបទល្មើស និងភាគីទីបីដែលបង្គាប់ឲ្យប្រព្រឹត្ត ឬរៀបចំបទល្មើស។ ដូច្នេះ បុគ្គលគ្រប់រូបដែលពាក់ព័ន្ធនឹងបទល្មើសត្រូវតែយកមកផ្តន្ទាទោស រួមទាំងអ្នកញុះញង់ឲ្យប្រព្រឹត្តបទល្មើស ហើយការផ្តន្ទាទោសនេះគួរតែប្រហាក់ប្រហែលនឹងជនល្មើស។[44]

## ២.៤ ការគាំពារជនរងគ្រោះ

ច្បាប់អាស៊ីដទាំងអស់ ត្រូវតែទទួលស្គាល់ពីផលប៉ះពាល់នៃបទល្មើសដែលមានមកលើជនរងគ្រោះពេញមួយជីវិត។ ដូច្នេះ ការបញ្ចូលបទប្បញ្ញត្តិគាំទ្រដល់តម្រូវការរបស់ជនរងគ្រោះ គឺជាគោលការណ៍សំខាន់ដើម្បីឲ្យមានច្បាប់អាស៊ីដដ៏ជោគជ័យ។ ច្បាប់ត្រូវតែទទួលខុសត្រូវចំពោះតម្រូវការរបស់ជនរងគ្រោះ ទាំងផ្នែកវេជ្ជសាស្ត្រ ផ្នែកចិត្តសាស្ត្រ ផ្នែកច្បាប់ និងផ្នែកហិរញ្ញវត្ថុ ដែលកើតមានជាបន្តបន្ទាប់ ទាំងក្នុងរយៈពេលខ្លី និងរយៈពេលវែង។

បទប្បញ្ញត្តិចែងពីការគាំទ្រគ្រប់ប្រភេទ ចោទជាសំណួរថា តើការគាំទ្រនេះនឹងទទួលបានមូលនិធិពីប្រភពណា? ចំណុចមួយដែលអាចធ្វើទៅបាន គឺតាមរយៈការបង្កើតមូលនិធិអាស៊ីដថ្នាក់ជាតិ។ នៅបង់ក្លាដែស ច្បាប់ស្តីពីការគ្រប់គ្រងអាស៊ីដរបស់បង់ក្លាដែស បានបង្កើតមូលនិធិឯករាជ្យមួយហៅថា មូលនិធិរបស់ក្រុមប្រឹក្សាជាតិគ្រប់គ្រងអាស៊ីដប្រទេសបង់ក្លាដេស (ម.ក.ជ.គ.អ.ប) ដើម្បី "*ស្វែងរកមូលនិធិដើម្បីសម្រេចតាមគោលបំណងក្នុងការបង្កើនការយល់ដឹងជាសាធារណៈ អំពីផលប៉ះពាល់អាក្រក់នៃការប្រើប្រាស់អាស៊ីដក្នុងផ្លូវខុស និងទិដ្ឋភាពនៃគ្រោះថ្នាក់ និងដើម្បីផ្តល់ការព្យាបាល និងជំនួយផ្នែកច្បាប់ ព្រមទាំងការស្តារនីតិសម្បទាដល់ជនរងគ្រោះដោយសារអាស៊ីដ*" ។[45]

---

[42] ដូចខាងលើ មាត្រា១៣ ។

[43] ការផ្តន្ទាទោសអតិបរមានៅបង់ក្លាដែស ចំពោះបទល្មើសដែលបណ្តាលឲ្យស្លាប់ គឺទោសប្រហារជីវិត ឬដាក់ពន្ធនាគារពេញមួយជីវិត និងការធ្វើការយ៉ាងធ្ងន់ធ្ងរ និងពិន័យជាប្រាក់បន្ថែមចំនួន ១០០,០០០ តាកា ក្នុង ច្បាប់គ្រប់គ្រងអាស៊ីដរបស់បង់ក្លាដែស មាត្រា៤។

[44] អ.ជ.ជ.ក.អ និង ម.ស.ម.ក កំណត់សម្គាល់លេខ៦ ទំព័រទី១៨។ មាត្រា៧ ក្នុងច្បាប់ស្តីពីការគ្រប់គ្រងបទល្មើសអាស៊ីដរបស់បង់ក្លាដែស ចែងថាការផ្តល់ជំនួយ និងការញុះញង់នឹងត្រូវទទួលការផ្តន្ទាទោសដូចជាជនល្មើសដែរ។

[45] ច្បាប់ស្តីពីការគ្រប់អាស៊ីដរបស់បង់ក្លាដែស មាត្រា១០។

ថវិកាដែលមានក្នុង ម.ក.ជ.គ.អ.ប អាចបានមកពី ជំនួយពីរដ្ឋាភិបាល ជំនួយរបស់រដ្ឋាភិបាលបរទេស ជំនួយរបស់អាជ្ញាធរក្នុងស្រុក ជំនួយរបស់អង្គការ និង/ឬបុគ្គល និងជំនួយមកពីប្រភពដទៃទៀត។ យន្តការបែបនេះ មានភាពចាំបាច់ខ្លាំងណាស់ ដើម្បីផ្តល់នូវជំនួយ និងការថែរក្សាដែលជនរងគ្រោះដោយសារអាស៊ីដត្រូវការ។ មូលនិធិនេះក៏ត្រូវបានប្រើដើម្បីបង្កើនការយល់ដឹងជាសាធារណៈស្តីពីគ្រោះថ្នាក់របស់អាស៊ីដផងដែរ។ នេះជាឧទាហរណ៍ ដែលច្បាប់អាស៊ីដទាំងអស់គួរតែមានលក្ខណៈគ្របដណ្តប់ក្នុងវិធីសាស្ត្រទាំងនោះ មិនមែនត្រឹមតែអាចដោះស្រាយផលប៉ះពាល់នៃអំពើហិង្សាដោយអាស៊ីដប៉ុណ្ណោះទេ ប៉ុន្តែដោះស្រាយជាមួយរោគសញ្ញាផងដែរ។ គោលបំណងនៃការលើកកម្ពស់ការយល់ដឹងស្តីពីស្ថានភាពជាក់ស្តែងនៃអំពើហិង្សាដោយអាស៊ីដត្រូវតែបញ្ចូលក្នុងច្បាប់។ ចំណុចនេះ ក៏អាចមានផលប្រយោជន៍បន្ថែមសម្រាប់ជនរងគ្រោះដោយអាស៊ីដ ប្រឆាំងនឹងការរើសអើង និងការមាក់ងាយផងដែរ។ ក្នុងប្រទេសដូចជាកម្ពុជា ដែលបទល្មើសអាស៊ីដកំពុងតែកើនឡើង អ្វីដែលចាំបាច់គឺច្បាប់អាស៊ីដទាំងអស់ ត្រូវតែរួមបញ្ចូលនូវការផ្តើមផ្តល់ជំនួយពីរដ្ឋាភិបាល ក្នុងគោលបំណងលើកកម្ពស់ការយល់ដឹងស្តីពីផលប៉ះពាល់ និងផលវិបាកនៃអំពើហិង្សាដោយអាស៊ីដ។

## (ក) ការគាំពារផ្នែកវេជ្ជសាស្ត្រ

ច្បាប់ក្នុងប្រទេសដទៃ បានកំណត់ជាកាតព្វកិច្ចដល់រដ្ឋ ដើម្បីផ្តល់ការគាំពារផ្នែកវេជ្ជសាស្ត្រដល់ជនរងគ្រោះ ជា ឧទាហរណ៍ គឺបញ្ញត្តិដែលបានចែងថារដ្ឋាភិបាលត្រូវឧបត្ថម្ភចំពោះថ្លៃចំណាយនៃការវាយតម្លៃផ្នែកវេជ្ជសាស្ត្រ។ ឧទាហរណ៍នៃការគាំពារផ្នែកវេជ្ជសាស្ត្រសម្រាប់ជនរងគ្រោះ ក៏មានចែងក្នុងច្បាប់ស្តីពីការគ្រប់គ្រងបទល្មើសអាស៊ីដរបស់បង់ក្លាដែស និងច្បាប់ស្តីពីការគ្រប់គ្រងអាស៊ីដរបស់បង់ក្លាដែសផងដែរ។ មាត្រា២៩(១) នៃច្បាប់ស្តីពីការគ្រប់គ្រងបទល្មើសអាស៊ីដរបស់បង់ក្លាដែស ចែងថា *"ជនរងគ្រោះនៃបទល្មើសទាំងឡាយដែលមានចែងក្នុងច្បាប់នេះ [ច្បាប់ស្តីពីការគ្រប់គ្រងបទល្មើស] នឹងត្រូវបានព្យាបាលដោយមន្ទីរពេទ្យរដ្ឋ ឬមន្ទីរពេទ្យឯកជនដែលទទួលស្គាល់ដោយរដ្ឋក្នុងគោលបំណងនេះ ឬមជ្ឈមណ្ឌលសុខភាពដែលបង្កើតដោយអង្គការស្ម័គ្រចិត្ត"* ។ ប៉ុន្តែ ការប្រើពាក្យថា *"អាច"* ក្នុងបញ្ញត្តិនេះ ហាក់ដូចជាមិនច្បាស់លាស់ និងធ្វើឲ្យជនរងគ្រោះប្រហែលជាមិនអាចទទួលបានព្យាបាលយ៉ាងសមរម្យ។ មាត្រា១៤ នៃច្បាប់ស្តីពីការគ្រប់គ្រងអាស៊ីដរបស់បង់ក្លាដែស ចែងថា មន្ត្រីមានសមត្ថកិច្ចអាចដាក់ពាក្យស្នើសុំជាលាយលក្ខណ៍អក្សរទៅកាន់ គណៈកម្មាធិការស្រុក នៃក្រុមប្រឹក្សាជាតិគ្រប់គ្រងអាស៊ីដ[46] ដើម្បីរៀបចំការព្យាបាលជាចាំបាច់ពេលមានជនរងគ្រោះដោយសារអាស៊ីដ ហើយដែលត្រូវការការព្យាបាលជាបន្ទាន់ ដើម្បីអាចឲ្យពួកគាត់រស់នៅក្នុង *'ជីវិតធម្មតា'* វិញបាន។ ជាថ្មីម្តងទៀត ខណៈពេលដែលគោលការណ៍នៃការផ្តល់ការគាំទ្រផ្នែកវេជ្ជសាស្ត្រសម្រាប់ជនរងគ្រោះមានចែងក្នុងច្បាប់ ប៉ុន្តែការប្រើពាក្យមិនច្បាស់លាស់ និងអាចប្រែប្រួល ដូចជាពាក្យថា *'ជីវិតធម្មតា'* អាចបណ្តាលឲ្យជនរងគ្រោះអាចនឹងមិនបានទទួលជំនួយដែលពួកគេត្រូវការ ជាពិសេសក្នុងអវត្តមាននៃដំណើរការដាក់ពាក្យបណ្តឹងឧទ្ធរណ៍។ ឧទាហរណ៍របស់ប្រទេសបង់ក្លាដែស គឺបង្ហាញយ៉ាងច្បាស់ថា បញ្ញត្តិក្នុងច្បាប់កម្ពុជាស្តីពីបញ្ហាការថែទាំព្យាបាលគួរតែមានភាពជាក់ច្បាស់ និងចែងដោយបើកចំហថាជនរងគ្រោះនឹងត្រូវទទួលការព្យាបាល ហើយការព្យាបាលត្រូវតែផ្តល់ជូនជនរងគ្រោះ។ បន្ថែមពីលើនេះ ពិតជាមានសារៈសំខាន់ណាស់ដែលច្បាប់កំណត់កាតព្វកិច្ចឲ្យរដ្ឋាភិបាល ដើម្បីធានាថាអ្នកជំនាញផ្នែកសុខភាពសាធារណៈ ដែលត្រូវបានបណ្តុះបណ្តាលក្នុងកម្រិតមូលដ្ឋាន បានរួមចំណែកធ្វើការព្យាបាលរបួសដោយអាស៊ីដ។ ចំណុចនេះគឺសំខាន់ណាស់ ដោយសារតែការព្យាបាលមិនត្រឹមត្រូវអាចបណ្តាលឲ្យមានគ្រោះថ្នាក់ច្រើនជាងការជួយសង្គ្រោះ។

[46] ច្បាប់ស្តីពីការគ្រប់គ្រងអាស៊ីដរបស់បង់ក្លាដែស ចែងថា គណៈកម្មាធិការស្រុក នៃក្រុមប្រឹក្សាជាតិគ្រប់គ្រងអាស៊ីដមាននៅគ្រប់ស្រុក។ គណៈកម្មាធិការនេះត្រូវតែចូលរួមពី អនុប្រធានគណៈកម្មការ ស្នងការនគរបាល វេជ្ជបណ្ឌិតផ្នែកវះកាត់ មន្ត្រីពីក្រសួងកិច្ចការនារី និងអ្នកតំណាងអង្គការមិនមែនរដ្ឋាភិបាល ជាដើម។ ទំនួលខុសត្រូវរបស់គណៈកម្មាធិការនេះ រួមទាំងការអនុវត្តន៍គោលនយោបាយរបស់ក្រុមប្រឹក្សាពាក់ព័ន្ធនឹងការគ្រប់គ្រងការផលិត ការដឹកជញ្ជូន ការផ្ញើទុក ការលក់ និងការប្រើប្រាស់អាស៊ីដ ការលើកកម្ពស់ការយល់ដឹង និងការអនុវត្តន៍នូវគោលនយោបាយពាក់ព័ន្ធនឹងការព្យាបាល និងស្តារនីតិសម្បទា។ សូមអាន មាត្រា៧-៨ នៃច្បាប់ស្តីពីការគ្រប់គ្រងអាស៊ីដរបស់បង់ក្លាដែស។

## (ខ) ការគាំពារផ្នែកច្បាប់

ការគាំពារផ្នែកច្បាប់ គឺជាទិដ្ឋភាពសំខាន់មួយទៀតពាក់ព័ន្ធនឹងអំពើហិង្សាដោយអាស៊ីដ ជាពិសេសគឺការប្រឆាំងនឹងនិទណ្ឌភាព។ ជនរងគ្រោះភាគច្រើនមិនអាចទទួលបានយុត្តិធម៌យ៉ាងត្រឹមត្រូវ ដោយសារភាពក្រីក្រ និងការខ្វះចំណេះដឹងពីបញ្ហាច្បាប់ ធ្វើឲ្យពួកគេមិនមានសមត្ថភាពក្នុងការដាក់ពាក្យបណ្ដឹង និងទទួលបានយុត្តិធម៌។ ដូច្នេះ អ្វីដែលសំខាន់គឺច្បាប់អាស៊ីដទាំងអស់ ដែលអនុវត្តនៅកម្ពុជា គួរតែទទួលខុសត្រូវចំពោះកង្វះខាតនៃលទ្ធភាពទទួលបានយុត្តិធម៌ និងការបញ្ចប់និទណ្ឌភាព។

ជំនួយផ្នែកច្បាប់ពិតជាចាំបាច់ណាស់ក្នុងផ្នែកនេះ។ ឧទាហរណ៍ ច្បាប់របស់បង់ក្លាដែសចែងថា "*ជនរងគ្រោះដោយអាស៊ីដ ឬអ្នកតំណាង អាចដាក់ពាក្យស្នើសុំទៅគណៈកម្មាធិការស្រុកដើម្បីសុំជំនួយផ្នែកច្បាប់បាន*" ។[47] ស្របពេលដែលច្បាប់របស់បង់ក្លាដែសបានចែងពីជំនួយផ្នែកច្បាប់ដល់ជនរងគ្រោះទាំងអស់ តែពុំមានវិធានការដ៏តឹងរ៉ឹងដែលដាក់កំណត់ថាមេធាវីនឹងត្រូវបានតែងតាំងក្នុងករណីនៃការវាយប្រហារទាំងអស់ ធ្វើឲ្យអ្នកធ្វើវិចារណកថាតវ៉ាថា "*ច្បាប់នេះដូចជាច្បាប់គ្មានជីវិត*" ។[48] ច្បាប់កម្ពុជាគួរតែអនុវត្តបញ្ញត្តិស្ដីពីជំនួយផ្នែកច្បាប់ដូចគ្នា ប៉ុន្តែគួរតែកំណត់ជាកាតព្វកិច្ចរបស់រដ្ឋដែលត្រូវតែរៀបចំឲ្យមានមេធាវីក្នុងគ្រប់ករណីទាំងអស់។

ការការពារជនរងគ្រោះ ក៏មានសារៈសំខាន់ស្មើគ្នាដែរក្នុងទិដ្ឋភាពនៃការគាំពារផ្នែកច្បាប់ និងធានាឲ្យមានការកាត់ទោសដ៏មានប្រសិទ្ធភាព។ ជនរងគ្រោះជាច្រើនបានបង្ហាញពីភាពភ័យខ្លាចថានឹងរងការវាយប្រហារនាពេលអនាគត និងការសងសឹកដោយសារតែជនរងគ្រោះរៀបចំនីតិវិធីផ្នែកច្បាប់ ក៏បានរួមចំណែកក្នុងវប្បធម៌និទណ្ឌភាពផងដែរ។ បញ្ហាដែលជនល្មើសនៅតែមានសេរីភាព ដោយសារតែពួកគេមិនទាន់ត្រូវបានចាប់ខ្លួន ឬបង់ប្រាក់ធានាដើម្បីនៅក្រៅឃុំ បណ្ដាលឲ្យជនរងគ្រោះកាន់តែភ័យខ្លាចថែមទៀត។ ឧទាហរណ៍ កង្វះកម្មវិធីរបស់រដ្ឋាភិបាលដើម្បីការពារដល់ជនរងគ្រោះ និងសាក្សី នៅបង់ក្លាដែស ត្រូវបានមើលឃើញថាជាឧបសគ្គមួយក្នុងការស្វែងរកយុត្តិធម៌ជូនជនរងគ្រោះ។[49] ដូច្នេះ គ្រប់ច្បាប់អាស៊ីដនៅកម្ពុជាគួរតែបញ្ចូលបញ្ញត្តិសមរម្យ និងធ្ងន់ធ្ងរចំពោះការបង់ប្រាក់ធានាក្នុងករណីវាយប្រហារដោយអាស៊ីដ ព្រោះអាចបង្កផលប៉ះពាល់ផ្នែកចិត្តសាស្ត្ររបស់ជនរងគ្រោះ និងការគំរាមកំហែង ការតាមរំខាន ការសម្លុតបំភ័យ និងការចាប់បង្ខំ របស់ជនល្មើស និងគ្រួសារជនល្មើសបន្ទាប់ពីការប្រព្រឹត្តបទល្មើស[50] ស្របពេលជាមួយគ្នានោះក៏គួរតែមានការការពារជនរងគ្រោះ និងសាក្សីអំឡុងពេលសនាវការ តាមការគួរផងដែរ។

---

[47] សូមអានមាត្រា១៥(១) នៃច្បាប់ស្ដីពីគ្រប់គ្រងអាស៊ីដរបស់បង់ក្លាដែស។

[48] ការផ្ដល់មតិរបស់ សាល់ម៉ា អាលី សមាគមស្ត្រីមេធាវីជាតិ ក្នុងរ៉ូឡែន បើក "*បញ្ហានៃការវាយប្រហារដោយទឹកអាស៊ីដនៅបង់ក្លាដែស*" ព័ត៌មាន ប៊ី ប៊ី ស៊ី ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៦ អាចអានបាន http://news.bbc.co.uk/2/hi/5133410.stm ចូលអានកាលពីថ្ងៃទី១៦ ខែមករា ឆ្នាំ២០១១។

[49] ការផ្ដល់មិតរបស់លោក បណ្ឌិត សាល់ម៉ា អាលី ជានាយកប្រតិបត្តិ, រ៉េហាណា ស៊ុលតាណា ជាប្រធានជំនួយផ្នែកច្បាប់ និង តូរីកា ខុដ័រ សមាគមស្ត្រីមេធាវីជាតិ ដូចដែលបានដកស្រង់សម្ដីក្នុងមូលនិធិអារ៉ែន កំណត់សម្គាល់លេខ២១ ទំព័រទី៣១។

[50] អ.ជ.ជ.ក.អ និង ម.ស.ម.ក កំណត់សម្គាល់លេខ៦ ទំព័រទី២១។ សូមអានមាត្រា១៥ នៃច្បាប់ស្ដីពីការគ្រប់គ្រងបទល្មើសអាស៊ីដ របស់បង់ក្លាដែសបន្ថែម។

# ៣. ច្បាប់ស្តីពីការគ្រប់គ្រងអាស៊ីដខ្លាំងនៅកម្ពុជា

ច្បាប់ស្តីពីការគ្រប់គ្រងអាស៊ីដខ្លាំងសម្រាប់កម្ពុជា បានអនុម័តដោយ រដ្ឋសភានៅថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០១១ និងបានចូលជាធរមាននៅក្នុងខែធ្នូ ឆ្នាំ២០១១ (ច្បាប់គ្រប់គ្រងអាស៊ីដខ្លាំង) ។ ខ្លឹមសារច្បាប់គ្រប់គ្រងអាស៊ីដខ្លាំងនេះ មានក្នុងឧបសម្ព័ន្ធនៃរបាយការណ៍។

ច្បាប់នេះមានគោលបំណងកំណត់អំពីការគ្រប់គ្រង ការត្រួតពិនិត្យអាស៊ីដខ្លាំងគ្រប់ប្រភេទដែលបណ្តាលឲ្យមានគ្រោះថ្នាក់ដល់សុខភាព និងអាយុជីវិតមនុស្ស និងដើម្បីការពារបទល្មើសដែលប្រើប្រាស់អាស៊ីដខ្លាំង ។[51] ជាទូទៅ ច្បាប់នេះមានទិដ្ឋភាពវិជ្ជមានជាច្រើនដែលដាក់ក្របខណ្ឌចំពោះច្បាប់គ្រប់គ្រងអាស៊ីដខ្លាំង ហើយបានគ្របដណ្តប់វិស័យសំខាន់ៗមួយចំនួន។ ប៉ុន្តែ នៅមានការខ្វះចន្លោះមួយចំនួនក្នុងច្បាប់នេះ ដែលគួរតែលើកយកមកពិភាក្សា។ ផ្អែកលើសេចក្តីព្រាងច្បាប់ដែលយើងទទួលបាន ក្នុងផ្នែកនេះនៃរបាយការណ៍ យើងនឹងធ្វើការត្រួតពិនិត្យលើសេចក្តីព្រាងច្បាប់ធៀបនឹងគោលការណ៍ដែលបានពិភាក្សាក្នុងផ្នែកខាងលើ ដើម្បីវាយតម្លៃពីភាពខ្លាំងរបស់ច្បាប់នេះ ក្នុងការការពារ ទប់ស្កាត់ និងបង្ក្រាបរាល់អំពើហិង្សាដោយអាស៊ីដ និងផលវិបាកទាំងអស់។

## ៣.១ ការចាត់ទុកអំពើហិង្សាដោយអាស៊ីដជាបទល្មើស

សេចក្តីព្រាងច្បាប់ មានចែងពីបញ្ញត្តិសំខាន់ៗ ក្នុងការចាត់ទុកអំពើហិង្សាដោយអាស៊ីដខ្លាំងជាបទល្មើស។ ក្នុងសេចក្តីព្រាងច្បាប់ និយមន័យ "អាស៊ីដខ្លាំង" រួមមាន "*អាស៊ីដ វត្ថុធាតុដើម និងធាតុផ្សំអាស៊ីដទាំងអស់ទោះជាល្បាយរាវ ឬរឹង ហើយមាន pH ស្មើ ឬក្រោម៣ ដែលបណ្តាលឲ្យមានគ្រោះថ្នាក់ដល់សុខភាព និងអាយុជីវិតមនុស្សដូចមានចុះនៅក្នុងតារាងឧបសម្ព័ន្ធនៃច្បាប់នេះ*" ។[52] អាស៊ីដខ្លាំងដែលបានរៀបរាប់ក្នុងឧបសម្ព័ន្ធនៃច្បាប់គ្រប់គ្រងអាស៊ីដខ្លាំង រួមមាន អាស៊ីដក្លរីឌ្រិក អាស៊ីដនីទ្រិក អាស៊ីដអ៊ីដ្រូប្រូមិក និងអាស៊ីដក្ល័រិក។ និយមន័យនេះ មានសារៈសំខាន់ដោយបានចែងថាវិសាលភាពនៃបញ្ជីនេះអាចនឹងត្រូវបានផ្លាស់ប្តូរដោយអនុក្រឹត្យ គឺស្រដៀងនឹងនិយមន័យក្នុងច្បាប់របស់បង់ក្លាដែស។ ចំណុចនេះមានសារៈសំខាន់ ដោយសារបញ្ជីនេះអាចពង្រីកវិសាលភាព ដើម្បីអាចបញ្ចូលអាស៊ីដថ្មីៗ ដែលពីរបកគំហើញថ្មី និងបច្ចេកវិទ្យាថ្មីដែលបង្កើតសារធាតុថ្មី។

ច្បាប់គ្រប់គ្រងអាស៊ីដខ្លាំង បានចែកដាច់ នូវអំពើមនុស្សឃាតដោយចេតនា មនុស្សឃាតដោយអចេតនា អំពើទារុណកម្ម និងអំពើឃោរឃៅ ការបង្ករបួសស្នាមដោយចេតនា និងការបង្ករបួសស្នាមដោយអចេតនា ដោយប្រើ "អាស៊ីដខ្លាំង" ។ អំពើមនុស្សឃាតដោយចេតនា ត្រូវផ្តន្ទាទោសឲ្យជាប់ពន្ធនាគារចាប់ពី ១៥ទៅ៣០ឆ្នាំ។ ក្នុងករណីវាយប្រហារដោយអាស៊ីដ ដែលមានការរៀបចំផែនការ ឬប្រើអាស៊ីដដើម្បីធ្វើទារុណកម្មមុន ឬក្នុងពេលសម្លាប់ នឹងត្រូវផ្តន្ទាទោសឲ្យជាប់ពន្ធនាគារពេញមួយជីវិត។ អំពើមនុស្សឃាតដោយអចេតនា ដោយសារតែការធ្វេសប្រហែស ឬបំពានកាតព្វកិច្ចសុវត្ថិភាព នឹងត្រូវផ្តន្ទាទោសឲ្យជាប់ពន្ធនាគារចាប់ពី ១ទៅ៥ឆ្នាំ និងត្រូវពិន័យជាប្រាក់។ អំពើហិង្សាដោយចេតនា នឹងត្រូវផ្តន្ទាទោសឲ្យជាប់ពន្ធនាគារចាប់ពី ២ទៅ៥ឆ្នាំ និងត្រូវពិន័យជាប្រាក់ ប៉ុន្តែប្រសិនបើអំពើហិង្សាដោយចេតនានេះបណ្តាលឲ្យមានពិការភាពជាអចិន្ត្រៃយ៍ នឹងត្រូវផ្តន្ទាទោសឲ្យជាប់ពន្ធនាគារចាប់ពី ៥ទៅ១០ឆ្នាំ។ ប្រសិនបើអំពើនេះ បណ្តាលឲ្យជនរងគ្រោះបាត់បង់ជីវិតដោយអចេតនា នឹងត្រូវផ្តន្ទាទោសឲ្យជាប់ពន្ធនាគារពី ១០ទៅ២០ឆ្នាំ។ របួសដែលបណ្តាលមកពីការធ្វេសប្រហែស ឬការបំពានកាតព្វកិច្ចសុវត្ថិភាព នឹងត្រូវផ្តន្ទាទោសឲ្យជាប់ពន្ធនាគារចាប់ពី ១ខែទៅ១ឆ្នាំ និងត្រូវពិន័យជាប្រាក់។ ក្នុងករណីដែលបានប្រើអាស៊ីដខ្លាំងក្នុងអំពើទារុណកម្ម និងអំពើឃោរឃៅ នឹងត្រូវផ្តន្ទាទោសឲ្យជាប់ពន្ធនាគារចាប់ពី ១០ទៅ២០ឆ្នាំ។ ការផ្តន្ទាទោសនឹងកើនឡើងពី ១៥ទៅ២៥ឆ្នាំ ប្រសិនបើសកម្មភាពនេះបណ្តាលឲ្យពិការ និងត្រូវផ្តន្ទាទោសឲ្យជាប់ពន្ធនាគារពី ២០ទៅ៣០ឆ្នាំ ប្រសិនបើបណ្តាលឲ្យជនរងគ្រោះបាត់បង់ជីវិត ឬធ្វើអត្តឃាត។ ចំពោះអំពើមនុស្សឃាតដោយអចេតនា ការបង្ករបួស

---

[51] សូមអានមាត្រា១ និង២ នៃច្បាប់គ្រប់គ្រងអាស៊ីដខ្លាំង។

[52] សូមអានមាត្រា៤ នៃច្បាប់គ្រប់គ្រងអាស៊ីដខ្លាំង។

ស្នាមដោយចេតនា និងការបង្ករបួសស្នាមដោយអចេតនា និងអំពើទារុណកម្ម និងអំពើឃោរឃៅ នឹងមានការផ្តន្ទាទោសបន្ថែមទៀត យោងតាមបញ្ញត្តិចែងក្នុងក្រមព្រហ្មទណ្ឌ។

សំខាន់ជាងនេះ ច្បាប់គ្រប់គ្រងអាស៊ីដខ្លាំង ក៏បានចែងយ៉ាងច្បាស់លាស់ថានីតិបុគ្គល នឹងត្រូវបានប្រកាសឲ្យទទួលខុសត្រូវព្រហ្មទណ្ឌ ពាក់ព័ន្ធនឹងការស្លាប់ ឬការបង្ករបួសដោយអចេតនាបណ្តាលមកពីការធ្វេសប្រហែស ឬភាពមិនប្រុងប្រយ័ត្ន ឬមកពីលទ្ធផលនៃការរំលោភកាតព្វកិច្ចសន្តិសុខផងដែរ[53] និងអាចត្រូវផ្តន្ទាទោសមួយ ឬច្រើនក្រោមមាត្រា២០៩ និង២៣៨ នៃក្រមព្រហ្មទណ្ឌដែលរួមមាន ការរំលាយ ឬហាមឃាត់ចំពោះការធ្វើសកម្មភាពមួយ ឬច្រើន ឬការបិទគ្រឹះស្ថានដែលប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើស។ នេះជាការគួរឲ្យលើកសរសើរមួយ ក្នុងខណៈពេលដែលច្បាប់បានរួមបញ្ចូលនូវកម្រិតនៃទំនួលខុសត្រូវព្រហ្មទណ្ឌ ដែលនីតិបុគ្គលជាប់ពាក់ព័ន្ធបានធ្វេសប្រហែស និងមិនប្រុងប្រយ័ត្នចំពោះការរក្សាទុក លក់ ឬចែកចាយអាស៊ីដខ្លាំងដែលបណ្តាលឲ្យមានការបាត់បង់ជីវិត ឬក៏គ្រោះថ្នាក់ដល់បុគ្គល ច្បាប់ ឬអនុក្រឹត្យត្រូវតត្រាលើរបបគ្រប់គ្រង (សូមអានខាងក្រោមសម្រាប់សេចក្តីលម្អិត) គួរតែបញ្ចូលនូវបញ្ញត្តិមួយដែលអាចព្យួរអាជ្ញាបណ្ណដែលបានផ្តល់ទៅកាន់នីតិបុគ្គលដែលពាក់ព័ន្ធ ក្នុងរយៈពេលកំណត់មួយជាជាងទុកឲ្យការសម្រេចជាឆន្ទានុសិទ្ធិរបស់ចៅក្រម ក្នុងក្រមព្រហ្មទណ្ឌ ។

ស្របពេលដែលច្បាប់គ្រប់គ្រងអាស៊ីដខ្លាំង បានបញ្ចូលនូវការវិវឌ្ឍន៍សំខាន់ៗ ក្នុងបញ្ញត្តិការផ្តន្ទាទោសធៀបនឹងបញ្ញត្តិក្នុងក្រមព្រហ្មទណ្ឌ ដែលបានឆ្លុះបញ្ចាំងពីភាពធ្ងន់ធ្ងរនៃបទល្មើស តែយើងនៅមានការព្រួយបារម្ភចំពោះការផ្តន្ទាទោសដែលមានកម្រិតទាប ចំពោះអំពើហិង្សាដោយចេតនាដែលបណ្តាលឲ្យពិការជាអចិន្ត្រៃយ៍។ ការផ្តន្ទាទោសបែបនេះមិនបានឆ្លុះបញ្ចាំងពីកម្រិតរបួសផ្នែករាងកាយ និងផ្លូវចិត្តដែលជនរងគ្រោះត្រូវប្រឈម និងដោយយោងតាមការពិតថាជនរងគ្រោះដោយអាស៊ីដនឹងរស់នៅជាមួយនឹងការខូចសម្ផស្សពេញមួយជីវិត គឺយូរជាងរយៈពេលដែលជនល្មើសទទួលទោសទៅទៀត។ ការផ្តន្ទាទោសបែបនេះក៏បានខកខានក្នុងការស្វែងរកយុត្តិធម៌ដល់ជនរងគ្រោះ ថែមទាំងបរាជ័យក្នុងការរួមចំណែកទប់ស្កាត់ការប្រើអំពើហិង្សាដោយអាស៊ីដខ្លាំងផងដែរ។

បន្ថែមពីលើនោះ នៅមានការព្រួយបារម្ភមួយ ដែលសេចក្តីព្រាងដំបូងមួយបានចែងយ៉ាងបើកចំហថាសហចារី អ្នកផ្តើមគំនិត និងអ្នកសមគំនិត នឹងត្រូវទទួលទោសដូចគ្នានឹងអ្នកប្រព្រឹត្តបទល្មើស ច្បាប់គ្រប់គ្រងអាស៊ីដខ្លាំងនេះ មិនបានបញ្ចូលនូវទោសប្បញ្ញត្តិដែលនឹងត្រូវដាក់ទៅលើ សហចារី អ្នកផ្តើមគំនិត និង/ឬ អ្នកសមគំនិតនោះទេ។ ដូចក្នុងករណីដំបូងដែលរបាយការណ៍នេះបានលើកឡើង ចរិតលក្ខណៈនៃអំពើហិង្សាដោយអាស៊ីដមានលក្ខណៈ ស្មុគស្មាញ។ ជាញឹកញាប់ ដែលបុគ្គលអ្នកប្រព្រឹត្តអំពើជះ ឬស្រោច មិនចាំបាច់ជាអ្នកផ្តើមឲ្យមានបទល្មើសនោះទេ។ មានការជំរុញឲ្យមានបទប្បញ្ញត្តិនេះ ក្នុងអំឡុងការជជែកពិភាក្សាក្នុងរដ្ឋសភា ដែលថាបញ្ញត្តិក្នុងក្រមព្រហ្មទណ្ឌនឹងអាចយកមកអនុវត្តបានក្នុងករណីបែបនេះ។ ខណៈពេលដែល ក្រមព្រហ្មទណ្ឌ បានរួមបញ្ចូលនូវបញ្ញត្តិទាក់ទងនឹងការដាក់ទោសចំពោះសហចារី អ្នកផ្តើមគំនិត និងអ្នកសមគំនិត[54] ប៉ុន្តែនៅមានភាពមិនច្បាស់លាស់ថាហេតុអ្វីបានជាបញ្ញត្តិទាំងនេះមិនបានបញ្ចូលទៅក្នុងច្បាប់គ្រប់គ្រងអាស៊ីដខ្លាំង ដើម្បីឆ្លុះបញ្ចាំងនូវភាពស្មុគស្មាញនៃបទល្មើសដែលពាក់ព័ន្ធនឹងការប្រើប្រាស់អាស៊ីដខ្លាំង។ ឧទាហរណ៍ ក្រមព្រហ្មទណ្ឌបានចែងថាអ្នកផ្តើមគំនិតនឹងអាចត្រូវផ្តន្ទាទោសប្រសិនបើអំពើនោះ ត្រូវបានប្រព្រឹត្ត ឬមានការប៉ុនប៉ង។ ដូច្នេះ គឺមានភាពមិនច្បាស់ថាតើការប៉ុនប៉ងត្រូវបានកម្រិតនៅត្រឹមណា តើនេះមានន័យថាគឺនៅពេលដែលមានការជះអាស៊ីដ ឬក៏គ្រាន់តែការទិញអាស៊ីដសម្រាប់ប្រព្រឹត្តបទល្មើស? ការមិនបញ្ចូលចំណុចដែលពាក់ព័ន្ធនឹងអំពើហិង្សាដោយអាស៊ីដទាំងនេះក្នុងវិសាលភាពច្បាប់គ្រប់គ្រងអាស៊ីដខ្លាំងឲ្យជាក់លាក់ គឺជាបរាជ័យក្នុងការស្វែងរកយុត្តិធម៌ឲ្យបានសមស្របចំពោះជនរងគ្រោះដោយអាស៊ីដ។

ច្បាប់គ្រប់គ្រងអាស៊ីដខ្លាំង មិនបានបែងចែកប្រភេទរងគ្រោះ។ ដូច្នេះ ជនល្មើសដែលវាយប្រហារដោយអាស៊ីដមកលើនីតិជន នឹងត្រូវផ្តន្ទាទោសដូចនឹងជនល្មើសដែលវាយប្រហារមកលើអនីតិជនដែរ។ យើងជឿថាការ

[53] សូមអានមាត្រា១៥ ១៨ ២២ និង២៤ នៃច្បាប់គ្រប់គ្រងអាស៊ីដខ្លាំង។
[54] សូមអានមាត្រា២៦ ២៨ និង២៩នៃក្រមព្រហ្មទណ្ឌ ។

បែងចែកប្រភេទជនរងគ្រោះ ក្នុងពេលពិចារណាផ្តន្ទាទោសគឺមានសារៈសំខាន់ណាស់។ ការវាយប្រហារដោយអាស៊ីដមកលើអនីតិជន អាចបង្កឲ្យមានផលប៉ះពាល់ធ្ងន់ធ្ងរជាង គឺពួកគេមិនត្រឹមតែត្រូវការការព្យាបាលដោយយកចិត្តទុកដាក់យ៉ាងជាប់លាប់ រហូតពេញមួយជីវិតរបស់ពួកគេ ទោះបីជានីតិជនក៏ត្រូវការការព្យាបាលបែបនេះក៏ដោយ ប៉ុន្តែការវាយប្រហារនេះអាចប៉ះពាល់ដល់ការរីកលូតលាស់ និងវិវឌ្ឍន៍ផ្នែករាងកាយ និងផ្លូវចិត្តរបស់កុមារទាំងអស់នោះ។

<u>**អនុសាសន៍**</u> ៖

- គួរតែធ្វើវិសោធនកម្មលើច្បាប់គ្រប់គ្រងអាស៊ីដខ្លាំង ដើម្បីចែងពីការផ្តន្ទាទោសធ្ងន់ធ្ងរជាងនេះ ចំពោះអំពើហិង្សាដោយចេតនាដែលបណ្តាលឲ្យពិការ ដើម្បីឆ្លុះបញ្ចាំងពីកម្រិតរបួសផ្នែករាងកាយ និងផ្លូវចិត្តដែលជនរងគ្រោះនៃការវាយប្រហារនេះត្រូវទទួលរងពេញមួយជីវិត។
- ច្បាប់គ្រប់គ្រងអាស៊ីដខ្លាំង គួរតែផ្តន្ទាទោសយ៉ាងធ្ងន់ធ្ងរដល់ជនល្មើស ក្នុងករណីជនរងគ្រោះជាអនីតិជន។
- គួរតែមានការព្រាងនូវសេចក្តីណែនាំស្តីពីការអនុវត្តច្បាប់គ្រប់គ្រងអាស៊ីដខ្លាំង ដោយក្រសួងមហាផ្ទៃ ដែលរួមមានទាំងការពន្យល់ថា សហចារី អ្នកផ្តើមគំនិត និងអ្នកសមគំនិតនឹងត្រូវទទួលការផ្តន្ទាទោសដូចគ្នានឹងអ្នកប្រព្រឹត្ត និងដើម្បីពន្យល់ជាលម្អិតថា តើការ "ប៉ុនប៉ង" ក្នុងការប្រព្រឹត្តបទល្មើសមានន័យដូចម្តេច ដើម្បីអាចផ្តន្ទាទោសមកលើអ្នកផ្តើមគំនិតឲ្យមានអំពើហិង្សាដោយអាស៊ីដ។
- ចំពោះនីតិបុគ្គល ច្បាប់គ្រប់គ្រងអាស៊ីដខ្លាំង គួរតែបញ្ចូលបញ្ញត្តិដោយបើកចំហរដែលអាចព្យួរអាជ្ញាប័ណ្ណរបស់នីតិបុគ្គលដែល ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌពាក់ព័ន្ធនឹងអំពើមនុស្សឃាតដោយអចេតនា ឬអំពើហិង្សាដោយអចេតនា។
- បន្ថែមទៅលើការចាត់ទុកការវាយប្រហារដោយអាស៊ីដជាបទល្មើស រដ្ឋាភិបាល និងក្រសួងមហាផ្ទៃ គួរតែធានាថាមានកម្លាំងនគរបាលដែលទទួលបានការបណ្តុះបណ្តាលត្រឹមត្រូវ ដើម្បីធ្វើការស៊ើបអង្កេតឲ្យបានដិតដល់ចំពោះករណីអំពើហិង្សាដោយអាស៊ីដ។

## ៣.២ ការគ្រប់គ្រងការលក់ ចែកចាយ និងកាន់កាប់អាស៊ីដខ្លាំង

មានការលើកឡើងថាការកើនឡើងនៃការប្រើប្រាស់ និងគ្មានច្បាប់គ្រប់គ្រង ហើយដោយសារតែនៅកម្ពុជាសារធាតុនេះមានតម្លៃទាប ធ្វើឲ្យអាស៊ីដក្លាយជាជម្រើសអាវុធមួយដើម្បីដោះស្រាយជម្លោះ។[55] ការស្រាវជ្រាវក៏បានបង្ហាញពីទំនាក់ទំនងរវាងករណីវាយប្រហារ នឹងភាពដែលងាយស្រួលរកបានរបស់អាស៊ីដផងដែរ។[56] ឧទាហរណ៍របាយការណ៍អាស៊ីដរកឃើញថា ខេត្តកំពង់ចាម ដែលអាស៊ីដងាយស្រួលរកប្រើប្រាស់បំផុត ព្រោះមានការប្រើប្រាស់ច្រើនដើម្បីបង្កកកៅស៊ូ ធ្វើឲ្យអត្រាបទល្មើសអាស៊ីដមានចំនួនច្រើនជាងខេត្តដទៃទៀត។[57] ច្បាប់ដ៏មានប្រសិទ្ធភាព និងការគ្រប់គ្រងដ៏តឹងតែង លើការប្រើប្រាស់អាស៊ីដ ដែលអាចគ្របដណ្តប់លើជីវភាពអាស៊ីដទាំងអស់ មានសារៈសំខាន់ខ្លាំងណាស់ដើម្បីកាត់បន្ថយករណីវាយប្រហារដោយអាស៊ីដ ជាពិសេសក្នុងតំបន់ទាំងនេះ។

មាត្រា៣ នៃច្បាប់គ្រប់គ្រងអាស៊ីដខ្លាំង ចែងថាច្បាប់នេះអនុវត្តបានចំពោះការនាំចូល ការផលិត ការដឹកជញ្ជូន ការចែកចាយ ការទិញការលក់ ការរក្សាទុក និងការប្រើប្រាស់អាស៊ីដគ្រប់ប្រភេទ ទោះបីជាមិនបានចែងពីការគ្រប់គ្រងសំណល់អាស៊ីដ ដែលអាចនឹងត្រូវបានប្រើប្រាស់ក្នុងគោលបំណងប្រព្រឹត្តអំពើហិង្សាដោយអាស៊ីដ និងមិនបានចែងពីការបិទផ្លាកសម្គាល់។ បើយោងតាមរបាយការណ៍ក្នុងខែឧសភា ឆ្នាំ២០១១ មានបុរសពីរនាក់ក្នុងខេត្តកំពតបានច្រលំផឹកទឹកអាស៊ីដ ដូច្នេះការដាក់ស្លាកសញ្ញា គឺមានសារៈសំខាន់ក្នុងការការពាររបួសដោយអាស៊ីដផ្សេងៗ។[58]

---

55 សូមអាន អ.ជ.ជ.ក.អ កំណត់សម្គាល់លេខ៦ ទំព័រទី៨។
56 ដូចខាងលើ។
57 ដូចខាងលើ ទំព័រទី៨។
58 ហ្វៀន គ្រីនវូដ "អំពើហិង្សាដោយអាស៊ីដ ៖ ជាបណ្តាសារមួយក្នុងប្រទេសកម្ពុជាដែរ" ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១១ អាចអានបាន ៖ http://thefastertimes.com/cambodia/2011/06/16/acid-attacks-a-cambodian-curse-too/ ។

ច្បាប់គ្រប់គ្រងអាស៊ីដខ្លាំង ក៏បានបន្តចែងពី ក្របខណ្ឌនៃរបបគ្រប់គ្រងដែលមានលក្ខណៈធូររលុង ដោយចែងថាប្រសិនបើរូបវន្តបុគ្គល ឬនីតិបុគ្គលមិនមានអាជ្ញាបណ្ណ ឬលិខិតដែលផ្តល់ដោយក្រសួងពាក់ព័ន្ធ ឬក៏អាជ្ញាធរនៃស្ថាប័នរដ្ឋាភិបាលដែលទទួលខុសត្រូវ ពួកគេនឹងមិនត្រូវបានអនុញ្ញាតឲ្យនាំចូល ដឹកជញ្ជូន ចែកចាយ ទិញ លក់ រក្សាទុក ឬក៏ប្រើប្រាស់អាស៊ីដនោះទេ។[59] ច្បាប់គ្រប់គ្រងអាស៊ីដខ្លាំង បានចែងជាពិសេសស្តីពីការផ្តល់អាជ្ញាប័ណ្ណ ដើម្បីនាំចូល នាំចេញ ផលិត ឬកែច្នៃអាស៊ីដខ្លាំង គឺស្ថិតនៅក្រោមសមត្ថកិច្ចនៃ ក.ឌ.រ.ថ។[60] ការផ្តល់អាជ្ញាប័ណ្ណ លិខិតអនុញ្ញាតសម្រាប់អាស៊ីដខ្លាំងដែល ប្រើប្រាស់ក្នុងវិស័យសុខាភិបាល គឺត្រូវស្ថិតក្រោមសមត្ថកិច្ចរបស់ក្រសួងសុខាភិបាល។[61] ទម្រង់ និងលក្ខខណ្ឌនៃការលក់ ការទិញ ការរក្សាទុក ការចែកចាយ ការវេចខ្ចប់ ការកាន់កាប់ និងការប្រើប្រាស់អាស៊ីដខ្លាំងគ្រប់ប្រភេទនឹងមានចែងដោយអនុក្រឹត្យ។ ប៉ុន្តែ ច្បាប់មិនបានបញ្ជាក់ឲ្យជាក់ច្បាស់ថាតើភ្នាក់ងាររដ្ឋាភិបាលមួយណាដែលទទួលខុសត្រូវចំពោះការផ្តល់អាជ្ញាប័ណ្ណពាក់ព័ន្ធនឹងការដឹកជញ្ជូន ការចែកចាយ ការទិញ ការលក់ ការរក្សាទុក និងការប្រើប្រាស់អាស៊ីដ ដែលមិនស្ថិតក្រោមសមត្ថកិច្ចរបស់ ក.ឌ.រ.ថ ឬក្រសួងសុខាភិបាល។ ពុំមានព័ត៌មានបន្ថែមស្តីពីអនុក្រឹត្យ និង/ឬការអនុម័តអនុក្រឹត្យទេ។ បន្ទាប់ពីច្បាប់គ្រប់គ្រងអាស៊ីដខ្លាំងចូលជាធរមាន រូបវន្តបុគ្គល ឬនីតិបុគ្គលដែលកំពុងធ្វើអាជីវកម្មពាក់ព័ន្ធនឹងអាស៊ីដខ្លាំងដោយគ្មានលិខិតអនុញ្ញាត ត្រូវតម្រូវឲ្យបំពេញបែបបទសុំលិខិតអនុញ្ញាតដើម្បីធ្វើអាជីវកម្មឲ្យស្របច្បាប់។[62] ប៉ុន្តែ ច្បាប់គ្រប់គ្រងអាស៊ីដខ្លាំង ខកខានមិនបានចែងថាការស្នើសុំនេះត្រូវធ្វើឡើងនៅពេលណានោះទេ និងដោយសារតែបញ្ញត្តក្នុងមាត្រា១៤ ដែលពាក់ព័ន្ធនឹងទោសប្បញ្ញត្តិចំពោះការប្រើប្រាស់អាស៊ីដខ្លាំងដោយគ្មានអាជ្ញាប័ណ្ណ ឬលិខិតអនុញ្ញាត (សូមអានខាងក្រោម) នឹងមិនទាន់ចូលជាធរមាន រហូតទាល់តែមានអនុក្រឹត្យត្រូវបានអនុម័ត នេះគឺជាចំណុចដែលខ្វះចន្លោះក្នុងច្បាប់។

ដោយសារតែគ្មានព័ត៌មានលម្អិតបន្ថែមស្តីពីអនុក្រឹត្យ យើងក៏មិនអាចដឹងថា តើមានតម្រូវការស្របច្បាប់បែបណាខ្លះដែលគួរតែគោរពតាម សម្រាប់បុគ្គលដែលមានបំណងចង់ស្នើសុំ ឬបន្តអាជ្ញាប័ណ្ណ។ ចំពោះលក្ខខណ្ឌនៃអាជ្ញាប័ណ្ណ ច្បាប់គ្រប់គ្រងអាស៊ីដខ្លាំង គ្រាន់តែបានចែងថា បុគ្គលដែលមានច្បាប់អនុញ្ញាត ត្រូវតែប្រើប្រាស់អាស៊ីដឲ្យចំគោលដៅ និងត្រូវគោរពបទដ្ឋានបច្ចេកទេសក្នុងកម្រិតសុវត្ថិភាពខ្ពស់បំផុត។[63] ប៉ុន្តែមិនច្បាស់ថា តើបទដ្ឋានបច្ចេកទេសនេះគឺជាអ្វី និងសំដៅលើអ្វី ហើយតើចំណុចទាំងនេះនឹងរួមមានទាំងការអនុលោមតាម បទដ្ឋានសុខភាព និងសុវត្ថិភាពផ្នែកវិជ្ជាជីវៈដែរឬមួយយ៉ាងណា ប៉ុន្តែយ៉ាងហោចណាស់គួរតែមានបទដ្ឋានឧស្សាហកម្ម ដែលធ្វើសេចក្តីព្រាងដោយអ្នកជំនាញ។ ការអនុលោមតាមបទដ្ឋានសុខភាព និងសុវត្ថិភាពផ្នែកវិជ្ជាជីវៈ គឺជាធាតុផ្សំដ៏សំខាន់មួយក្នុងច្បាប់។[64] ការផ្តល់ និងរក្សាអាជ្ញាប័ណ្ណ គួរតែផ្អែកលើ និងគោរពតាមបទដ្ឋានទាំងនេះ។ ច្បាប់គ្រប់គ្រងអាស៊ីដខ្លាំង ក៏មិនបានចែងពីរយៈពេលនៃការផ្តល់អាជ្ញាប័ណ្ណ និងមិនដឹងពីលក្ខខណ្ឌនៃការកាន់កាប់ និងរក្សាទុកអាជ្ញាប័ណ្ណទាំងនេះដែរ យើងសន្មត់ថាចំណុចទាំងនេះនឹងមានក្នុងអនុក្រឹត្យ។ ពិតជាមានសារៈសំខាន់ណាស់ដែលរបបគ្រប់គ្រងបញ្ចូលនូវលក្ខខណ្ឌនៃអាជ្ញាប័ណ្ណ ដែលកំណត់ថាអាជ្ញាប័ណ្ណនឹងត្រូវបានផ្តល់ជូនក្នុងរយៈពេលមួយជាក់លាក់ និងតម្រូវឲ្យមានការស្នើសុំបន្តអាជ្ញាប័ណ្ណ ហើយនឹងអាចបន្តបានបន្ទាប់ពីមានដំណើរការត្រួតពិនិត្យដែលបង្ហាញថាអ្នកកាន់កាប់អាជ្ញាប័ណ្ណបានគោរពតាមលក្ខខណ្ឌពាក់ព័ន្ធនៃអាជ្ញាប័ណ្ណ រួមទាំងគោរពយ៉ាងខ្ជាប់ខ្ជួនតាមបទដ្ឋានបច្ចេកទេស និងសុវត្ថិភាព។ សកម្មភាពនេះគឺមានសារៈសំខាន់ក្នុងការគ្រប់គ្រងលើសកម្មភាពពុករលួយ។ របបផ្តល់អាជ្ញាប័ណ្ណគួរតែធានាថាអាជ្ញាប័ណ្ណមិនអាចផ្ទេរ ឬលក់ពីអាជីវកម្មមួយ ទៅអាជីវកម្មមួយទៀត ឬពីបុគ្គលមួយទៅបុគ្គលមួយទៀតនោះទេ។ រាល់ការផ្លាស់ប្តូរការគ្រប់គ្រង ឬម្ចាស់កម្មសិទ្ធិគឺត្រូវឆ្លងកាត់ដំណាក់កាលស្នើសុំអាជ្ញាប័ណ្ណថ្មី។ លើសពីនោះ ការដែលច្បាប់តម្រូវឲ្យមានការរក្សាទុកនូវបញ្ជីឈ្មោះរបស់អ្នកទិញ គឺពិតជាមានសារៈសំខាន់ណាស់។ ចំណុចនេះអាចជាប្រភពដ៏មានតម្លៃសម្រាប់នគរបាលដើម្បីធ្វើការស៊ើបអង្កេត។

---

59 សូមអានមាត្រា៥ និង ៨ នៃច្បាប់គ្រប់គ្រងអាស៊ីដខ្លាំង។
60 សូមអានមាត្រា៦ នៃច្បាប់គ្រប់គ្រងអាស៊ីដខ្លាំង។
61 ដូចខាងលើ។
62 សូមអានមាត្រា២៦ នៃច្បាប់គ្រប់គ្រងអាស៊ីដខ្លាំង។
63 សូមអានមាត្រា៨ នៃច្បាប់គ្រប់គ្រងអាស៊ីដខ្លាំង។
64 សូមអាន ម.ស.ម.ក និង អ.ជ.ជ.ក.អ កំណត់សម្គាល់លេខ៦ ទំព័រទី១០។

ស្របពេលដែលព័ត៌មានលម្អិតនៃរបបគ្រប់គ្រងនៅមិនទាន់គ្រប់គ្រាន់ ច្បាប់គ្រប់គ្រងអាស៊ីដខ្លាំង បានចែងពីបញ្ញត្តិវិជ្ជមានមួយចំនួនស្តីពីការផ្តន្ទាទោសចំពោះការគ្មានអាជ្ញាប័ណ្ណ។ ការផ្តន្ទាទោស ត្រូវកំណត់ដោយផ្អែកលើបរិមាណអាស៊ីដ និងខុសគ្នាដោយផ្អែកថាតើអាស៊ីដខ្លាំងនោះកាន់កាប់ដោយរូបវន្តបុគ្គល ឬនីតិបុគ្គល។[65] ច្បាប់គ្រប់គ្រងអាស៊ីដខ្លាំង ក្នុងមាត្រា១៤ បានបញ្ចូលការផ្តន្ទាទោសដោយពិន័យជាប្រាក់ និងក្នុងករណីខ្លះទៀតត្រូវដាក់ពន្ធនាគារសម្រាប់ប្រតិបត្តិការដែលគ្មានអាជ្ញាប័ណ្ណ។ រូបវន្តបុគ្គលដែលគ្មានអាជ្ញាប័ណ្ណ ឬលិខិតអនុញ្ញាត កាន់កាប់អាស៊ីដខ្លាំងមានទម្ងន់ក្រោម ៥០០ក្រាម ត្រូវពិន័យជាប្រាក់ពី ៥០០,០០០រៀល ទៅ ១,៥០០,០០០រៀល និងការរឹបអូសអាស៊ីដខ្លាំង ខណៈពេលដែលនីតិបុគ្គលនឹងត្រូវពិន័យជាប្រាក់ពី ៥,០០០,០០០រៀល ទៅ ១០,០០០,០០០រៀល។ ចំពោះអាស៊ីដដែលមានទម្ងន់លើសពី ៥០០ក្រាម រូបវន្តបុគ្គលនឹងត្រូវបានផ្តន្ទាទោសឲ្យជាប់ពន្ធនាគារចាប់ពី ៣ ខែទៅ២ឆ្នាំ និងពិន័យជាប្រាក់ពី ២,០០០,០០០រៀល ទៅ ១០,០០០,០០០រៀល និងត្រូវរឹបអូសអាស៊ីដខ្លាំង ចំណែកនីតិបុគ្គលនឹងត្រូវពិន័យជាប្រាក់ពី ១០,០០០,០០០រៀល ទៅ ៥០,០០០,០០០រៀល។ នីតិបុគ្គលអាចនឹងត្រូវទទួលការផ្តន្ទាទោសបន្ថែមតាមមាត្រា១៦៨ នៃក្រមព្រហ្មទណ្ឌ ដោយសារការធ្វើប្រតិបត្តិការដោយគ្មានអាជ្ញាប័ណ្ណ ឬលិខិតអនុញ្ញាត ដែលរួមមានការរំលាយ និងការហាមឃាត់ពីការធ្វើសកម្មភាពមួយក្នុងចំណោមសកម្មភាពជាច្រើន។ ជាពិសេស យោងតាមមាត្រា២៦ នៃច្បាប់គ្រប់គ្រងអាស៊ីដខ្លាំង បញ្ញត្តិទាំងនេះ នឹងមិនអាចចូលជាធរមានរហូតទាល់តែមានការអនុម័តរបស់អនុក្រឹត្យ។ ដូច្នេះ ពិតជាមានសារៈសំខាន់ខ្លាំងណាស់ដែលអនុក្រឹត្យត្រូវបានព្រាង និងចូលជាធរមានឲ្យបានលឿនបំផុតតាមដែលអាចធ្វើទៅបាន ដើម្បីធានាថាគ្រប់វិស័យក្នុងសង្គម និងសេដ្ឋកិច្ចដែលពាក់ព័ន្ធនឹងអាស៊ីដត្រូវបានគ្រប់គ្រង និងត្រួតពិនិត្យបានយ៉ាងត្រឹមត្រូវដើម្បីការពារអំពើហិង្សាដោយអាស៊ីដ។

នៅពេលចូលមកដល់រឿងការអនុវត្តនៃរបបគ្រប់គ្រងនេះ ដោយសារតែសេចក្តីព្រាងច្បាប់អាស៊ីដដែលមិនបានចែងពីក្រុមស៊ើបអង្កេតដ៏ជាក់លាក់មួយ ដើម្បីពិនិត្យលើអាជ្ញាប័ណ្ណ និងលិខិតអនុញ្ញាត ធ្វើឲ្យមានភាពស្រពេចស្រពិលថាតើបញ្ញត្តិនេះនឹងត្រូវបានអនុវត្តដោយរបៀបណា។ បទពិសោធន៍ក្នុងប្រទេសបង់ក្លាដែស បានបង្ហាញថាដោយគ្មានការគ្រប់គ្រង និងការអនុវត្តច្បាប់ឲ្យបានច្បាស់លាស់ ប្រព័ន្ធនៃការគ្រប់គ្រងនឹងគ្មាននូវប្រសិទ្ធភាពក្នុងការការពារ។[66] មានការកត់សម្គាល់ថា ទោះបីជាមានប្រព័ន្ធនៃការគ្រប់គ្រង "ការលក់ និងការចែកចាយ ត្រូវបានគ្រប់គ្រងដោយគ្មានប្រសិទ្ធភាព គ្មានការអនុវត្ត និងគ្មានការតាមដាន"។[67] ដូច្នេះ បន្ថែមទៅលើការមានច្បាប់គ្រប់គ្រងអាស៊ីដខ្លាំង និងអនុក្រឹត្យ ក្រសួងមហាផ្ទៃត្រូវតែធ្វើការដើម្បីបង្កើតនូវមធ្យោបាយក្នុងការតាមដាននូវដំណើរការផ្សេងៗនៃការផលិត ការនាំចូល ការដឹកជញ្ជូន ការលក់ និងការប្រើប្រាស់ ដើម្បីធានានូវការអនុវត្តយ៉ាងមានប្រសិទ្ធភាព។ ប្រព័ន្ធនេះគួរតែរាប់បញ្ចូលនូវការត្រួតពិនិត្យ និងការស៊ើបអង្កេតនៅនឹងកន្លែងផងដែរ។

<u>**អនុសាសន៍**</u> ៖

- អនុក្រឹត្យស្តីពីរបបផ្តល់អាជ្ញាប័ណ្ណ សម្រាប់អ្នកផលិត ដឹកជញ្ជូនចែកចាយ ទិញ លក់ រក្សាទុក និងប្រើប្រាស់អាស៊ីដខ្លាំង គួរតែចែករំលែកទៅដល់អ្នកពាក់ព័ន្ធ សង្គមស៊ីវិល និងអ្នកជំនាញមុនពេលដាក់ឲ្យរដ្ឋសភាអនុម័ត ដើម្បីធានាថាប្រព័ន្ធគ្រប់គ្រងនេះមានប្រសិទ្ធភាពក្នុងការការពារ។
- របបផ្តល់អាជ្ញាប័ណ្ណគួរតែបញ្ចូលនូវលក្ខខណ្ឌច្បាស់លាស់ សម្រាប់ការកាន់កាប់អាជ្ញាប័ណ្ណឬលិខិតអនុញ្ញាត ហើយគួរតែចែងពីលក្ខខណ្ឌដូចខាងក្រោម
  - o លទ្ធភាពក្នុងការទទួលបានអាជ្ញាប័ណ្ណ ត្រូវផ្អែកលើការអនុលោមតាមបទដ្ឋានឧស្សាហកម្ម ដែលត្រូវកំណត់ដោយអ្នកជំនាញ ដូចជាបទដ្ឋានសុខភាព និងសុវត្ថិភាពផ្នែកវិជ្ជាជីវៈ ការរក្សាបញ្ជីឈ្មោះរបស់អ្នកទិញ អ្នកផ្គត់ផ្គង់ ជាដើម។

[65] សូមអានមាត្រា១៤ នៃសេចក្តីព្រាងច្បាប់អាស៊ីដ។
[66] សូមអាន ម.ស.ម.ក និង អ.ជ.ជ.ក.អ កំណត់សម្គាល់លេខ៦ ទំព័រទី១១។
[67] ម.ជ.អ ប្រទេសប៉ាគីស្ថាន របាយការណ៍ស្ថានភាព ទំព័រទី៨ ។

- o អាជ្ញាប័ណ្ណគួរតែមានរយៈពេលកំណត់ច្បាស់លាស់ ហើយតម្រូវឲ្យដាក់ពាក្យស្នើសុំបន្ត។ ចំណុចនេះអាចធានាថានឹងមានការត្រួតពិនិត្យជាទៀងទាត់ចំពោះអ្នកកាន់កាប់អាជ្ញាប័ណ្ណ និងការថៃរក្សាបញ្ជីឈ្មោះរបស់ពួកគេ។
- o ក្នុងករណីដែលបុគ្គល ឬនីតិបុគ្គលរំលោភលក្ខខណ្ឌនៃអាជ្ញាប័ណ្ណ ត្រូវតែមានការព្យួរអាជ្ញាប័ណ្ណភ្លាមៗ ហើយអាចចុះបញ្ជីជាថ្មីម្តងទៀត លុះត្រាតែបន្ទាប់ពីមាន "ការស្តារនីតិសម្បទា" និងការស៊ើបអង្កេតបន្ថែមដោយអាជ្ញាធរពាក់ព័ន្ធ។

- ក្រសួងមហាផ្ទៃគួរតែបង្កើត ក្រុមអ្នកត្រួតពិនិត្យដែលបានចាត់តាំងដើម្បីតាមដាន ចំពោះការដាក់ពាក្យស្នើសុំ និងការអនុលោមតាមលក្ខខណ្ឌ ដើម្បីធានានូវប្រសិទ្ធភាពនៃរបបប្រព័ន្ធគ្រប់គ្រង។ ការតាមដានគួរតែមានក្នុងទម្រង់ជាការត្រួតពិនិត្យដោយចៃដន្យ ដោយមានការដាក់ទោសទណ្ឌមកលើអ្នកដែលរំលោភបំពានលើលក្ខខណ្ឌទាំងនោះផងដែរ។

## ៣.៣ ការកាត់ទោស និងផ្តន្ទាទោស

តាមការកត់សម្គាល់ខាងលើ ច្បាប់គ្រប់គ្រងអាស៊ីដខ្លាំង មានការផ្តន្ទាទោសដ៏តឹងរ៉ឹងចំពោះការដាក់ពន្ធនាគារ ឬដាក់ពន្ធនាគារពេញមួយជីវិត សម្រាប់ជនប្រព្រឹត្តបទល្មើស ដែលធ្វើឲ្យជនរងគ្រោះពិការអស់មួយជីវិត ដែលមានចែងក្នុងក្រមព្រហ្មទណ្ឌបច្ចុប្បន្ន និងដែលអាចឆ្លុះបញ្ចាំងពីលក្ខណៈនៃបទល្មើសបានយ៉ាងច្បាស់ជាង។ ក្នុងករណីដែលបទល្មើសអាចបណ្តាលឲ្យជនរងគ្រោះត្រូវស្លាប់ និងមានការរៀបចំគម្រោងទុកជាមុន ជនល្មើសនឹងត្រូវផ្តន្ទាទោសឲ្យជាប់ពន្ធនាគារអស់មួយជីវិត។ បច្ចុប្បន្ន ការផ្តន្ទាទោស ក្នុងក្រមព្រហ្មទណ្ឌចំពោះអំពើបង្ករបួសស្នាមដោយចេតនា មានរយៈពេលចាប់ពី ២ទៅ៥ឆ្នាំ ដែលនេះអាចធ្វើឲ្យជនរងគ្រោះក្លាយជាគោលដៅនៃការសងសឹក បន្ទាប់ពីជនល្មើសចេញពីពន្ធនាគារមកវិញ។ មានការសង្ឃឹមថាការផ្តន្ទាទោសឲ្យជាប់ពន្ធនាគារក្នុងរយៈពេលវែង មិនត្រឹមតែគ្រប់គ្រាន់ដើម្បីជាការបន្លាច និងដាក់ទណ្ឌកម្មចំពោះអ្នកប្រព្រឹត្តបទល្មើសនោះទេ ប៉ុន្តែក៏អាចជំរុញឲ្យជនរងគ្រោះស្វែងរកការសងជំងឺចិត្តតាមផ្លូវច្បាប់ ដោយមិនខ្លាចការសងសឹកផងដែរ។ ដូចបានពិភាក្សាខាងលើ ការខកខានមិនបានចាត់ទុកថាសកម្មភាពរបស់អ្នកផ្តើមគំនិត សហចារី និងអ្នកសមគំនិត ជាបទល្មើស និងផ្តន្ទាទោសចំពោះទង្វើទាំងនេះទៅក្នុងច្បាប់គ្រប់គ្រងអាស៊ីដខ្លាំង នៅតែជាចំណុចគួរឲ្យព្រួយបារម្ភ។

ច្បាប់គ្រប់គ្រងអាស៊ីដខ្លាំង ក៏ខកខានមិនបានបែងចែកប្រភេទជនល្មើសផងដែរ។ ឧទាហរណ៍ ជនល្មើសដែលវាយប្រហារមកលើនីតិជន នឹងទទួលការផ្តន្ទាទោសដូចជនល្មើសដែលវាយប្រហារមកលើអនីតិជនដែរ។ ដូចបានរៀបរាប់ខាងលើ យើងជឿជាក់ថាការបែងចែកជនរងគ្រោះក្នុងពេលពិចារណាសម្រេចទោសគឺចាំបាច់ណាស់។ ប្រហាក់ប្រហែលគ្នាដែរ យើងគិតថាច្បាប់គ្រប់គ្រងអាស៊ីដខ្លាំង គួរតែបែងចែកប្រភេទជនល្មើស ចំពោះជនល្មើសដែលជាអនីតិជន ការផ្តន្ទាទោសគួរតែមិនសូវធ្ងន់ធ្ងរ។

ច្បាប់គ្រប់គ្រងអាស៊ីដខ្លាំង ក៏បានបញ្ចូលការផ្តន្ទាទោសមកលើរូបវន្តបុគ្គល និងនីតិបុគ្គល ដែលមាន ឬគ្មានអាជ្ញាប័ណ្ណ ឬការអនុញ្ញាត ហើយបានធ្វេសប្រហែស ឬមិនប្រុងប្រយ័ត្នក្នុងការគ្រប់គ្រងប្រតិបត្តិការរបស់ពួកគេបណ្តាលឲ្យមានរបួស ពិការភាព ឬការស្លាប់របស់អ្នកដទៃផងដែរ។ ការផ្តន្ទាទោសទាំងនេះ រួមមាន ការដាក់ពន្ធនាគារចំពោះរូបវន្តបុគ្គល និងពិន័យជាប្រាក់ទាំងរូបវន្តបុគ្គល និងនីតិបុគ្គល។ ប៉ុន្តែ បញ្ញត្តិទាំងនេះមិនបានដាក់ការលុបចោល ឬព្យួរអាជ្ញាប័ណ្ណ ទៅក្នុងផ្នែកមួយនៃការផ្តន្ទាទោសនោះទេ។ បញ្ញត្តិនេះគឺមានការចាំបាច់ ដើម្បីការពារមិនឲ្យជនល្មើសបន្តសកម្មភាពរបស់ពួកគេ ដោយគ្រាន់តែបង់ប្រាក់ពិន័យ ឬទទួលទោសជាប់ពន្ធនាគារនោះទេប៉ុន្តែតម្រូវឲ្យមានការត្រួតពិនិត្យយ៉ាងច្បាស់លាស់ដោយអាជ្ញាធរពាក់ព័ន្ធ។ ចំពោះបញ្ញត្តិពាក់ព័ន្ធនឹងការផ្តន្ទាទោសចំពោះការគ្មាន ឬការប្រើប្រាស់អាជ្ញាប័ណ្ណដោយមិនត្រឹមត្រូវ ធ្វើឲ្យមានការព្រួយបារម្ភថា ច្បាប់ដែលកំពុងស្ថិតក្នុងសេចក្តីព្រាងបច្ចុប្បន្នមិនបានបង្កើតក្រុមស៊ើបអង្កេតដើម្បីធានាថានឹងមានការអនុវត្តន៍របបច្បាប់នេះបានត្រឹមត្រូវនោះទេ យើងគួរតែចងចាំពីបទពិសោធន៍របស់បង់ក្លាដែស ដែលបានបញ្ជាក់ក្នុងផ្នែកទីពីរនៃរបាយការណ៍នេះ ។ អវត្តមាននៃរបបនេះ

ត្រូវបានចាត់ទុកថាជាការទទួលខុសត្រូវដ៏ធំ ចំពោះកង្វះខាតនៃរបបគ្រប់គ្រងនៅបង់ក្លាដែស។ ត្រូវតែមានការធានាថាច្បាប់គ្រប់គ្រងអាស៊ីដខ្លាំងនឹងបង្កើតក្រុមស៊ើបអង្កេតបែបនេះ។

ខុសពីច្បាប់នៅបង់ក្លាដែស ច្បាប់គ្រប់គ្រងអាស៊ីដខ្លាំងនេះ ពុំមានចែងពីបញ្ញត្តិទាក់ទងនឹងនីតិវិធីសម្រាប់ការស៊ើបអង្កេត និងកាត់ទោសបទល្មើសអាស៊ីដនោះទេ។ ប៉ុន្តែ ដើម្បីឲ្យមានការកាត់ទោសបានយ៉ាងមានប្រសិទ្ធភាព អ្វីដែលសំខាន់ គឺពាក្យបណ្តឹងនៃអំពើហិង្សាដោយអាស៊ីដ ត្រូវបានស៊ើបអង្កេតយ៉ាងឆាប់រហ័ស និងត្រឹមត្រូវ ហើយដូច្នេះច្បាប់គ្រប់គ្រងអាស៊ីដខ្លាំងគួរតែបញ្ចូលបញ្ញត្តិស្តីពីរយៈពេលសមរម្យមួយ សម្រាប់ធ្វើការស៊ើបអង្កេត និងនាំយកករណីទាំងនេះមកធ្វើការជំនុំជម្រះ។ ដើម្បីធ្វើបែបនោះបាន កម្លាំងនគរបាលគួរតែត្រូវបានការបណ្តុះបណ្តាលឲ្យបានគ្រប់គ្រាន់ស្តីពីការស៊ើបអង្កេតករណីអំពើហិង្សាដោយអាស៊ីដ ការប្រមូលភស្តុតាង និងការគាំពារជនរងគ្រោះ និងសាក្សីផងដែរ។

<u>**អនុសាសន៍**</u> ៖

- គួរតែធ្វើវិសោធនកម្មច្បាប់គ្រប់គ្រងអាស៊ីដខ្លាំង ដើម្បីបែងចែកប្រភេទជនល្មើស និងប្រភេទជនរងគ្រោះ។
- គួរតែធ្វើវិសោធនកម្មច្បាប់គ្រប់គ្រងអាស៊ីដខ្លាំង ដើម្បីចាត់ទុកសកម្មភាពរបស់សហចារី អ្នកផ្តើមគំនិត និងអ្នកសមគំនិត ជាបទល្មើស និងផ្តន្ទាទោសឲ្យដូចនឹងជនល្មើសដែរ។
- ក្រសួងមហាផ្ទៃ គួរតែធានាថាកម្លាំងនគរបាលនឹងទទួលបានការបណ្តុះបណ្តាលយ៉ាងត្រឹមត្រូវដើម្បីធ្វើការស៊ើបអង្កេតករណីអាស៊ីដបានយ៉ាងមានប្រសិទ្ធភាព និងសមរម្យ។ ចំណុចនេះរួមទាំង ការបណ្តុះបណ្តាលដ៏ត្រឹមត្រូវស្តីពីការគាំពារជនរងគ្រោះ និងសាក្សី តាមតម្រូវការក្នុងអំឡុងនៃការស៊ើបអង្កេតផងដែរ។
- ដូចបានផ្តល់អនុសាសន៍ខាងលើ ក្រសួងមហាផ្ទៃគួរតែធានាថា ក្រុមស៊ើបអង្កេត នឹងត្រូវបានបង្កើតឡើងដើម្បីធ្វើការស៊ើបអង្កេតការអនុវត្តន៍ច្បាប់ឲ្យបានត្រឹមត្រូវនៅក្នុងអនុក្រឹត្យ។
- ការស៊ើបអង្កេតក្នុងករណីបទល្មើសអាស៊ីដគួរតែត្រូវបានធ្វើឡើង ឲ្យបានទាន់ពេលវេលា និងនាំជនល្មើសមកកាត់ទោសឲ្យបានឆាប់រហ័ស។

## ៣.៤ ការគាំពារជនរងគ្រោះ

ដូចបានរៀបរាប់ក្នុងផ្នែកទីពីរនៃរបាយការណ៍នេះ គ្រប់ច្បាប់អាស៊ីដគួរតែអាចដោះស្រាយផលវិបាករបស់អំពើហិង្សាដោយអាស៊ីដ ដែលមានចំពោះជីវិតរបស់ជនរងគ្រោះ និងអាចដោះស្រាយបានយ៉ាងមានប្រសិទ្ធភាពចំពោះផលប៉ះពាល់នៃការវាយប្រហារដោយអាស៊ីដទាំងក្នុងរយៈពេលខ្លី និងរយៈពេលវែង។

ច្បាប់គ្រប់គ្រងអាស៊ីដខ្លាំង មិនបាននិយាយពីគណៈកម្មាធិការជាតិណាមួយ ដូចជា មជ្ឈមណ្ឌលសម្រាប់ជនរងគ្រោះរងរបួសដោយអាស៊ីដ ដើម្បីត្រួតពិនិត្យលើការអនុវត្តច្បាប់នោះទេ ជាពិសេស ស្តីពីការគាំពារជនរងគ្រោះ។ ដូច្នេះ យើងមិនទាន់ដឹងច្បាស់ថា តើអាជ្ញាធរមួយណាដែលទទួលខុសត្រូវចំពោះបញ្ញត្តិស្តីពីការគាំពារផ្នែកវេជ្ជសាស្ត្រ និងផ្នែកច្បាប់ ដែលបានចែងក្នុងច្បាប់ ហើយដែលនឹងត្រូវបានពិភាក្សាយ៉ាងលម្អិតបន្ថែមទៀតនោះទេ ទោះបីជាការការពារ ការស្តារនីតិសម្បទា និងធ្វើសមាហរណកម្ម ដើម្បីឲ្យជនរងគ្រោះអាចត្រលប់ទៅរស់នៅក្នុងសង្គមវិញបាន គឺជាសមត្ថកិច្ចរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក៏ដោយ ប៉ុន្តែនៅតែមានភាពមិនច្បាស់លាស់នៅក្នុងច្បាប់ ថាតើការការពារ ការស្តារនីតិសម្បាទ និងសមាហរណកម្មនេះមាននៅក្នុងទម្រង់បែបណា។[68] តើនឹងមានបញ្ចូលនូវការព្យាបាលកាយវប្បកម្ម និងផ្នែកអាជីព ដើម្បីអាចឲ្យជនរងគ្រោះអាចរៀនរស់នៅជាមួយភាពពិការរបស់ខ្លួន និងសម្របខ្លួនរស់នៅក្នុងសភាពបែបនោះ? តើនឹងមានការបញ្ចូលនូវការផ្តល់ការបណ្តុះបណ្តាលវិជ្ជាជីវៈ

[68] សូមអានមាត្រា១២ នៃច្បាប់គ្រប់គ្រងអាស៊ីដខ្លាំង។

និងជំនាញ ដើម្បីអាចឲ្យជនរងគ្រោះអាចទទួលបាននូវឯករាជ្យភាព និងក្លាយជាសមាជិកសកម្មនៅក្នុងសង្គមដូចកាលពីមុន?

ច្បាប់ក៏មិនបានចែងនូវបទប្បញ្ញត្តិស្ដីពីការលើកកម្ពស់ការយល់ដឹង ពីផលប៉ះពាល់នៃការប្រើប្រាស់អាស៊ីដខុសគោលដៅ និងគ្រោះថ្នាក់នៃអាស៊ីដនោះទេ។ រដ្ឋាភិបាល និងក្រសួងពាក់ព័ន្ធគួរតែពិចារណាបញ្ចូលបញ្ញត្តិដែលមានក្នុងច្បាប់ស្ដីពីការគ្រប់គ្រងអាស៊ីដរបស់បង់ក្លាដែស ហើយដែលច្បាប់នេះបានបង្កើតមូលនិធិឯករាជ្យដើម្បី *"ស្វែងរកថវិកា ដើម្បីបំពេញតាមគោលបំណងនៃការបង្កើតការយល់ដឹងជាសាធារណៈ ស្ដីអំពីផលអាក្រក់នៃការប្រើប្រាស់អាស៊ីដក្នុងផ្លូវខុស និងគ្រោះថ្នាក់របស់អាស៊ីដ"* ។[69] ការលើកកម្ពស់ការយល់ដឹងអំពីគ្រោះថ្នាក់នៃអាស៊ីដ គឺមានសារៈសំខាន់សម្រាប់គោលបំណងទូទៅក្នុងការការពាររាល់គ្រោះថ្នាក់ពាក់ព័ន្ធនឹងអាស៊ីដ។ វិធានការរបស់រដ្ឋាភិបាលដែលមានលក្ខណៈគ្រប់ដណ្ដប់លើបញ្ហាស្ដីពីអំពើហិង្សាដោយអាស៊ីដ គួរតែបញ្ចូលនូវតម្រូវការឲ្យរដ្ឋមានតួនាទីលើកកម្ពស់ការយល់ដឹងពាក់ព័ន្ធនឹងផលប៉ះពាល់របស់អាស៊ីដ និងជួយដល់សង្គមកម្ពុជាដើម្បីយល់ដឹងពីវិធានការដោះស្រាយជម្លោះដោយអហិង្សា។ ចំណុចនេះត្រូវបានអនុវត្តដើម្បីកាត់បន្ថយរាល់ភាពមាក់ងាយដែលមានមកលើជនរងគ្រោះនៅកម្ពុជាក្នុងពេលបច្ចុប្បន្នផងដែរ។

## (ក) ការគាំពារផ្នែកវេជ្ជសាស្ត្រ

ច្បាប់គ្រប់គ្រងអាស៊ីដខ្លាំង បានបញ្ចូលកាតព្វកិច្ចចំពោះអាជ្ញាធរដែលទទួលខុសត្រូវ និងពាក់ព័ន្ធដើម្បីនាំយកជនរងគ្រោះមកកាន់មណ្ឌលសុខភាព មន្ទីរពេទ្យរដ្ឋ ឬគ្រឹះស្ថានព្យាបាលរបស់រដ្ឋដទៃទៀត ដែលស្ថាប័នទាំងនេះគួរតែផ្ដល់ការគាំទ្រ និងការព្យាបាលដល់ជនរងគ្រោះដោយមិនចាំបាច់ត្រូវចំណាយប្រាក់។[70] ស្របពេលនឹងការទទួលស្គាល់ថា ការគាំពារផ្នែកវេជ្ជសាស្ត្រដែលជនរងគ្រោះត្រូវការគឺជាអ្វីដែលគួរឲ្យកោតសរសើរ ប៉ុន្តែ សំណួរគឺ តើគ្រឹះស្ថានព្យាបាលរដ្ឋទាំងនោះ ជាកន្លែងសមរម្យសម្រាប់បញ្ជូនជនរងគ្រោះដោយអាស៊ីដដែរឬទេ? របួសដោយសារអាស៊ីដជារបួសដែលងាយឆ្លងមេរោគ ហើយការព្យាបាលមួយចំនួនប្រហែលជាមានផលអាក្រក់ច្រើនជាងផលល្អ។ ដូច្នេះ ការបញ្ជូនជនរងគ្រោះទៅកាន់គ្រឹះស្ថានព្យាបាល ដែលមានវេជ្ជបណ្ឌិតមានការបណ្ដុះបណ្ដាលជាពិសេសដើម្បីព្យាបាលរបួសដោយអាស៊ីដ គឺចាំបាច់បំផុត ហើយចំណុចនេះគួរតែត្រូវកំណត់ក្នុងច្បាប់ឲ្យច្បាស់ថាជនរងគ្រោះដោយអាស៊ីដត្រូវបានបញ្ជូនទៅទទួលការព្យាបាលនៅគ្រឹះស្ថានសុខភាពប្រភេទណា។

ច្បាប់គ្រប់គ្រងអាស៊ីដខ្លាំងចែងថា ការកំណត់កម្រិតភាពពិការរបស់ជនរងគ្រោះដោយសារការវាយប្រហារដោយអាស៊ីដខ្លាំង នឹងត្រូវបានកំណត់ដោយគណៈកម្មាធិការជំនាញដែលបង្កើតឡើងដោយក្រសួងសុខាភិបាល។[71] ចំណុចសំខាន់គឺសមាជិករបស់គណៈកម្មាធិការពិសេស ត្រូវតែរួមមានវេជ្ជបណ្ឌិតមានជំនាញច្បាស់លាស់ក្នុងការព្យាបាលរបួសដោយសារអាស៊ីដ ហើយគណៈកម្មាធិការនេះគួរតែត្រូវបង្កើតឡើងឲ្យបានឆាប់រហ័ស ក្រោយពីមានការប្រកាសឲ្យអនុវត្តច្បាប់គ្រប់គ្រងអាស៊ីដ។ ទន្ទឹមពេលដែលការបង្កើតគណៈកម្មាធិការនេះ នឹងរួមចំណែកជួយដល់ការកំណត់ស្ថានភាពរបួសដែលចាំបាច់សម្រាប់ការផ្ដល់សេវាព្យាបាល ចំណុចសំខាន់គឺការព្យាបាលនោះត្រូវតែផ្ដល់ជូនជនរងគ្រោះឲ្យបានទាន់ពេលវេលា។ ចំណុចមួយទៀតដែលសំខាន់ដូចគ្នា គឺមិនត្រូវឲ្យជនរងគ្រោះរងចាំឲ្យគណៈកម្មាធិការចាត់វិធានការដោយមិនបានទទួលការព្យាបាលនោះទេ។ ការថែទាំជាបន្ទាន់មិនត្រូវអាស្រ័យលើគណៈកម្មាធិការណាមួយឡើយ ផ្ទុយទៅវិញគណៈកម្មាធិការនោះគួរតែធានានូវការព្យាបាលជាបន្តបន្ទាប់ និងជាប់លាប់ចំពោះជនរងគ្រោះ។ ប៉ុន្តែនៅមិនទាន់ច្បាស់ថាតើគណៈកម្មាធិការនេះនឹងមានទីតាំងនៅទីក្រុងភ្នំពេញ ដោយមានសមាជិកអាចធ្វើដំណើរទូទាំងប្រទេស ឬមានការិយាល័យនៅតាមខេត្តផងដែរនោះ។ ទិដ្ឋភាពទាំងនេះគួរតែត្រូវបានលើកយកមកពិចារណា ដើម្បីធានាថាជនរងគ្រោះអាចទទួលបានជំនួយចាំបាច់ និងឆាប់រហ័ស។ ច្បាប់គ្រប់គ្រងអាស៊ីដខ្លាំង គឺនៅមានភាពមិនច្បាស់លាស់ ចំពោះករណីថាតើការព្យាបាល និងការស្ដារនីតិសម្បទានឹងត្រូវបានផ្ដល់ឲ្យទាំងក្នុង

[69] សូមអានមាត្រា១០ នៃច្បាប់ស្ដីពីការគ្រប់គ្រងអាស៊ីដរបស់បង់ក្លាដែស។
[70] សូមអានមាត្រា១០ និង១១ នៃច្បាប់គ្រប់គ្រងអាស៊ីដខ្លាំង។
[71] ដូចខាងលើ។

រយៈពេលខ្លី និងរយៈពេលវែងឬក៏យ៉ាងណា។ ក្នុងអំឡុងពេលពិភាក្សាវែកញែកលើសេចក្តីព្រាងនៅរដ្ឋសភា មានការលើកឡើងថាការផ្តល់ការថែទាំង និងការព្យាបាលអស់មួយជីវិតគឺមិនត្រូវបានរំពឹងទុកនោះទេ ហើយការព្យាបាល និងការស្តារនីតិសម្បទានឹងអាចផ្តល់ជូនតែក្នុងរយៈពេលខ្លី។ ពិតជាមានសារៈសំខាន់ខ្លាំងណាស់ដែលការព្យាបាលរយៈពេលវែងនឹងត្រូវបានផ្តល់ជូនទៅជនរងគ្រោះដោយអាស៊ីដ ដោយសារជនរងគ្រោះភាគច្រើនតម្រូវឲ្យមានការវះកាត់ និងការព្យាបាលអស់មួយជីវិត។

ពេលដែលច្បាប់គ្រប់គ្រងអាស៊ីដខ្លាំង បានចែងពីការផ្តល់ការគាំទ្រផ្នែកវេជ្ជសាស្ត្រ និងការព្យាបាលដល់ជនរងគ្រោះ ប៉ុន្តែក៏មិនបានចែងពីការព្យាបាលជនល្មើស និងអ្នកសមគំនិតនោះទេ។ ជាញឹកញាប់ ក្នុងអំឡុងពេលវាយប្រហារមួយចំនួន អាចមានអាស៊ីដខ្ទាតមកលើជនល្មើសបណ្តាលឲ្យជនល្មើសរងរបួស។ ការមិនផ្តល់នូវការថែទាំចំពោះជនល្មើស គឺជាទោសបន្ថែមដែលជនល្មើសបានទទួល។ ប៉ុន្តែ ការខកខានមិនផ្តល់នូវការគាំទ្រផ្នែកវេជ្ជសាស្ត្រដល់ជនល្មើស ក៏អាចបណ្តាលឲ្យមានផលប៉ះពាល់ចំពោះការផ្តន្ទាទោសក្នុងករណីអំពើហិង្សាដោយអាស៊ីដផងដែរ។ ឧទាហរណ៍ ករណីមួយក្នុងខេត្តកំពង់ចាម ជនល្មើសម្នាក់បានរងរបួសដោយសារអាស៊ីដខ្ទាត តុលាការបានចេញសេចក្តីសម្រេចព្យួរទោសដោយមានលក្ខខណ្ឌឲ្យជនល្មើសជាប់ឃាំងក្នុងផ្ទះ និងទទួលការព្យាបាល។ ការធ្វើបែបនេះធ្វើឲ្យមានផលប៉ះពាល់ដល់ជនរងគ្រោះជាខ្លាំង ដោយអាចធ្វើឲ្យពួកគេក្លាយជាជនរងគ្រោះនៃការវាយប្រហារម្តងទៀត និងបង្អាក់ទឹកចិត្តមិនឲ្យពួកគេដាក់ពាក្យបណ្តឹងទៅតុលាការ ។ ការផ្តល់ការថែទាំរបស់រដ្ឋ និងប្រព័ន្ធផ្តល់ការថែទាំដល់ជនល្មើស ស្របពេលដែលពួកគេកំពុងតែទទួលទណ្ឌកម្ម មានសារៈសំខាន់ចំពោះសុខុមាលភាពផ្លូវចិត្តរបស់ជនរងគ្រោះ។ ទោះបីជា ជនល្មើសគួរតែទទួលខុសត្រូវចំពោះមុខច្បាប់ដែលមានអនុភាពពេញលេញ និងមិនគួរមានការកាត់បន្ថយទោសចំពោះជនល្មើសដោយសារតែរងរបួសដោយការខ្ទាតអាស៊ីដនោះ ប៉ុន្តែ ជនល្មើសក៏មិនគួរទទួលទោសបន្ថែម ព្រោះតែការខកខានមិនផ្តល់ការព្យាបាលដល់ជនល្មើសនោះទេ។

### (ខ) ការគាំពារផ្នែកច្បាប់

ច្បាប់គ្រប់គ្រងអាស៊ីដខ្លាំង ចែងថារដ្ឋាភិបាលគួរតែផ្តល់ការគាំពារផ្នែកច្បាប់ដល់ជនរងគ្រោះដោយអាស៊ីដខ្លាំង។[72] ចំណុចនេះ មានគោលបំណងកាត់បន្ថយបញ្ហានៃលទ្ធភាពទទួលបានយុត្តិធម៌ដែលជាចំណុចគួរឲ្យពេញចិត្ត ប៉ុន្តែនៅមិនទាន់ច្បាស់ តើពាក្យ "ផ្តល់នូវការគាំពារផ្នែកច្បាប់" មានន័យបែបណា។ តើចំណុចនេះរួមទាំងការទទួលបានមេធាវី ឬទទួលបានមូលនិធិសម្រាប់ស្វែងរកមេធាវី? នៅកម្ពុជាមានការខ្វះខាតជំនួយផ្នែកច្បាប់ជាខ្លាំង ដែលមានន័យថាជនរងគ្រោះនៃអំពើហិង្សាដោយអាស៊ីដ ត្រូវតែប្រឈមមុខនឹងការស្វែងរកជំនួយផ្នែកច្បាប់ ពេលដែលពួកគេត្រូវការ ដោយសារខ្វះខាតថវិកា និងផ្នែកធនធានមនុស្សដែលបណ្តាលឲ្យចំនួនមេធាវីមិនគ្រប់គ្រាន់សម្រាប់ផ្តល់ជំនួយផ្នែកច្បាប់ដែលអាចជួយដល់ជនរងគ្រោះដែលកំពុងត្រូវការបាន។[73] រដ្ឋាភិបាល និងក្រសួងពាក់ព័ន្ធគួរតែធ្វើការពិចារណាជាថ្មីម្តងទៀត ដើម្បីធ្វើវិសោធនកម្មច្បាប់គ្រប់គ្រងអាស៊ីដខ្លាំង ដើម្បីបញ្ចូលបញ្ញត្តិ ដូចដែលមានចែងក្នុងច្បាប់របស់បង់ក្លាដែស ដែលមូលនិធិរបស់រដ្ឋត្រូវបង្កើតឡើង ហើយថវិកាក្នុងមូលនិធិទាំងនោះអាចយកមកប្រើប្រាស់សម្រាប់ផ្តល់ជំនួយផ្នែកច្បាប់។ ចំណែកឯប្រាក់ចំណូលដែលបានមកពីការផ្តល់អាជ្ញាប័ណ្ណ ក៏អាចបញ្ចូលក្នុងមូលនិធិនេះ និងដើម្បីប្រើប្រាស់សម្រាប់ចំណាយផ្នែកច្បាប់ផងដែរ។

ក្រៅពីការលើកឡើងដែលនៅមានមន្ទិលសង្ស័យទាក់ទងនឹងជំនួយផ្នែកច្បាប់ ដែលត្រូវបានសន្មត់ថាសំដៅលើអ្នកតំណាងផ្នែកច្បាប់ ច្បាប់គ្រប់គ្រងអាស៊ីដខ្លាំងមិនបានចែងអំពីជំនួយផ្នែកច្បាប់ក្នុងទម្រង់ដទៃទៀត ដែលជាជំនួយដែលជនរងគ្រោះនៃអំពើហិង្សាដោយអាស៊ីដត្រូវការនោះទេ។ ដូចបានរៀបរាប់ នៅផ្នែកខាងដើមនៃរបាយ

---

[72] ដូចខាងលើ។

[73] ឧទាហរណ៍ របាយការណ៍របស់ក្រុមប្រឹក្សាដើម្បីកំណែទម្រង់ផ្នែកច្បាប់ និងប្រព័ន្ធយុត្តិធម៌ ឆ្នាំ២០០៦ នៃរដ្ឋាភិបាល រកឃើញថា *"ពុំមានក្របខណ្ឌច្បាប់ ស្ថាប័ន និងគោលនយោបាយដែលទូលាយនៅថ្នាក់ជាតិដើម្បីណែនាំពីបញ្ញត្តិ និងក្បួនសម្រាប់សេវាផ្នែកច្បាប់នោះទេ"* ។ សម្រាប់ព័ត៌មានបន្ថែម សូមអានក្រុមប្រឹក្សាដើម្បីកំណែទម្រង់ផ្នែកច្បាប់ និងប្រព័ន្ធយុត្តិធម៌ ជំនួយផ្នែកច្បាប់នៅកម្ពុជា ៖ ការអនុវត្ត ការយល់ឃើញ និងតម្រូវការ (ភ្នំពេញ ៖ ក្រុមប្រឹក្សាដើម្បីកំណែទម្រង់ផ្នែកច្បាប់ និងប្រព័ន្ធតុលាការ ខែធ្នូ ឆ្នាំ២០០៦) ទំព័រទី១០។

ការណ៍នេះ បញ្ហាធំបំផុតជុំវិញអំពើហិង្សាដោយអាស៊ីដ គឺនិទណ្ឌភាព។ ផលវិបាកសំខាន់បំផុតរបស់និទណ្ឌភាព គឺជនរងគ្រោះមានការភ័យខ្លាចចំពោះការសងសឹកប្រសិនបើពួកគាត់ទាមទារឲ្យមានការអនុវត្តនីតិវិធីផ្នែកច្បាប់។ ដូច្នេះ អ្វីដែលសំខាន់គឺ ច្បាប់គ្រប់គ្រងអាស៊ីដខ្លាំង គួរតែបញ្ចូលបញ្ញត្តិស្តីពីការការពារជនរងគ្រោះ និងសាក្សី។ ក្រមព្រហ្មទណ្ឌបានចែងនូវបញ្ញត្តិដែលមានបំណងទប់ស្កាត់នូវការគំរាមកំហែងដល់ជនរងគ្រោះ ឬជ្រៀតជ្រែកនីតិវិធីតុលាការដោយបង្កើនការផ្តន្ទាទោសចំពោះបទល្មើសជាក់ស្តែង ក្នុងករណីដែលមានការជ្រៀតជ្រែកនេះ។ មាត្រា៣១៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ (ក្រមនីតិវិធីព្រហ្មទណ្ឌ) បានចែងបន្ថែមទៀតពីវិធានការដូចជា សវនាការកំបាំងមុខ របាំង និងការផ្តល់ចម្លើយតាមរយៈខ្សែវីដេអូ ដើម្បីការពារជនរងគ្រោះ។ ប៉ុន្តែ ការមានបញ្ញត្តិជាក់លាក់ក្នុងច្បាប់គ្រប់គ្រងអាស៊ីដខ្លាំង គឺចាំបាច់ណាស់។ ដូចដែលមានចែងក្នុងច្បាប់អំពើហិង្សាក្នុងគ្រួសារ ច្បាប់គួរតែទទួលស្គាល់ថាការការពារសាក្សី គឺចាំបាច់ប្រសិនបើជនល្មើសត្រូវនាំយកមកកាត់ទោសតាមផ្លូវច្បាប់។

ជាញឹកញាប់ ទំនាក់ទំនងដ៏ចាក់ស្រេះក្នុងគ្រួសារ តែងកើតមានក្នុងករណីដែលពាក់ព័ន្ធនឹងអំពើហិង្សាដោយអាស៊ីដ ធ្វើឲ្យដំណើរការកាត់ទោសកាន់តែស្មុគស្មាញ។ ដូចបានរៀបរាប់ ក្នុងរបាយការណ៍អាស៊ីដ មាត្រា៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចែងថា *"យុត្តាធិការព្រហ្មទណ្ឌក៏អាចទទួលពាក្យបណ្តឹងពីមន្ត្រីរដ្ឋាភិបាល ឬភ្នាក់ងារសាធារណៈដទៃទៀត ដែលច្បាប់ដោយឡែកបានប្រគល់អំណាចឲ្យផងដែរ"* ។ ដូច្នេះ បង្ហាញពីលទ្ធភាពដើម្បីតែងតាំងមន្ត្រីក្នុងមាត្រានេះ ដើម្បីផ្តល់អំណាចដល់ពួកគេក្នុងការបញ្ជូនបណ្តឹងទៅកាន់ព្រះរាជអាជ្ញា។ មួយវិញទៀត មាត្រា១៧ ដល់មាត្រា១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានចែងថាសមាគមដែលធ្វើការដើម្បីឲ្យមានការកាត់បន្ថយនៃអំពើហិង្សាខាងផ្លូវភេទ អំពើហិង្សាក្នុងគ្រួសារ ឬអំពើហិង្សាប្រឆាំងនឹងកុមារ គ្រប់ទម្រង់ ព្រមទាំងសមាគមដែលធ្វើការដើម្បីឲ្យការកាត់បន្ថយនៃការចាប់ពង្រត់ ការជួញដូរមនុស្ស និងការធ្វើអាជីវកម្មខាងផ្លូវភេទ និងសមាគមដែលធ្វើការឲ្យមានការប្រឆាំងនឹងការប្រកាន់ពូជសាសន៍ និងការរើសអើងគ្រប់ទម្រង់ អាចធ្វើជាដើមបណ្តឹង ក្នុងបណ្តឹងរដ្ឋប្បវេណី ពាក់ព័ន្ធនឹងបទល្មើសដែលបានចែងពាក់ព័ន្ធនឹងជំនាញរបស់ពួកគេ។ ច្បាប់គ្រប់គ្រងអាស៊ីដខ្លាំង គួរតែបង្ហាញពីបញ្ញត្តិទាំងនេះដើម្បីជំរុញឲ្យមានការចូលរួមពីអង្គការមិនមែនរដ្ឋាភិបាល ក្នុងដំណើរការសវនាការ។ បទបញ្ញត្តិទាំងនេះ *"នឹងត្រូវបានអនុវត្តដើម្បីជំរុញឲ្យមានការដាក់ពាក្យបណ្តឹងព្រហ្មទណ្ឌ របស់ជនរងគ្រោះដោយសារអាស៊ីដ និងបណ្តឹងតបនឹងភាពអសកម្មរបស់ព្រះរាជអាជ្ញា"* ។[74]

**<u>អនុសាសន៍</u> ៖**

- រដ្ឋាភិបាលគួរតែអនុម័តនូវប្រកាសមួយដោយឡែក ដើម្បីបង្កើតមូលនិធិជាតិដើម្បីស្វែងរកថវិកា ដើម្បីបង្កើនការយល់ដឹងជាសាធារណៈស្តីពីអំពើហិង្សាដោយអាស៊ីដ និងដើម្បីផ្តល់ការព្យាបាល និងជំនួយផ្នែកច្បាប់ដល់ជនរងគ្រោះដោយសារអាស៊ីដ។ ប្រាក់ចំណូលដែលបានមកពីការផ្តល់អាជ្ញាប័ណ្ណក៏អាចប្រើដើម្បីគាំទ្រមូលនិធិនេះផងដែរ។ ប្រសិនបើគ្មានការអនុម័តនូវប្រកាស យ៉ាងហោចណាស់ រដ្ឋាភិបាលក៏គួរតែធ្វើការរួមជាមួយអង្គការដទៃទៀត បង្កើតឲ្យមានចំណេះដឹងសាធារណៈ និងយុទ្ធនាការអប់រំពាក់ព័ន្ធនឹងច្បាប់គ្រប់គ្រងអាស៊ីដខ្លាំង និងផលប៉ះពាល់នៃអាស៊ីដ។ ចំណុចទាំងនេះគួរតែធ្វើតាមរយៈបណ្តាញផ្សព្វផ្សាយ និងធ្វើការជាមួយសាលា។
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា តាមរយៈនៃប្រកាសគួរតែកំណត់នូវផែនការស្តីពីកម្មវិធីដើម្បីផ្តល់ការជ្រោមជ្រែង ស្តារនីតិសម្បទា និងធ្វើសមាហរណកម្មជនរងគ្រោះទៅក្នុងសង្គម ក្រោមមាត្រា១២ នៃច្បាប់គ្រប់គ្រងអាស៊ីដខ្លាំង។ កម្មវិធីនេះមិនត្រឹមតែបញ្ចូលនូវការព្យាបាលកាយវប្បកម្ម និងផ្នែកអាជីពប៉ុណ្ណោះទេ ប៉ុន្តែត្រូវរួមមានទាំងការបណ្តុះបណ្តាលវិជ្ជាជីវៈ និងជំនាញផងដែរ។
- ច្បាប់គួរតែបង្កើតគណៈកម្មាធិការថ្នាក់មូលដ្ឋាន ដែលទទួលខុសត្រូវក្នុងការអនុវត្តច្បាប់ស្តីពីការព្យាបាល ការស្តារនីតិសម្បទា និងជំនួយផ្នែកច្បាប់ និងការតាមដានការអនុវត្តន៍សេវាកម្មទាំងនេះដើម្បីធានាថាមាន

[74] អ.ជ.ជ.ក.អ និង ម.ស.ម.ក កំណត់សម្គាល់លេខ៦ ទំព័រទី២៥ ។

អាជ្ញាធរពាក់ព័ន្ធមួយក្រុមដែលច្បាស់លាស់ ដើម្បីជួយគាំពារដល់ជនរងគ្រោះ ហើយការគាំពារផ្នែកវេជ្ជសាស្រ្ត និងផ្នែកច្បាប់ត្រូវតែផ្តល់ជូនយ៉ាងឆាប់រហ័សតាមដែលអាចធ្វើទៅបាន។

- រដ្ឋាភិបាលគួរតែអនុម័តនូវសារាចរណ៍បញ្ជាក់ពីប្រភេទនៃសម្ភារៈបរិក្ខារ និងស្ថាប័នផ្នែកវេជ្ជសាស្រ្តដែលជនរងគ្រោះគួរអាចស្វែងរកបាន។
- គួរតែមានការធ្វើវិសោធនកម្មច្បាប់គ្រប់គ្រងអាស៊ីដខ្លាំង ដើម្បីឲ្យមានការកំណត់ច្បាស់លាស់ថាការព្យាបាលផ្នែកវេជ្ជសាស្រ្ត និងសេវាការស្តារនីតិសម្បទាត្រូវបានផ្តល់ជូន ដែលរួមបញ្ចូលទាំងការព្យាបាលបន្ទាន់ ក៏ដូចជាការព្យាបាលក្នុងរយៈពេលវែង។ មិនតែប៉ុណ្ណោះ ការព្យាបាលបែបនេះគួរតែផ្តល់ជូនដល់ជនរងគ្រោះ និងជនល្មើសផងដែរ។
- ត្រូវបញ្ចូលបញ្ញត្តិស្តីពីការការពារជនរងគ្រោះ និងសាក្សីក្នុងសវនាការក្នុងករណីទឹកអាស៊ីដផងដែរ។

# ៤. សេចក្តីសន្និដ្ឋាន

ច្បាប់គ្រប់គ្រងអាស៊ីដខ្លាំង ចែងពីបញ្ញត្តិចាំបាច់ជាច្រើន ដើម្បីឲ្យច្បាប់មានភាពជោគជ័យ ដូចជា ការចាត់ទុកអំពើហិង្សាដោយអាស៊ីដជាបទល្មើស ការគ្រប់គ្រងការលក់ ការទិញ ការចែកចាយ និងការដឹកជញ្ជូនអាស៊ីដ ការផ្តន្ទាទោស និងកាត់ទោសឲ្យស័ក្តិសមចំពោះជនល្មើស និងការគាំពារជនរងគ្រោះ។ ប៉ុន្តែ នៅមានភាពខ្វះចន្លោះក្នុងច្បាប់ដែលត្រូវលើកយកមកពិភាក្សា តាមរយៈការធ្វើវិសោធនកម្មនៃច្បាប់ ឬក៏តាមរយៈការអនុម័តអនុក្រឹត្យ ប្រកាស សារាចរណ៍ សេចក្តីណែនាំ ដែលត្រូវបំពេញបន្ថែមដើម្បីអាចឲ្យច្បាប់ធានាថារបបច្បាប់នេះមានរូបជាស្រេចដើម្បីធ្វើការកាត់បន្ថយបញ្ហានៃអំពើហិង្សាដោយអាស៊ីដឲ្យមានប្រសិទ្ធភាព ហើយដើម្បីធានាការកាត់ទោសចំពោះជនល្មើស ការការពារជនរងគ្រោះ ការគ្រប់គ្រងយ៉ាងត្រឹមត្រូវចំពោះការផលិត ការលក់ ការទិញ នៃសារធាតុគ្រោះថ្នាក់ដែលកាត់បំផ្លាញសាច់ និងវិធានការស្តារនីតិសម្បទា។ អនុសាសន៍ដែលបានផ្តល់ជូនក្នុងផ្នែកទី៣ ក្នុងរបាយការណ៍ ត្រូវបានធ្វើឡើងដើម្បីជួយដល់រដ្ឋាភិបាលក្នុងការបង្កើតច្បាប់ដ៏រឹងមាំមួយ ដែលអាចដោះស្រាយបញ្ហាអំពើហិង្សាដោយអាស៊ីដយ៉ាងមានប្រសិទ្ធភាព ដោយផ្អែកលើបទពិសោធន៍របស់យុត្តាធិការប្រទេសដទៃ។

ដូចដែលបានបញ្ជាក់ក្នុងរបាយការណ៍នេះរួចស្រេច ថ្វីត្បិតច្បាប់អាស៊ីដដ៏ល្អិតល្អន់ ពិតជាមានសារៈសំខាន់សម្រាប់ប្រឆាំងនឹងអំពើហិង្សាដោយអាស៊ីដដ៏ឃោរឃៅនេះក្តី ការអនុម័ត និងការអនុវត្តន៍ច្បាប់ ជាកត្តាចាំបាច់ដើម្បីដោះស្រាយបញ្ហាហិង្សាដោយអាស៊ីដនេះ។ កាលពីថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១១ តុលាការខេត្តកំពង់ចាមបានកាត់ទោសស្ត្រីម្នាក់ អាយុ២៥ឆ្នាំ ដោយព្យួរទោសចំនួន៣ឆ្នាំ ជំនួសការជាប់ពន្ធនាគារចំនួន២ឆ្នាំ ពីបទជះទឹកអាស៊ីដមកលើម្តាយ និងកូនពីរនាក់។[75] ដោយមិនបានយោងតាមការពិតដែលថា បញ្ញត្តិនៃការផ្តន្ទាទោសដែលមានស្រាប់នៅមានកម្រិតទាប ហើយពុំឆ្លុះបញ្ចាំងពីលក្ខណៈនៃបទល្មើសអាស៊ីដទៀតនោះ ការផ្តន្ទាទោសនេះបង្ហាញពីកង្វះខាតដ៏គួរឲ្យបារម្ភមួយ ចំពោះការអនុវត្តន៍ច្បាប់ជាធរមានឲ្យបានត្រឹមត្រូវ ក្នុងករណីនេះគឺក្រមព្រហ្មទណ្ឌ។ អ្វីដែលកាន់តែសំខាន់ គឺនេះជាការដាស់តឿនដ៏សំខាន់មួយថាច្បាប់អាស៊ីដត្រូវបានអនុម័ត នឹងមានប្រសិទ្ធភាពបានទាំងស្រុង លុះត្រាតែមានប្រព័ន្ធអនុវត្តន៍ច្បាប់ និងការតាមដានការអនុវត្តន៍ច្បាប់ដោយតុលាការយ៉ាងត្រឹមត្រូវពិតប្រាកដ។ ចំណុចសំខាន់គឺ តើប្រព័ន្ធតុលាការនឹងអាចអនុវត្តច្បាប់បានយ៉ាងត្រឹមត្រូវក្នុងកម្រិតណា។

ករណីដូចជា បង់ក្លាដែស ដែលច្បាប់អាស៊ីដបានបង្ហាញថាប្រសិនបើគ្មានប្រព័ន្ធអនុវត្តច្បាប់ដ៏ត្រឹមត្រូវទេ ឥទ្ធិពលដែលច្បាប់ចំពោះបទល្មើសអាស៊ីដអាចមានតិចតួចណាស់។ ដូច្នេះ បន្ថែមពីលើអនុសាសន៍ដែលបានផ្តល់ជូនពាក់ព័ន្ធនឹងច្បាប់គ្រប់គ្រងអាស៊ីដខ្លាំង អ្វីដែលសំខាន់ គឺរដ្ឋាភិបាលគួរតែប្រើវិធីសាស្ត្របែបគ្របដណ្តប់ និងពហុវិធានការវិន័យចំពោះអំពើហិង្សាដោយអាស៊ីដ ដែលពិចារណាពីរបៀបដែលច្បាប់នឹងត្រូវបានអនុវត្តបែបណាដើម្បីការពារអំពើហិង្សាដោយអាស៊ីដ និងផ្តន្ទាទោសយ៉ាងមានប្រសិទ្ធភាពចំពោះជនល្មើស។ ទន្ទឹមនឹងការគ្រប់គ្រង និងត្រួតពិនិត្យលទ្ធភាពរកអាស៊ីដមកប្រើប្រាស់ ការបញ្ចូលនូវការរារាំង តាមរយៈការចាត់អំពើហិង្សាដោយអាស៊ីដជាបទល្មើស ដូចដែលបានឃើញក្នុងច្បាប់គ្រប់គ្រងអាស៊ីដខ្លាំង គឺមានសារៈសំខាន់ អ្វីដែលត្រូវការបន្ថែមគឺហេដ្ឋារចនាសម្ព័ន្ធដ៏សមស្រប មានដូចជាអាជ្ញាធរដែលមានអំណាចក្នុងការតាមដានការលក់ ការគ្រប់គ្រង និងការកាន់កាប់អាស៊ីដ កងកម្លាំងនគរបាលដែលអាចធ្វើការស៊ើបអង្កេតដ៏ត្រឹមត្រូវ និងការធ្វើកំណែទម្រង់សង្គម ដែលអាចកាត់បន្ថយអាកប្បកិរិយារបស់សាធារណជន និង “*បន្ថយអំណាចសង្គមដែលការវាយប្រហារបែបនេះបានកាន់កាប់*” ។[76] ដើម្បីទទួលបានលទ្ធផលនេះ គឺត្រូវតែមានកិច្ចសហប្រតិបត្តិការពីស្ថាប័នរដ្ឋាភិបាលនានា កងកម្លាំងនគរបាល និងអាជ្ញាធរ និងអង្គការសង្គមស៊ីវិល ដើម្បីធានាថាបណ្តាញគាំទ្រដ៏សមស្របត្រូវបានបង្កើតឡើងដើម្បីឲ្យមានការអនុវត្តច្បាប់។

[75] ឆេង សុខហុង “ស្ត្រីម្នាក់ត្រូវព្យួរទោសចំនួន៣ឆ្នាំ ក្នុងករណីវាយប្រហារដោយអាស៊ីដ” ឌឹ ខែមបូឌា ដេលី ថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១១។

[76] អ.ជ.ជ.ក.អ និង ម.ស.ម.ក កំណត់សម្គាល់លេខ៦ ទំព័រទី៣៦។

# ៥. ឧបសម្ព័ន្ធ – ច្បាប់ស្តីពីការគ្រប់គ្រងអាស៊ីដខ្លាំង

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.**

ច្បាប់នេះ មានគោលបំណងកំណត់អំពីការគ្រប់គ្រង ការត្រួតពិនិត្យអាស៊ីដខ្លាំងគ្រប់ប្រភេទ ដែលបណ្ដាលឲ្យមានគ្រោះថ្នាក់ដល់សុខភាព និង អាយុជីវិតមនុស្ស ។

**មាត្រា ២.**

ច្បាប់នេះ មានគោលដៅកំណត់អំពីការបង្ការ ការទប់ស្កាត់ និងការបង្ក្រាបបទល្មើសដែលបង្កឡើង ដោយការប្រើប្រាស់អាស៊ីដខ្លាំងគ្រប់ប្រភេទ ហើយដែលបណ្ដាលឲ្យមានគ្រោះថ្នាក់ដល់សុខភាព និង អាយុជីវិតមនុស្ស ។

**មាត្រា ៣.**

ច្បាប់នេះ មានវិសាលភាពគ្របដណ្ដប់លើការផលិត ការកែច្នៃ ការនាំចូល ការនាំចេញ ការវេចខ្ចប់ ការដឹកជញ្ជូន ការយកតាមខ្លួន ការចែកចាយ ការលក់ ការទិញ ការរក្សាទុក និងការប្រើប្រាស់អាស៊ីដ ខ្លាំងគ្រប់ប្រភេទ ដែលបណ្ដាលឲ្យមានគ្រោះថ្នាក់ដល់សុខភាព និងអាយុជីវិតមនុស្ស នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៤.**

អាស៊ីដខ្លាំងក្នុងច្បាប់នេះ សំដៅដល់អាស៊ីដ វត្ថុធាតុដើម និងធាតុផ្សំជាអាស៊ីដទាំងឡាយ ទោះជាល្បាយរាវ ឬ រឹង ហើយមានប៉េហាស (pH) ស្មើ ឬ ក្រោម ៣ (បី) ដែលបណ្ដាលឲ្យមានគ្រោះថ្នាក់ដល់សុខភាព និងអាយុជីវិតមនុស្ស ដូចមានចុះនៅក្នុងតារាង ឧបសម្ព័ន្ធនៃច្បាប់នេះ លើកលែង អាស៊ីដស៊ុលហ្វួរិក ដែលជាល្បាយរាវ (សូលុយស្យុង) និង មានកំហាប់ ឬ ដង់ស៊ីតេក្រោម ៣៣%ដែលប្រើប្រាស់សម្រាប់ចាក់អាគុយ។ តារាងឧបសម្ព័ន្ធនៃច្បាប់នេះ អាចកែប្រែដោយអនុក្រឹត្យ។

## ជំពូកទី ២
## សមត្ថកិច្ចគ្រប់គ្រងអាស៊ីដខ្លាំង

**មាត្រា ៥.**

ការផលិត ការកែច្នៃ ការនាំចូល ការនាំចេញ ការវេចខ្ចប់ ការដឹកជញ្ជូន ការយកតាមខ្លួន ការ ចែកចាយ ការលក់ ការទិញ ការរក្សាទុក និង ការប្រើប្រាស់អាស៊ីដខ្លាំងគ្រប់ប្រភេទ ត្រូវមានអាជ្ញាបណ្ណ ឬ លិខិតអនុញ្ញាត ឬ ការកំណត់ ដោយបទដ្ឋានគតិយុត្តផ្សេងទៀត ។

**មាត្រា ៦.**

ការចេញអាជ្ញាបណ្ណ ឬ លិខិតអនុញ្ញាតទាក់ទងនឹងការនាំចូល ការនាំចេញ ការផលិតការកែច្នៃអាស៊ីដខ្លាំងគ្រប់ប្រភេទ ជាសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល។

ចំពោះអាស៊ីដខ្លាំងមានក្នុងនៅក្នុងតារាងឧបសម្ព័ន្ធ ហើយដែលត្រូវយកទៅប្រើប្រាស់សម្រាប់វិស័យសុខាភិបាល គឺជាសមត្ថកិច្ចរបស់ក្រសួងសុខាភិបាល ។

**មាត្រា ៧.**

បែបបទ និង លក្ខខណ្ឌនៃការលក់ ការទិញ ការរក្សាទុក ការចែកចាយ ការដឹកជញ្ជូន ការវេចខ្ចប់ ការយកតាមខ្លួន និង ការប្រើប្រាស់អាស៊ីដខ្លាំងគ្រប់ប្រភេទ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៨.**

រូបវន្តបុគ្គល ឬ នីតិបុគ្គល ដែលមានច្បាប់អនុញ្ញាតឲ្យប្រើប្រាស់អាស៊ីដខ្លាំងគ្រប់ប្រភេទត្រូវ ប្រើប្រាស់អាស៊ីដខ្លាំងទាំងនោះ ឲ្យចំគោលដៅ និង ត្រូវគោរពបទដ្ឋានបច្ចេកទេស ក្នុងកម្រិតសុវត្ថិភាពខ្ពស់បំផុត ។

**មាត្រា ៩**.

អាស៊ីដខ្លាំងគ្រប់ប្រភេទ ដូចមានចុះនៅក្នុងតារាងឧបសម្ព័ន្ធនៃច្បាប់នេះ ត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់តែក្នុងគោលដៅបម្រើវិស័យឧស្សាហកម្ម សុខាភិបាល កសិកម្ម សិប្បកម្ម បច្ចេកទេស វិទ្យាសាស្ត្រ វិទ្យាសាស្ត្រស្រាវជ្រាវ ពិសោធន៍ ការធ្វើតេស្ត និង វិស័យផ្សេងទៀត ដែលបម្រើផល ប្រយោជន៍ខាងសេដ្ឋកិច្ច សង្គម និង បម្រើជីវភាពប្រចាំថ្ងៃដែលស្របច្បាប់ ។

## ជំពូកទី៣
## ការគាំពារជនរងគ្រោះដោយអាស៊ីដខ្លាំង

**មាត្រា ១០**.

ក្នុងករណីមានជនរងគ្រោះដោយអាស៊ីដខ្លាំង អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធត្រូវសហការ បញ្ជូនជនរងគ្រោះទៅសង្គ្រោះជាបន្ទាន់ នៅមណ្ឌលសុខភាព មន្ទីរពេទ្យរដ្ឋ ឬ គ្រឹះស្ថានព្យាបាលផ្សេងទៀត ដែលស្ថិតនៅជិតបំផុត ។

**មាត្រា ១១**.

មណ្ឌលសុខភាព មន្ទីរពេទ្យរដ្ឋ ឬ គ្រឹះស្ថានព្យាបាលសាធារណៈផ្សេងទៀត ត្រូវផ្តល់ការ សង្គ្រោះ និងការព្យាបាលដល់ជនរងគ្រោះដោយសារអាស៊ីដខ្លាំង ដោយឥតគិតថ្លៃ ។

ការកំណត់កម្រិតពិការភាពនៃជនរងគ្រោះ ដោយសារអាស៊ីដខ្លាំង ជាសមត្ថកិច្ចរបស់គណៈកម្មការជំនាញដែលបង្កើតឡើងដោយក្រសួងសុខាភិបាល និង អនុលោមតាមបញ្ញត្តិនៃក្រមនីតិវិធី ព្រហ្មទណ្ឌ ។

រដ្ឋត្រូវផ្តល់ជំនួយសង្គ្រោះផ្នែកច្បាប់ ដល់ជនរងគ្រោះ ដោយសារអាស៊ីដខ្លាំង ។

**មាត្រា ១២**.

ការគាំពារ ការស្តារនីតិសម្បទា និងការធ្វើសមាហរណកម្មជនរងគ្រោះ ដោយអាស៊ីដខ្លាំងទៅ ក្នុងសហគមន៍ ជាសមត្ថកិច្ចរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ។

**មាត្រា ១៣**.

រដ្ឋលើកទឹកចិត្តឲ្យមានការចូលរួមពីសប្បុរសជន សមាគម អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ និងពីវិស័យឯកជន ក្នុងការជួយគាំពារដល់ជនរងគ្រោះដោយសារអាស៊ីដខ្លាំង ។

## ជំពូកទី៤
## ទោសប្បញ្ញត្តិ

**មាត្រា ១៤**.

អំពើផលិត កែច្នៃ នាំចូល នាំចេញ វេចខ្ចប់ ដឹកជញ្ជូន យកតាមខ្លួន ចែកចាយ លក់ ទិញ រក្សាទុក និង ប្រើប្រាស់អាស៊ីដខ្លាំងគ្រប់ប្រភេទ ដោយគ្មានអាជ្ញាបណ្ណ ឬ លិខិតអនុញ្ញាត ឬ មិនគោរព តាមការកំណត់របស់បទដ្ឋានគតិយុត្តផ្សេងទៀត ត្រូវផ្តន្ទាទោសដូចខាងក្រោម:

១- ពិន័យជាប្រាក់ពី ៥០០.០០០(ប្រាំសែន) រៀល ទៅ ១.៥០០.០០០ (មួយលានប្រាំសែន) រៀល ព្រមទាំងទោសបន្ថែម ដោយរឹបអូសអាស៊ីដខ្លាំង ក្នុងករណីដែលអាស៊ីដខ្លាំងនោះ មានទម្ងន់ ក្រោម ៥០០ (ប្រាំរយ) ក្រាម ។

២- ពិន័យជាប្រាក់ពី ១.៥០០.០០០ (មួយលានប្រាំសែន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ព្រមទាំងទោសបន្ថែម ដោយរឹបអូសអាស៊ីដខ្លាំង ក្នុងករណីដែលអាស៊ីដខ្លាំងនោះ មានទម្ងន់ចាប់ពី ៥០០ (ប្រាំរយ) ក្រាមឡើងទៅ ។

**មាត្រា១៥**.

នីតិបុគ្គល អាចប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌ ដែលមានចែងក្នុង មាត្រា ៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ ចំពោះបទល្មើសដូចមានចែងក្នុងមាត្រា១៤ ខាងលើនេះ។

នីតិបុគ្គល ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន)រៀលទៅ ១០.០០០.០០០(ដប់លាន) រៀល ក្នុងករណីដែលអាស៊ីដខ្លាំងនោះ មានទម្ងន់ក្រោម ៥០០(ប្រាំរយ) ក្រាម ។

នីតិបុគ្គល ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ៥០.០០០.០០០ (ហាសិបលាន) រៀល ក្នុងករណីដែលអាស៊ីដខ្លាំងនោះ មានទម្ងន់ចាប់ពី ៥០០ (ប្រាំរយ) ក្រាមឡើងទៅ ។

នីតិបុគ្គល ត្រូវទទួលទោសបន្ថែមណាមួយ ឬ ច្រើន ដូចមានចែងក្នុងមាត្រា ១៦៨ (ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ ។

**មាត្រា ១៦**.

អំពើសម្លាប់មនុស្សដោយចេតនា ដោយប្រើអាស៊ីដខ្លាំង ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ (ដប់ប្រាំ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ ។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត ក្នុងករណីបទឧក្រិដ្ឋខាងលើត្រូវបានប្រព្រឹត្តដោយមាន :

១- ការគិតទុកជាមុន ឬ ការពួនស្ទាក់។

២- អំពើទារុណកម្ម ឬ អំពើឃោរឃៅមុន ឬ ក្នុងពេលប្រព្រឹត្តអំពើសម្លាប់។

ចំពោះបទឧក្រិដ្ឋខាងលើ ទោសបន្ថែមដែលមានចែងក្នុងមាត្រា ២០៦ (ទោសបន្ថែម : ប្រភេទ និង រយៈពេល) នៃក្រមព្រហ្មទណ្ឌ អាចត្រូវបានប្រកាស ។

**មាត្រា ១៧**.

អំពើដែលបណ្តាលឲ្យស្លាប់អ្នកដទៃ ដោយអចេតនា ដោយការធ្វេសប្រហែស ការមិនប្រុង ប្រយ័ត្ន ការខ្ជីខ្ជា ឬ ការបំពានលើកាតព្វកិច្ចសន្តិសុខ ឬ កាតព្វកិច្ចប្រុងប្រយ័ត្នដែលច្បាប់ ឬ បទដ្ឋានគតិយុត្តផ្សេងទៀត តម្រូវក្នុងការគ្រប់គ្រងអាស៊ីដខ្លាំង ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និង ពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

ចំពោះបទមជ្ឈិមខាងលើ ទោសបន្ថែមដែលមានចែងក្នុងមាត្រា ២០៨ (ទោសបន្ថែម : ប្រភេទ និង រយៈពេល) នៃក្រមព្រហ្មទណ្ឌ អាចត្រូវបានប្រកាស ។

**មាត្រា ១៨**.

នីតិបុគ្គល អាចត្រូវបានប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌ ដែលមានចែង ក្នុងមាត្រា ៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ ចំពោះបទល្មើស ដែលមានចែងក្នុងមាត្រា ១៧ ខាងលើ ។

នីតិបុគ្គល ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ២០.០០០.០០០ (ម្ភៃលាន) រៀល ទៅ ៥០.០០០.០០០ (ហាសិបលាន) រៀល ព្រមទាំងទោសបន្ថែមណាមួយ ឬ ច្រើន ដូចមានចែងក្នុង មាត្រា២០៩ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ ។

**មាត្រា ១៩**.

ទារុណកម្ម និង អំពើឃោរឃៅដោយប្រើអាស៊ីដខ្លាំង ដែលប្រព្រឹត្តទៅលើបុគ្គលណាមួយ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ២០ (ម្ភៃ) ឆ្នាំ ។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ (ដប់ប្រាំ) ឆ្នាំ ទៅ ២៥ (ម្ភៃប្រាំ) ឆ្នាំ កាលបើការប្រព្រឹត្តបទឧក្រិដ្ឋខាងលើនេះ នាំឲ្យមានការកាត់អវយវៈ ឬ ឲ្យមានពិការភាពជាអចិន្ត្រៃយ៍ដល់ជនរងគ្រោះ។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២០ (ម្ភៃ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ កាលបើការប្រព្រឹត្ត បទឧក្រិដ្ឋខាងលើបណ្តាលឲ្យជនរងគ្រោះស្លាប់ ដោយគ្មានចេតនាសម្លាប់ ឬ នាំឲ្យមានអត្តឃាតរបស់ជននេះ ។

ចំពោះបទឧក្រិដ្ឋខាងលើ ទោសបន្ថែមដែលមានចែងក្នុងមាត្រា ២១៦ (ទោសបន្ថែម : ប្រភេទ និង រយៈពេល) នៃក្រមព្រហ្មទណ្ឌ អាចត្រូវបានប្រកាស ។

**មាត្រា ២០**.

អំពើហិង្សាដោយចេតនាទៅលើអ្នកដទៃ ដោយប្រើអាស៊ីដខ្លាំង ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ៥ (ប្រាំ) ឆ្នាំ និង ពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ កាលបើការប្រព្រឹត្តអំពើនេះ នាំឲ្យមានការកាត់អវយវៈ ឬ ឲ្យមានពិការភាពជាអចិន្ត្រៃយ៍ដល់ជនរងគ្រោះ ។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ២០ (ម្ភៃ) ឆ្នាំ កាលបើអំពើនេះបណ្តាលឲ្យជនរងគ្រោះស្លាប់ដោយគ្មានចេតនាសម្លាប់ ។

ចំពោះបទល្មើសខាងលើ ទោសបន្ថែមដែលមានចែងក្នុងមាត្រា ២២៩ (ទោសបន្ថែម : ប្រភេទ និង រយៈពេល) នៃក្រមព្រហ្មទណ្ឌ អាចត្រូវបានប្រកាស ។

ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិម ដែលមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ ត្រូវផ្តន្ទាទោសដូចបទមជ្ឈិមនេះដែរ ។

**មាត្រា ២១**.

អំពើដែលបង្កឲ្យមានរបួស ដោយអចេតនា ដោយការធ្វេសប្រហែស ការមិនប្រុងប្រយ័ត្ន ការខ្ជីខ្ជា ឬ ការបំពានលើកាតព្វកិច្ចសន្តិសុខ ឬ កាតព្វកិច្ចប្រុងប្រយ័ត្ន ដែលច្បាប់ ឬ បទដ្ឋានគតិយុត្តផ្សេងទៀត តម្រូវក្នុងការគ្រប់-គ្រងអាស៊ីដខ្លាំង ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១(មួយ) ឆ្នាំ និង ពិន័យជាប្រាក់ពី ២០០.០០០ (ម្ភៃម៉ឺន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល ។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ៣ (បី) ឆ្នាំ និង ពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល កាលបើការប្រព្រឹត្តនេះ នាំឲ្យមានការកាត់អវយវៈ ឬ ឲ្យមានពិការភាពជាអចិន្ត្រៃយ៍ ដល់ជនរងគ្រោះ ។

ចំពោះបទមជ្ឈិមខាងលើ ទោសបន្ថែមដែលមានចែងក្នុងមាត្រា ២៣៧ (ទោសបន្ថែម : ប្រភេទ និងរយៈពេល) នៃក្រមព្រហ្មទណ្ឌ អាចត្រូវបានប្រកាស ។

**មាត្រា ២២**.

នីតិបុគ្គល អាចត្រូវបានប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌ ដែលមានចែងក្នុងមាត្រា ៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ ចំពោះបទល្មើសដូចមានចែងក្នុងមាត្រា ២១ ខាងលើនេះ ។

នីតិបុគ្គល ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី៥.០០០.០០០ (ប្រាំលាន)រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល ព្រមទាំងទោសបន្ថែមណាមួយ ឬ ច្រើន ដូចមានចែងក្នុងមាត្រា ២៣៨ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិ-បុគ្គល) នៃក្រមព្រហ្មទណ្ឌ ។

**មាត្រា ២៣**.

អំពើផលិតម្ហូបអាហារ ឬ ការអនុញ្ញាតឲ្យផលិតម្ហូបអាហារ ដោយប្រើអាស៊ីដខ្លាំង ខុសពីបទដ្ឋានបច្ចេកទេស ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ១០.០០០.០០០(ដប់លាន) រៀល ។

**មាត្រា ២៤**.

នីតិបុគ្គល អាចត្រូវបានប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌ ដែលមានចែងក្នុងមាត្រា ៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ ចំពោះបទល្មើស ដែលមានចែងក្នុងមាត្រា ២៣ ខាងលើ ។

នីតិបុគ្គល ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ២០.០០០.០០០ (ម្ភៃលាន) រៀល ទៅ ៥០.០០០.០០០ (ហាសិបលាន) រៀល ព្រមទាំងទោសបន្ថែមណាមួយ ឬ ច្រើន ដូចមានចែងក្នុង មាត្រា ១៦៨ (ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ ។

## ជំពូកទី៥
## អន្តរប្បញ្ញត្តិ

**មាត្រា ២៥.**

ក្រោយពេលដែលច្បាប់នេះចូលជាធរមាន រូបវន្តបុគ្គល ឬ នីតិបុគ្គល ដែលបាននិងកំពុងធ្វើ អាជីវកម្មអាស៊ីដខ្លាំង ដោយគ្មានការអនុញ្ញាត ហើយដែលមានបំណងធ្វើអាជីវកម្មអាស៊ីដខ្លាំង ត្រូវបំពេញបែបបទដើម្បីស្នើសុំការអនុញ្ញាតធ្វើអាជីវកម្មស្របតាមច្បាប់ជាធរមាន ។

**មាត្រា ២៦.**

បទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា ១៩ នៃច្បាប់ត្រូវចាប់អនុវត្ត ក្រោយពេលមានអនុក្រឹត្យ ដូចមានកំណត់ក្នុងមាត្រា ៧ នៃច្បាប់នេះ ។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**មាត្រា ២៧.**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវចាត់ទុកថា គ្មានអនុភាពត្រឹមទំហំដែលផ្ទុយនឹងច្បាប់នេះ ចាប់ពីថ្ងៃដែលច្បាប់នេះត្រូវបានអនុវត្ត ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១១

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**ហត្ថលេខា**

**ស ខេង**

លេខ : ១០៧៩ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០១១

**អគ្គលេខាធិការរងទី១រាជរដ្ឋាភិបាល**

**សយ សុខា**

# តារាងឧបសម្ព័ន្ធ
## អាស៊ីដខ្លាំង( មាត្រា ៤ នៃច្បាប់ស្តីពីការគ្រប់គ្រងអាស៊ីដខ្លាំង )

**តារាងនេះមានៈ**

- ឈ្មោះអាស៊ីដខ្លាំងជាភាសារខ្មែរនិងភាសារអន្តរជាតិ
- អាស៊ីដខ្លាំង ទោះបីជាល្បាយរឹង ឬ ល្បាយរាវ ដែលមាន pH ស្មើរ ឬ ក្រោម ៣ (បី) ហើយបណ្តាលឲ្យមានគ្រោះថ្នាក់ដល់សុខភាពនិងអាយុជីវិតមនុស្ស
- រាប់ទាំងវត្ថុធាតុដើមនិងវត្ថុធាតុផ្សំជាសារធាតុអាស៊ីដខ្លាំង

| ភាសាខ្មែរ | ភាសាបារាំង | ភាសាអង់គ្លេសបែបអាមេរិចកាំង | រូបមន្តគីមី |
|---|---|---|---|
| អាស៊ីដអ៊ីដ្រូអ៊ីយ៉ូឌីក | Acide iodhydrique | Hydroiodic acid | $HI$ |
| អាស៊ីដអ៊ីដ្រូប្រូមិក | Acide bromhydrique | Hydrobromic acid | $HBr$ |
| អាស៊ីដពែរក្លរិក | Acide perchlorique | Perchloric acid | $HClO_4$ |
| អាស៊ីដក្លរីឌ្រីក | Acide chlorhydrique | Hydrochloric acid | $HCl$ |
| អាស៊ីដហ្លួយអរីឌ្រិក | Acide Fluoridrique | Hydrofluoric Acid | $HF$ |
| អាស៊ីដស៊ុលហ្វួរិក | Acide sulfurique | Sulfuric acid | $H_2SO_4$ |
| អាស៊ីដនីទ្រីក | Acide nitrique | Nitric acid | $HNO_3$ |
| អាស៊ីដក្លរិក | Acide chlorique | Chloric acid | $HClO_3$ |
| អាស៊ីដប៉ារ៉ាតូលុយអែន ស៊ុលហ្វូនិក | Acide para toluensultfonique | p-Toluenesulfonic acid | $C_7H_8O_3S$ |
| អាស៊ីដប្រូមិក | Acide bromique | Bromic acid | $HBrO_3$ |
| អាស៊ីដពែរប្រូមិក | Acide perbromique | Perbromic acid | $HBrO_4$ |
| អាស៊ីដអ៊ីយ៉ូឌីក | Acide iodique | Iodic acid | $HIO_3$ |
| អាស៊ីតពែរអ៊ីយ៉ូឌីក | Acide periodique | Periodic acid | $HIO_4$ |
| អាស៊ីដហ្លួយអូរ៉ូអង់ទីម៉ូនិក | Acide fluoroatimonique | Fluoroantimonic acid | $H[SbF_6]$ |
| អាស៊ីដម៉ាហ្សិក | Acide magique | Magic acid | $FSO_3HSbF_5$ |
| អាស៊ីដកាបូរ៉ាន | Acide carborane | Carborane acid | $H(CHB_{11}Cl_{11})$ |
| អាស៊ីដហ្លួយអូរ៉ូស៊ុលហ្វួរិក | Acide fluorosulfurique | Fluorosufuric acid | $FSO_3H$ |
| អាស៊ីដទ្រីហ្លិក | Acide Triflique | Triflic acid | $CF_3SO_3H$ |

# ៦. គន្លងនិទ្ទេស

## ច្បាប់

### ច្បាប់អន្តរជាតិ

មហាសន្និបាតរបស់អង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ថ្ងៃទី១០ ខែតុលា ឆ្នាំ ១៩៤៨

មហាសន្និបាតរបស់អង្គការសហប្រជាជាតិ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦

មហាសន្និបាតរបស់អង្គការសហប្រជាជាតិ អនុសញ្ញាប្រឆាំងនឹងការជួញដូរថ្នាំញៀន និងសារធាតុពង្វក់ស្មារតី ថ្ងៃទី២៥ ខែឧសភា ឆ្នាំ១៩៨៨

### ច្បាប់កម្ពុជា

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ (ដែលមានការធ្វើវិសោធនកម្ម)

សេចក្តីប្រកាសពីគោលការណ៍មូលដ្ឋាននៃយុត្តិធម៌សម្រាប់ជនរងគ្រោះនៃបទឧក្រិដ្ឋ និងការរំលោភបំពានអំណាច ដែលអនុម័តដោយមហាសន្និបាត ក្នុងសេចក្តីសម្រេចលេខ ៤០/៣៤ នៅថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ១៩៨៥

ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ឆ្នាំ២០០៥

ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩

### ច្បាប់បរទេស

ច្បាប់ស្តីពីការគ្រប់គ្រងអាស៊ីដរបស់បង់ក្លាដែស (អនុម័ត ថ្ងៃទី១៧ ខែមិនា ឆ្នាំ២០០២)

ច្បាប់ស្តីពីការគ្រប់គ្រងបទល្មើសអាស៊ីដរបស់បង់ក្លាដែស (អនុម័ត ថ្ងៃទី១៧ ខែមិនា ឆ្នាំ២០០២)

គណៈកម្មការច្បាប់នៃប្រទេសឥណ្ឌា "ការបញ្ចូលការវាយប្រហារដោយអាស៊ីដ ជាបទល្មើសជាក់លាក់ក្នុងក្រមព្រហ្មទណ្ឌរបស់ឥណ្ឌា និងច្បាប់នៃការផ្តល់សំណងដល់ជនរងគ្រោះនៃបទឧក្រិដ្ឋ" (គណៈកម្មការច្បាប់ លេខ២២៦ ខែកក្កដា ឆ្នាំ២០០៨)

ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះកម្ពុជា (អនុម័តថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៥ ប្រកាសឲ្យចូលជាធរមាននៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៥)

ច្បាប់ស្តីពីការគ្រប់គ្រងអាស៊ីដ និងច្បាប់ការពារបទល្មើសអាស៊ីដ របស់ប៉ាគីស្ថាន ឆ្នាំ២០០៩

## របាយការណ៍ និងការបោះពុម្ពផ្សាយ


មជ្ឈមណ្ឌលអាវ៉ុនពិភពលោកដើម្បីស្ត្រី និងយុត្តិធម៌ នៅសាលាច្បាប់ខរណែល និងគណៈមេធាវីនៃរដ្ឋញូវយ៉ក "ការទប់ស្កាត់អំពើហិង្សាដោយអាស៊ីដនៅបង់ក្លាដែស កម្ពុជា និង ឥណ្ឌា" (២០១១) <http://www.lawschool.cornell.edu/womenandjustice/Launch-event-Avon-Global-Center-report-on-acid-violence-in-Bangladesh-Cambodia-and-India.cfm> ចូលអានកាលពីថ្ងៃទី ០២ ខែមិនា ឆ្នាំ២០១១

ហ្វ្រីដា អាលឡឺ ដើហាត អូ.ដាប់បិលយូ. មូល័រ និង វីល្លៀម អែស. ឡូហ្វឺរ ឧក្រិដ្ឋវិទ្យា (ម៉ែកក្រ ហ៊ីល រដ្ឋញូវយ៉ក ឆ្នាំ២០០១)

ឃីធី បូឡឺនីនី "អំពើហិង្សាយេនឌ័រក្នុងលំហសាធារណៈ ៖ ការជះទឹកអាស៊ីដ" មជ្ឈមណ្ឌលសឺឃ្វីន ដើម្បីសមភាព និងការដាក់បញ្ចូល (២០១០) <http://cequinindia.org/pdf/Special_Reports/Acid%20Throwing.pdf> ចូលអានកាលពីថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១០

អង្គការជួយសង្គ្រោះជនរងគ្រោះដោយសារអាស៊ីដនៅកម្ពុជា របាយការណ៍ប្រចាំឆ្នាំ២០១០ http://www.cambodianacidsurvivorscharity.org/annual%20report2010.pdf, ចូលអានកាលពីថ្ងៃទី ១៦ ខែមករា ឆ្នាំ២០១១

អង្គការជួយសង្គ្រោះជនរងគ្រោះដោយសារអាស៊ីដនៅកម្ពុជា របាយការណ៍ប្រចាំឆ្នាំ២០០៩ http://www.cambodianacidsurvivorscharity.org/annual%20report2009.pdf, ចូលអានកាលពីថ្ងៃទី ១៦ ខែមករា ឆ្នាំ២០១១

អង្គការជួយសង្គ្រោះជនរងគ្រោះដោយសារអាស៊ីដនៅកម្ពុជា និង មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា(ម.ស.ម.ក) "នាំគ្នាបញ្ឈប់អំពើ ហិង្សាដោយអាស៊ីដ នៅកម្ពុជា" (ឧសភា ២០១០)

សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ (លីកាដូ) "ការវាយប្រហារដោយទឹកអាស៊ីដនៅកម្ពុជានៅតែមិនទាន់មានការត្រួតពិនិត្យ" (ថ្ងៃទី២៩ ខែមករា ឆ្នាំ២០១០) <http://www.licadho-cambodia.org/articles/20100129/105/index.html> ចូលអានកាលពីថ្ងៃទី១៦ ខែមករា ឆ្នាំ២០១១

សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ (លីកាដូ) និងមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា(ម.ស.ម.ក) "និទណ្ឌភាពកំពុងកើនឡើង ៖ សាលក្រមនៃករណីវាយប្រហារដោយទឹកអាស៊ីដនៅកម្ពុជាជាភាពគួរឲ្យខ្មាស់អៀនរបស់ប្រព័ន្ធយុត្តិធម៌កម្ពុជា" (ថ្ងៃទី០២ ខែកញ្ញា ២០០៩) <http://www.licadho-cambodia.org/pressrelease.php?perm=214> ចូលអានកាលពីថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១០

សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្សកម្ពុជា "រស់នៅក្នុងស្រមោល ៖ ការវាយប្រហារដោយអាស៊ីដនៅកម្ពុជា" កម្មវិធីប្រឆាំងនឹងអំពើទារុណកម្ម (២០០៣)

ចាន់ វ៉ាន់ ឌីក អ៊ីរិន សាជែល ក្រែនដ៍ និង លីអូ ធូនលីត "ឧក្រិដ្ឋវិទ្យាបច្ចុប្បន្ន" (ពោងពុម្ព អែស ឌី យូ ទីក្រុងឡាអេ ឆ្នាំ២០០៦)

បណ្ដាញព័ត៌មានថ្នាក់តំបន់ប្រមូលផ្ដុំ "បង់ក្លាដែស ៖ ការវាយប្រហារដោយទឹកអាស៊ីដនៅតែបន្ត ទោះជាមានច្បាប់ថ្មីក៏ដោយ" (ដាកា ថ្ងៃទី០៥ ខែមករា ឆ្នាំ២០០៩) <http://www.unhcr.org/refworld/docid/496321d826.html> ចូលអានកាលពីថ្ងៃទី១៧ ខែមករា ឆ្នាំ ២០១១

បណ្ដាញព័ត៌មានថ្នាក់តំបន់ប្រមូលផ្ដុំ "កម្ពុជា ៖ ការផ្ដន្ទាទោសដ៏ធ្ងន់ធ្ងរត្រូវបានគ្រោងទុកសម្រាប់ការវាយប្រហារដោយអាស៊ីដ" (ភ្នំពេញ ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១០) <http://www.unhcr.org/refworld/docid/4bda87228.html> ចូលអានកាលពីថ្ងៃទី១៧ ខែមករា ឆ្នាំ ២០១១

ណាតាលី អូរិនស្ទើន "ជនរងគ្រោះដោយទឹកអាស៊ីដជំរុញឲ្យមានការបង្កើតច្បាប់នៅប៉ាគីស្ថាន" ញូវស៍ដេស ( ថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១០) < http://newsdesk.org/2010/06/acid-attack-victim-inspires-pakistani-legislation/> ចូលអានកាលពីថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១០

សែរ៉ា រ៉ាម៉ាន "ការឆ្លុះបញ្ចាំងខុសពីការពិត ៖ អំពើហិង្សាទឹកអាស៊ីដ និងច្បាប់នៅបង់ក្លាដែស" គណៈកម្មការសិទ្ធិមនុស្ស (ថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៥) <http://www.hrsolidarity.net/mainfile.php/2005vol15no03/2429/> ចូលអានកាលពីថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១០

សែរ៉ា រ៉ាម៉ាន សាហា្យដ ហ៊ូសែន និងកានីស ហ្វៃតម៉ា "បញ្ឈប់និទណ្ឌភាពនៃអំពើហិង្សាដោយអាស៊ីដ និងការរំលោភ" អូធិកា (ថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០០៧)

គ្រីស្ទីន ស៊ូលបើក "ជំហានរបស់ប៉ាគីស្ថានដើម្បីបង្ក្រាបអំពើហិង្សាដោយអាស៊ីដ" (២០១០) ឌឹ ឡែនសិត ភាគទី៣៧៦ (៩៧៤៨) ទំព័រ ១២០៩-១២១០ <http://www.sciencedirect.com/science?_ob=ArticleURL&_udi=B6T1B-51633TM9&_user=496085&_coverDate=10%2F15%2F2010&_rdoc=1&_fmt=high&_orig=search&_origin=search&_sort=d&_docanchor=&view=c&_acct=C000024218&_version=1&_urlVersion=0&_userid=496085&md5=c5ff1b4972e028e3f9fb693be8a52d52&searchtype=a> ចូលអានកាលពីថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១០

ចរដែន ស្វានសុន "ការវាយប្រហារដោយអាស៊ីដ ៖ កិច្ចខិតខំប្រឹងប្រែងរបស់បង់ក្លាដែសដើម្បីបញ្ឈប់អំពើហិង្សា" សុខភាពអន្តរជាតិ (២០០២) ភាគទី៣ <http://www.hcs.harvard.edu/~epihc/currentissue/spring2002/swanson.php> ចូលអានកាលពីថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១០

លីហ្សា អែម ថៃល័រ "ការសង្គ្រោះផ្ទៃមុខ ៖ ច្បាប់ស្ដីពីអំពើហិង្សាដោយអាស៊ីដ បន្ទាប់ពីមានការបង្កើត កតិកាសញ្ញាស្ដីពីការលុបបំបាត់ការរើសអើងគ្រប់ទម្រង់ប្រឆាំងនឹងស្ត្រី" សារព័ត៌មានចចជៀរស្ដីពីច្បាប់អន្តរជាតិ និងបែបប្រៀបធៀប ភាគទី២៩ (២០០០-២០០១) ៣៩៥-៤២៦

## អត្ថបទសារព័ត៌មាន

អាលីស ហ្វុសស្ទ័រ "មនុស្សចំនួន៣៦នាក់ រងគ្រោះដោយសារអាស៊ីដក្នុងឆ្នាំ២០១០ យោងតាមអង្គការសង្គ្រោះជនរងគ្រោះ" ឌឹ ខែមបូឌា ដេលី ថ្ងៃទី០៥ ខែមករា ឆ្នាំ២០១០

ឆេង សុខុម "ស្ត្រីម្នាក់ទទួលការព្យួរទោសចំនួន ៣ឆ្នាំ ក្នុងករណីវាយប្រហារដោយអាស៊ីដ" ឌឹ ខែមបូឌា ដេលី ថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១១

ហ្គាយ ឌីឡនីយ "ជនរងគ្រោះដោយអាស៊ីដនៅកម្ពុជាទាមទារស្វែងរកភាពយុត្តិធម៌" ប៊ី ប៊ី ស៊ី (ភ្នំពេញ ថ្ងៃទី២២ ខែមិនា ឆ្នាំ២០១០) <http://news.bbc.co.uk/2/hi/asia-pacific/8576195.stm> ចូលអានកាលពីថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១០

មុំ គន្ធា "តុលាការចោទប្រកាន់បុគ្គលបីនាក់ ក្នុងករណីវាយប្រហារនៅរាជធានី" ភ្នំពេញប៉ុស្តិ៍ ថ្ងៃទី២១ ខែមករា ឆ្នាំ២០១១

មុំ គន្ធា "បុគ្គលបីនាក់ត្រូវបានចោទប្រកាន់ក្នុងបទវាយប្រហារដោយអាស៊ីដ" ភ្នំពេញប៉ុស្តិ៍ ថ្ងៃទី២៤ ខែមករា ឆ្នាំ ២០១១

ផន បុប្ផា និង សែម៉ុន ម៉ាក "សេចក្តីព្រាងច្បាប់អាស៊ីដ មានរយៈពេលត្រឹមតែពីរបីអាទិត្យទៀតទេ យោងតាមសម្តីរបស់មន្ត្រីម្នាក់" សារព័ត៌មាន ឌឹ ខែមបូឌា ដេលី ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១០

ផន បុប្ផា និង សែម៉ុន ម៉ាក "សេចក្តីព្រាងច្បាប់អាស៊ីដចែងពីការផ្តន្ទាទោសដ៏ធ្ងន់ធ្ងរ" សារព័ត៌មានឌឹខែមបូឌា ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១០

រ៉ូឡែន បើក "បញ្ហាការវាយប្រហារដោយអាស៊ីដរបស់ប្រទេសបង់ក្លាដែស" ប៊ី ប៊ី ស៊ី (ដាកា ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៦) < http://news.bbc.co.uk/2/hi/5133410.stm>, ចូលអានកាលពីថ្ងៃទី១៦ ខែមករា ឆ្នាំ២០១១

ឃី សុវុឌ្ឍី និង ហ្សមប័រ ភីតទ័រ "ជនសង្ស័យក្នុងករណីវាយប្រហារដោយទឹកអាស៊ីដត្រូវបានសាកសួរកាលពីម្សិលមិញ" សារព័ត៌មាន ឌឹ ខែមបូឌា ដេលី ថ្ងៃទី២១ ខែមករា ឆ្នាំ២០១១

ឃី សុវុឌ្ឍី "បុគ្គលបីនាក់ត្រូវបានបើកសវនាការ ពីបទចោទប្រកាន់ក្នុងការវាយប្រហារមួយក្នុងទីក្រុងភ្នំពេញ" សារព័ត៌មាន ឌឹ ខែមបូឌា ដេលី ថ្ងៃទី១១-១២ ខែមិថុនា ឆ្នាំ២០១១

ឃី សុវុឌ្ឍី "តុលាការក្រុងភ្នំពេញ ផ្តន្ទាទោសបុគ្គល ៣នាក់ ក្នុងករណីវាយប្រហារដោយអាស៊ីដ" សារព័ត៌មាន ឌឹ ខែមបូឌា ដេលី ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១១

## គេហទំព័រ

មូលនិធិជនរងគ្រោះដោយសារអាស៊ីដ (ម.ជ.អ) <http://www.acidsurvivors.org/> ចូលអានកាលពីថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១០